សំណួរអំពីអានិសង្សសេនាសនៈទាន

សំណួរ ៈតើពាក្យថា **អានិសង្ស** ប្រែដូចម្តេច និងមានន័យយ៉ាងណា ?

ឆ្លើយថា ៈ ពាក្យថា **អានិសង្ស** ប្រែថា ប្រយោជន៍ ផលរបស់បុណ្យ មានន័យថា ផលដែលទទួលបានពីកុសលដូចជាអានិសង្សរបស់ទាន អានិសង្សរបស់សីល សមាធិ បញ្ញា ។

ម្យ៉ាងទៀត ពាក្យថាអានិសង្សនេះ គឺអាចនិយាយបានតែជាមួយកុសលប៉ុណ្ណោះ មិនអាចនិយាយថា អានិសង្សរបស់បាបបានឡើយ បើផ្នែកខាងអកុសលគឺនិយាយថាអ្នកធ្វើបាបទទួលផលរបស់បាប ។

ពាក្យថា **សេនាសនៈ** ប្រែដូចម្តេច ?

ពាក្យថា **សេនាសនៈ** ប្រែថា ទីដេក ទីអង្គុយ (វិហារ កុដិ សាលា ឬ

ផ្ទះជាដើម) ។

ពាក្យថា **ទានៈ** ប្រែដូចម្តេច ?

ពាក្យថា **ទានៈ** ប្រែថា ការឱ្យ ។

សរុបសេចក្តីមក ពាក្យថា **អានិសង្សសេនាសនៈទាន** មានន័យថា

អានិសង្ស (ផល) ដែលកើតអំពីការឱ្យនូវទីដេក ទីអង្គុយជាដើម ។

# សន្សំបុណ្យដោយការសាង សេនាសនទាន

បើមានតែប្រាក់បន្តិចបន្តួចហើយបានចូលរួមកសាងវិហារ កុដិ សាលា ស្ពានថ្នល់ជាដើមជាមួយនឹងអ្នកដទៃ តើឈ្មោះថាបានសម្រេចជាទីសេនាសនៈទានដែរឬទេ ?

ពុទ្ធបរិស័ទសម័យបច្ចុប្បន្ននេះដោយច្រើនធ្វើទានដោយកម្លាំងសាមគ្គី ដូចជាសាងព្រះវិហារមួយរួមគ្នា កុដិសាលាមួយរួមគ្នារាប់រយពាន់នាក់ ទើបបានសម្រេចនូវសមិទ្ធិមួយៗ ហើយបុណ្យកុសលក៏បានសម្រេចច្រើនក្នុងសន្តានចិត្តរៀងៗខ្លួន តាមកម្លាំងចេតនារបស់អ្នកបរិច្ចាគនោះ ហើយក៏បានឈ្មោះថាជាអ្នកធ្វើនូវទីសេនាសនៈទានដែរ ។

# ឱ្យទីជ្រកអាស្រ័យ គឺឱ្យនូវសេចក្តីសុខ

បញ្ចខន្ធកើតឡើងក្នុងលោកជារបស់ពុកផុយណាស់ ងាយនឹងទទួលរងនូវសេចក្តីទុក្ខអំពីរបស់ទាំងឡាយទាំងពួង ដូចជា ក្តៅ ត្រជាក់ របោម មូស ខ្យល់ ពស់តូច ពស់ធំទាំងឡាយជាដើម ប្រសិនបើមានបច្ច័យទាំងបួនជួយទំនុកបម្រុងខ្លះ សេចក្តីទុក្ខក៏អាចធូរស្រាលបានមួយចំនួនដែរ ព្រោះហេតុដូច្នេះហើយ បានជាព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃទាំងឡាយទទួលប្រើប្រាស់បច្ច័យទាំងបួន សមរម្យតាមកាល និង ជារបស់ដែលគួរភិក្ខុដែលជាអ្នកប្រើប្រាស់បច្ច័យទាំងនោះ គឺមានសតិស្មារតីមុននឹងប្រើ កំពុងប្រើ និងប្រើប្រាស់រួចហើយ កាលភិក្ខុប្រើប្រាស់ប្រកបដោយបញ្ញាដូច្នេះ ចិត្តក៏

មិនជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ រលាស់ខ្លួនមិនឱ្យជិតដាមក្នុងបាបអកុសល ទីបំផុតក៏ដល់ព្រះនិព្វាន ដូច្នេះភិក្ខុសង្ឃដែលលោកប្រើប្រាស់នូវទីសេនាសនៈ បច្ច័យប្រកបដោយសតិស្មារតី មានប្រយោជន៍ដល់លោកអ្នកប្រើប្រាស់ផង និងបានកុសលដល់អ្នកបរិច្ចាគនូវទីសេនាសនៈនោះផង ។

## អ្នកឱ្យនូវទីសេនាសនៈ ឈ្មោះថាឱ្យនូវវត្ថុគ្រប់យ៉ាង

អ្នកឱ្យនូវទីដេក ទីអង្គុយ ឈ្មោះថា ឱ្យនូវវត្ថុគ្រប់យ៉ាង ព្រោះគ្រប់ឥរិយាបថទាំងបួន គឺដេក ដើរ ឈរ អង្គុយ តែងតែមាននូវសេនាសនៈដែរ ជាគ្រឿងបិទបាំងឬជួយទ្រទ្រង់ដូចជា ក្នុងខណៈដែលយើងដេក ក៏ត្រូវមានទីដេកដូចជា គ្រែ ពូក កន្ទេលខ្នើយសម្រាប់ដេកក្នុងទីនោះៗ បើមិនមានគ្រែ

ពូកកន្ទេលជាដើមទេ យ៉ាងហោចណាស់ក៏មានក្តារមួយបន្ទះ រនាប៤-៥ជរៀក ឬស្លឹកឈើមួយបាច់សម្រាប់ទ្រាប់ឬកើយក្នុងទីនោះទើបអាចដេកទៅបាន មិនសូវទទួលនូវសេចក្តីទុក្ខ ព្រោះមានអាសនៈប្រណីត ឬ ថៅកទាបសម្រាប់ប្រើប្រាស់ ។

ក្នុងខណៈដែលយើងដើរ ក៏ត្រូវមានទីសេនាសនៈសម្រាប់ខ្លួនយើងដែរ ដូចជាយើងមានស្បែកជើងសម្រាប់ពាក់ ការពារគ្រួសឬបន្លា មានឆ័ត្រសម្រាប់បាំងភ្លៀងឬកំដៅថ្ងៃ ជាពិសេសពេលយើងដើរនោះក៏ត្រូវមានផ្លូវថ្នល់ដែលគេបានត្រួសត្រាយហើយ និងស្ពានដែលសង់សម្រាប់ឆ្លងប្រឡាយ អូរស្ទឹងទន្លេជាដើម ទាំងនេះជាទីសេនាសនៈដ៏សំខាន់ ដែលមិនអាចអត់បាន

សម្រាប់មនុស្សគ្រប់រូប ដូច្នេះបុគ្គលណាដែលបានធ្វើថ្នល់ សាងស្ពានជាដើម សម្រាប់មនុស្សទូទៅ គឺឈ្មោះថា ធ្វើនូវប្រយោជន៏ដល់ជនទាំងឡាយផង សម្រាប់ខ្លួនឯងផង ។

ក្នុងខណៈដែលឥរិយាបថប្រព្រឹត្តទៅជាការអង្គុយ ឬឈរ ក៏ត្រូវមានទីសេនាសនៈសម្រាប់ទ្រទ្រង់ក្នុងពេលនោះដែរដូចជា តុ កៅអី សាឡុង ឬវត្ថុណាដែលមានដំបូលប្រក់ ឬម្លប់ឈើជាដើម ទើបឥរិយាបថនោះប្រព្រឹត្តទៅបាន មិនសូវជួបប្រទះនូវទុក្ខវេទនា ដូច្នេះហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គត្រាស់ថា អ្នកឱ្យនូវទីសេនាសនៈឈ្មោះថា ឱ្យនូវវត្ថុគ្រប់យ៉ាង ។

# ប្រយោជន៍របស់អ្នកសាងសេនាសនទានមានច្រើនយ៉ាង

- អ្នកឱ្យនូវទីសេនាសនៈឈ្មោះថា ឱ្យនូវសេចក្ដីសុខ

- អ្នកឱ្យនូវទីសេនាសនៈឈ្មោះថា

ឱ្យនូវសេចក្ដីសប្បាយដល់អ្នកដទៃ

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកមានមេត្តាចិត្តក្នុងខ្លួន

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកមានករុណាចិត្តក្នុងខ្លួន

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកមានចិត្តស្ងប់ត្រជាក់ល្អ

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកចង់ឱ្យគេបាននូវប្រយោជន៍

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកមានបញ្ញាក្នុងខ្លួន

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកបានលះបង់នូវសេចក្ដីកំណាញ់

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកប្រព្រឹត្តវត្តបដិបត្តិដូចសក្កទេវរាជ

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកប្រព្រឹត្តដូចព្រះពោធិសត្វ

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកសាងវិហារធមិសម្រាប់ខ្លួន

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកធ្វើឱ្យអ្នកដទៃត្រជាក់កាយនិង

ធ្វើឱ្យខ្លួនឯងបានត្រជាក់ចិត្ត ព្រោះសម្រេចបុណ្យកុសលដ៏ច្រើន

- អ្នកឱ្យនូវទីសេនាសនៈឈ្មោះថាឱ្យនូវទីពឹងសម្រាប់ជនទាំងឡាយ

- អ្នកឱ្យនូវទីសេនាសនៈ គឺជាអ្នកបានជួយទំនុកបម្រុងថែរក្សាភិក្ខុ

សង្ឃក្នុងព្រះពុទ្ធសាសនា ធ្វើឱ្យព្រះពុទ្ធសាសនារុងរឿងបានមួយចំណែកធំ ។

# ការឱ្យយានជំនិះ

**យានទោ សុខទោ ហោតិ** ការឱ្យយានឈ្មោះថា ឱ្យនូវសេចក្តីសុខ ព្រោះឱ្យអ្នកដទៃ ងាយស្រួលក្នុងការធ្វើដំណើរ ឱ្យបានឆាប់រហ័សទាន់ពេលវេលា យានដែលត្រូវឱ្យដូចជា ឈើច្រត់ ស្បែកជើង ក្រែស្នែង អង្រឹងសែងរទេះ និង យានដែលមានជីវិតដូចជា សត្វគោ សេះ ដំរីជាដើម ដែលអាចជាយានរបស់មនុស្សបាន និង រថយន្តគ្រប់ប្រភេទដូចជា ឡាន ម៉ូតូ កង់ជាដើម ការឱ្យប្រើប្រាស់នូវយានទាំងនោះរហូតក្តី មួយរយៈក្តី ឱ្យខ្ចីក្តី ឱ្យគេជិះទៅជាមួយខ្លួនក្តី ឬទិញសំបុត្ររថយន្តធ្វើដំណើរឱ្យក្តី ទាំងនេះហៅថាការឱ្យយាន ។ បុគ្គលគួរគប្បីសន្សំបុណ្យក្នុងការឱ្យយានជាទានឱ្យបានច្រើន ព្រោះនាំមកនូវសេចក្តីសុខដល់ជនដទៃ និងបានសេចក្តីសុខសម្រាប់ខ្លួនឯងក្នុងបច្ចុប្បន្ននិងទៅបរលោក ។

# ការដាំដើមឈើឈ្មោះថាធ្វើទីសេនាសនៈទាន

វុក្ខជាតិទាំងឡាយដែលបានដុះហើយលើផែនដី ធំក្តី តូចក្តី ជាវុក្ខជាតិដុះឯងឬមានមនុស្សដាំ គឺជាជម្រកយ៉ាងត្រជាក់សម្រាប់មនុស្ស និង សត្វ ដូចជាដើមឈើដែលនៅតាមព្រៃភ្នំជាជម្រករបស់សត្វព្រៃទាំងឡាយដូចជា ដំរី រមាំង ប្រើស ក្តាន់ ជាដើម និងសត្វបក្សាបក្សីជាច្រើនទៀតដែលបានរស់នៅតាមព្រៃឈើទាំងឡាយនោះ ។

ចំណែកវុក្ខជាតិដែលដុះក្នុងស្រុក ជាជម្ររបស់សត្វស្រុកទាំងឡាយ និង ជាជម្រករបស់មនុស្ស ជាគ្រហស្ថ ឬ បព្វជិត ។ ដើមឈើណានៅតាមដងផ្លូវ គឺជាទីពឹងរបស់អ្នកធ្វើដំណើរទាំងឡាយ គឺអ្នកដំណើរ

ទាំងនោះតែងចូលទៅសម្រាកកាយ បរិភោគអាហារប្រកបដោយសេចក្ដីរីករាយក្រោមម្លប់ឈើនោះ ។

បើដើមឈើណាដែលព្រះសង្ឃឬពុទ្ធបរិស័ទបានដាំនៅក្នុងអារាម គឺដើមឈើនោះមានប្រយោជន៍សម្រាប់ព្រះសង្ឃផងពុទ្ធបរិស័ទផងបានជ្រកក្រោមម្លប់ញ៉ាំងឱ្យកម្លាំងកាយកើតឡើង ហើយបានបំពេញបុណ្យកុសលផ្សេងៗ នៅខាងក្រោមម្លប់ឈើទាំងនោះ ។ម្យ៉ាងទៀតរុក្ខជាតិខ្លះដែលបានដាំបណ្ដុះអាចនឹងមានផ្កាមានផ្លែនិងស្លឹកជាអាហាររបស់មនុស្សសត្វទាំងឡាយ ដូចជា ដើមត្នោត ដើមដូង ដើមស្វាយ ដើមអង្គាដីជាដើម រុក្ខជាតិទាំងនោះមានប្រយោជន៍ គឺ ជាទីជម្រកដ៏ត្រជាក់ របស់

មនុស្សសត្វទាំងឡាយ និងជាអាហាររបស់មនុស្សសត្វទាំងឡាយ ។

ដូច្នេះបើបុគ្គលឯណាបានដាំដើមឈើតាមដងវិថីក្តីតាមទីរមណីយ-

ដ្ឋានក្តី តាមទីសាធារណៈក្តី និងក្នុងវត្តអារាមក្តី គឺរមែងបានប្រយោជន៍

ពីរយ៉ាង គឺប្រយោជន៍សម្រាប់ខ្លួនឯងមួយ សម្រាប់អ្នកដទៃមួយ ។

**ប្រយោជន៍សម្រាប់ខ្លួនឯងតើដូចម្តេច?**

ក្នុងបច្ចុប្បន្ននេះ នឹង មានអ្នកសរសើររាប់អានគេតែងនិយាយថា

លោកអ៊ុំ លោកតា លោកយាយឈ្មោះនេះ បានដាំដើមឈើនៅត្រង់នេះ

ត្រង់នោះជាដើម ហើយអ្នកផងតែងនិយាយទៀតថា អ្នកដាំដើមឈើ

នេះគឺជាអ្នកមានមេត្តា មានករុណានិងមានបញ្ញាវាងវៃទើបបានថែរក្សា

ដើមឈើទាំងនេះទុកឱ្យជាប្រយោជន៍ដល់មនុស្សសត្វទូទៅម្យ៉ាងទៀត អ្នកដាំដើមឈើជាទាន ក្នុងបរលោក រមែងបាននូវសម្បត្តិមនុស្ស និង សម្បត្តិទេវតានិង រួចផុតចាកទុក្ខ ។

**ប្រយោជន៍សម្រាប់អ្នកដទៃ តើដូចម្ដេច ?**

គឺបានឱ្យអ្នកដទៃជ្រកអាស្រ័យផង និងញុំាំងធាតុអាកាសក្នុង ស្រុកនោះៗ ឱ្យប្រព្រឹត្តិទៅបានល្អ ដូចជាការ ការពារខ្យល់ព្យុះជាដើម ។

ហេតុដូច្នេះយើងទាំងអស់គ្នាត្រូវចេះដាំដើមឈើនិងជួយថែរក្សាព្រៃ ឈើឱ្យបានគង់វង្ស ដើម្បីជាប្រយោជន៍ខ្លួនឯងនិងដល់សង្គមជាតិ ។

ព្រោះដាំដើមឈើមួយដើមដូចជាបានកសាងផ្ទះមួយខ្នងឱ្យទៅ ជាទានដូច្នោះដែរ ។

# សេនាសនក្ខន្ធកៈ

សម័យនោះព្រះពុទ្ធមានព្រះភាគ គង់នៅវត្តវេឡុវ័នកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯងព្រះមានព្រះភាគមិនទាន់បានបញ្ញត្តិសេនាសនដល់ពួកភិក្ខុនៅឡើយ ។ ភិក្ខុទាំងនោះក៏នៅក្នុងទីនោះ៧ គឺ ព្រៃ គល់ឈើ ភ្នំ ច្រក គុហាទ្បេបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្ដាលវាល និងគំនរចំបើង ។ លុះព្រលឹមឡើងភិក្ខុទាំងនោះដើរចេញអំពីទីនោះ ៧ គឺ ព្រៃ គល់ឈើ ភ្នំ ច្រក គុហាទ្បេបភ្នំ ព្រៃស្មសាន ព្រៃធំទីកណ្ដាលវាល និងគំនរចំបើង សឹងមានភិក្ខុសម្លឹងចុះ បរិបូរណ៍ដោយឥរិយាបថ គឺឈានទៅមុខ ថយក្រោយ ក្រឡេកស្ដាំ ក្រឡេកឆ្វេង បត់ចូល លាចេញ គួរឱ្យកើតសេចក្ដីជ្រះថ្លា ។

គ្រានោះឯង រាជគហសេដ្ឋីបានទៅឧទ្យានអំពីព្រលឹម ។ រាជគហសេដ្ឋី

ក៏បានឃើញភិក្ខុទាំងនោះ កំពុងនិមន្តចេញពីទីនោះ ៗ គឺព្រៃ គល់ឈើ ភ្នំ ច្រក

គុហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្តាលវាល និងគំនរចំបើងអំពីព្រលឹម-

ដែរ សឹងមានចក្ខុសំម្លឹងចុះ បរិបូរណ៏ដោយឥរិយាបថ គឺឈានទៅមុខ ថយ

ក្រោយក្រឡេកស្តាំ ក្រឡេកឆ្វេង បត់ចូលលាចេញ គួរឱ្យកើតសេចក្តីជ្រះថ្លា ។

លុះរាជគហសេដ្ឋីនោះឃើញហើយ ក៏មានចិត្តជ្រះថ្លា ។ លំដាប់នោះ រាជ-

គហសេដ្ឋីក៏ដើរចូលទៅរកពួកភិក្ខុនោះ លុះចូលទៅដល់ហើយបាននិយាយ

ពាក្យនេះនឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចំរើន ប្រសិនបើខ្ញុំ

ព្រះករុណាឱ្យគេធ្វើវិហារ( ប្រគេន) តើលោកម្ចាស់ទាំងឡាយ នឹងនៅក្នុង

វិហាររបស់ខ្ញុំព្រះករុណាឬទេ? ។ ភិក្ខុនោះឆ្លើយថា ម្នាលគហបតិ ព្រះដ៏មានព្រះភាគទ្រង់មិនទាន់បានអនុញ្ញាតវិហារទេ ។ រាជគហសេដ្ឋីឆ្លើយថា បពិត្រលោកទាំងឡាយដ៏ចំរើន បើដូច្នោះសូមលោកម្ចាស់ក្រាបបង្គំទូលសួរ ចំពោះព្រះមានព្រះភាគ (អំពីរឿងវិហារនោះ) ហើយមេត្តាប្រាប់ដល់ខ្ញុំព្រះករុណាផង ។ ភិក្ខុទាំងនោះទទួលស្តាប់ពាក្យរាជគហសេដ្ឋី ដោយពាក្យថាយ៉ាងហ្នឹងហើយ គហបតិ រួចក៏ចូលទៅកាន់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគរួចអង្គុយក្នុងទីដ៏សមគួរ ។ ភិក្ខុទាំងនោះអង្គុយ ក្នុងទីដ៏សមគួរហើយក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន រាជគហសេដ្ឋីមានសេចក្តីប្រាថ្នានឹងឱ្យគេធ្វើវិហារ

បពិត្រព្រះអង្គដ៏ចំរើន តើយើងខ្ញុំគប្បីប្រតិបត្តិដូចម្ដេច? ។

ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយ

ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា

**អនុជានាមិ ភិក្ខវេ បញ្ច សេនា-**

**សនានិ វិហារំ អឌ្ឍយោគំ បាសាទំ**

**ហម្មិយំ គុហន្តិ ។**

ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេនាសនៈប្រាំយ៉ាងគឺ

វិហារ អឌ្ឍយោគ ប្រាសាទ ហម្មិយ គុហា។

**វិហារ** លំនៅដែលក្រៅពីសេនាសនៈមាន អឌ្ឍយោគជាដើម។

**អឌ្ឍយោគ** គឺផ្ទះមានសណ្ឋានដូចស្លាបគ្រុឌ ឬផ្ទះដែលមានកំពូលតែម្ខាង គឺបង្ការ ។

**ប្រាសាទ** គឺប្រាសាទវែង ។

**ហម្មិយ** ផ្ទះ ឬប្រាសាទដែលមានកំពូល ។

**គុហា** គុហាដែលធ្វើដោយឥដ្ឋ ដោយថ្ម ដោយឈើ ដោយអាចម៍ដី ឬដែលកើតឯងក្នុងភ្នំ ( អដ្ឋកថាពន្យល់សេនាសនៈទាំង៥នេះយ៉ាងនេះឯង ) ។

គ្រានោះ ពួកភិក្ខុនោះចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងរាជគហសេដ្ឋីថា ម្នាលគហបតិ ព្រះមានព្រះភាគទ្រង់អនុញ្ញាតវិហារហើយ ឥឡូវនេះអ្នកយល់ថាកាលណាគួរ( ក៏គប្បីធ្វើចុះ) ។

គ្រានោះ រាជគហសេដ្ឋីឱ្យគេសាងវិហារចំនួន ៦០ តែមួយថ្ងៃគត់ ក៏ហើយជាស្រេច ។ រាជគហសេដ្ឋីឱ្យគេសាងវិហារ ៦០ រួចស្រេចហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ រាជគហសេដ្ឋី អង្គុយក្នុងទីសមគួរហើយបានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគថា  បពិត្រព្រះអង្គដ៏ចំរើនសូមព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃទទួលភត្តរបស់ព្រះអង្គដើម្បីធ្វើភត្តកិច្ចក្នុងថ្ងៃស្អែក ។ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គ្រានោះរាជគហសេដ្ឋីដឹងច្បាស់ថា ព្រះមានព្រះភាគទទួលនិមន្តហើយក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណរួចចៀសចេញទៅ ។ គ្រាកាលកន្លងរាត្រី

នោះទៅ រាជគហសេដ្ឋីក៏ឱ្យតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ហើយឱ្យ

ទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន

វេលាដល់ហើយ ភត្តសម្រេចហើយ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់និងបាត្រចីវរក្នុងវេលាបុព្វណ្ហ

សម័យ ហើយទ្រង់យាងទៅកាន់លំនៅនៃរាជគហសេដ្ឋី លុះយាងទៅដល់

ហើយគង់លើអាសនៈដែលគេក្រាល (បម្រុងទុក) មួយអន្លើដោយភិក្ខុសង្ឃ ។

ឯរាជគហសេដ្ឋី បានអង្គាសខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសារដោយដៃ

ខ្លួនឯង ថ្វាយចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ លុះ

ព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្ថទៅក្នុងបាត្រហើយ

(សេដ្ឋីនោះ) ក៏អង្គុយក្នុងទីសមគួរ ។ រាជគហសេដ្ឋី លុះអង្គុយក្នុងទីសមគួរ ហើយ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើនខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបុណ្យនិងឋានសួគ៌ បានសាងវិហារទាំង ៦០ខ្នង ស្រេចហើយបពិត្រព្រះអង្គដ៏ចំរើនខ្ញុំព្រះអង្គនឹងប្រតិបត្តិក្នុងវិហារទាំងនោះដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថាម្នាលគហបតិបើដូច្នោះអ្នកចូរប្រតិស្ឋានវិហារទាំង ៦០ នោះ សម្រាប់សង្ឃដែលមកហើយ និងមិនទាន់មកអំពីទិសទាំង ៤ ចុះ ។ រាជគហសេដ្ឋីទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ រួចហើយក៏ប្រតិស្ឋានវិហារទាំង ៦០ នោះ ដើម្បីសង្ឃ ដែលមកហើយទាំងមិនទាន់មក អំពីទិសទាំង ៤ ។ ទើបព្រះមានព្រះ

ភាគទ្រង់អនុមោទនាចំពោះរាជគហសេដ្ឋីដោយគាថាទាំងឡាយនេះថា

សីតំ ឧណ្ហំ បដិហន្តិ　　តតោ ពាឡមិគានិ ច

សិរីសពេ ច មកសេ　　សិសិរេ បាពិ វុដ្ឋិយោ

តតោ វាតាតបោ ឃោរោ　　សញ្ជាតោ បដិហញ្ញតិ ។

លេណត្ថញ្ច សុខត្ថញ្ច　　ឈាយិតុញ្ច វិបស្សិតុំ

វិហារទានំ សង្ឃស្ស　　អគ្គំ ពុទ្ធេហិ វណ្ណិតំ ។

តស្មា ហិ បណ្ឌិតោ បោសោ　　សម្បស្សំ អត្ថមត្តនោ

វិហារេ ការយេ រម្មេ　　វាសយេត្ថ ពហុស្សុតេ ។

តេសំ អន្នញ្ច បានញ្ច　　វត្ថសេនាសនានិ　ច

**ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា**

**តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខា បនូទនំ**

**យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតិ អនាសវោតិ ។**

(វិហារ គឺ ទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូច និងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់និងកំដៅថ្ងៃដ៏ក្លាខ្លាំងដែលកើតឡើងហើយរមែងបាត់ទៅវិញព្រោះវិហារនោះ ៗ ។ វិហារទាន គឺ ការឱ្យលំនៅ (ដែលបុគ្គលបានឱ្យហើយ) ដល់សង្ឃដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីផុតបាបធម៌ផង

ដើម្បីចំរើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយតែងសរសើរ ថាជាទានដ៏ប្រសើរ ។

ព្រោះហេតុនោះបុរស ស្ត្រី ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រ-យោជន៍របស់ខ្លួន ក៏គួរសាងព្រះវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោកដែលជាពហុស្សូត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយឱ្យនៅក្នុងទីនោះ ។ គួរមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយដែលមានចិត្តត្រង់ ហើយប្រគេនបាយទឹក សំពត់ និងសេនាសនៈទាំងឡាយដល់លោកទាំងនោះចុះ ។ លោកទាំងនោះរមែងសំដែងធម៌ជាគ្រឿងបន្ទោរបង់ឱ្យឃ្លាតចាកទុក្ខគ្រប់ប្រការដល់អ្នកនោះលុះអ្នកនោះបានដឹងធម៌ណាក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈរមែងបរិនិព្វាន ។

## ពុទ្ធបញ្ញត្តិ(គ្រែ តាំង)

ក្នុងវិន័យបិដក មហាវិភង្គ ភាគ៤ ទំព័រ៣៨៦ ទ្រង់ត្រាស់ថា

**នវំ បន ភិក្ខុនា មញ្ចំ វា បីឋំ វា**

**ការយមានេន អដ្ឋង្គុលបាទកំ ការេតព្វំ**

**សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ**

**អដនិយា តំ អតិក្កមយតោ ឆេទនកំ បាចិត្តិយំ ។**

ភិក្ខុឱ្យគេធ្វើគ្រែក្តីតាំងក្តីត្រូវឱ្យធ្វើមានជើង ៨ធ្នាប់ព្រះសុគតវាស់ពីត្រឹមមេគ្រែខាងក្រោម ចុះទៅ(បើធ្វើ)ឱ្យកន្លងពីនោះទៅ ត្រូវឆេទនកបាចិត្តិយៈ ។

## គ្រែដែលទ្រង់អនុញ្ញាតមាន ៤យ៉ាង គឺ

**១-មសារកៈ** គ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង

**២-ពុន្ទិកាពទ្ធៈ** គ្រែដែលគេភ្ជាប់មេនឹងជើង

**៣- កុឡិរបាទកៈ** គ្រែដែលមានជើងដូចជាជើងក្ដាម

**៤- អាហច្ចបាទកៈ** គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលទៅក្នុងដំណាប់មេ ។

## តាំងដែលទ្រង់អនុញ្ញាតមាន ៤យ៉ាង គឺ

**១-មសារកៈ** តាំងដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង

**២-ពុន្ទិកាពទ្ធៈ** តាំងដែលគេភ្ជាប់មេនឹងជើង

**៣- កុឡិរបាទកៈ** តាំងដែលមានជើងដូចជាជើងក្ដាម

**៤-អាហច្ចបាទកៈ** តាំងដែលមានជើងចុចបតាំងដែលគេបញ្ចូលទៅ

ក្នុងដំណាប់មេ ។

ក្រែនិងតាំងទាំងអស់គឺត្រូវមានកំពស់ល្មមប្រមាណ ទើបប្រើប្រាស់បានដេកបាន អង្គុយបាន បើក្រែ និង តាំង នោះខ្ពស់ហួសប្រមាណ គឺសុទ្ធតែជាក្រែ និងតាំង ដែលទ្រង់ហាមទាំងអស់ ។ កំពស់ ប្រមាណដែលព្រះសម្មា-សម្ពុទ្ធទ្រង់ អនុញ្ញាតនោះគឺ ជើងក្រែ និងជើង តាំង មានកំពស់ ៨ ធ្នាប់ដោយធ្នាប់ព្រះសុគត វាស់ត្រឹមមេក្រែចុះក្រោម ។ បើលើសពី ៨ធ្នាប់ព្រះសុគតនោះមិនគួរ ។

ក្រែនិងតាំងដែលខ្ពស់ហួសប្រមាណឈ្មោះថា **ឧច្ចាសយនះ**គឺទីដេកទីអង្គុយដែលខ្ពស់ហួសប្រមាណ ចំណែកឯ **មហាសយនា** វិញនោះគឺទ្រង់សំដៅដល់ទីសេនាសនៈដ៏ប្រសើរបានដល់គ្រឿងក្រាលដែលជា**អកប្បិយៈ**២០យ៉ាងគឺ

១-**អាសន្ទិ** អាសនៈខ្ពស់ហួសប្រមាណ

២-**បល្លង្កៈ** ក្រែដែលវិចិត្រដោយរូបសត្វសាហាវ

៣-**គោណកៈ** ព្រំដែលមានរោមវែងជាង ៤ធ្នាប់

៤-**ចិត្តកៈ** កម្រាលដែលគេធ្វើដោយរោមសត្វ( រោមកែះ)

៥-**បដិកៈ** កម្រាលពណ៌ស ដែលធ្វើដោយរោមសត្វ( រោមកែះ)

៦-**បដិលិកៈ** កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម

៧-**តូលិកៈ** កម្រាលដែលញាត់ដោយសំឡីគជាប្រក្រតី

៨-**វិកតិកៈ** កម្រាលដែលធ្វើដោយរោមសត្វវិចិត្រដោយរូបសត្វមាន សីហៈ និងខ្លាធំជាដើម

៩-**ឧទ្ធលោមិ** កម្រាលធ្វើដោយរោម មានរោមច្រាងឡើងតែម្ខាង

១០-**ឯកន្តលោមិ** កម្រាលដែលធ្វើដោយរោមសត្វមានរោមច្រាង ឡើងទាំងសងខាង

១១-**កដិស្សៈ** កម្រាលដែលធ្វើដោយឱនមាស និងសូត្រហើយចាក់ស្រេះដោយរតនៈ

១២-**កោសេយ្យះ** កម្រាលដែលធ្វើដោយសរសៃសូត្រហើយចាក់ស្រេះដោយ

រតនះ

១៣-**កុត្តកះ** កម្រាលដែលធ្វើដោយរោមសត្វ ល្មមចុះពួកស្រីរបាំ១៦នាក់

ឈររាំបាន

១៤-**ហត្ថត្ថរះ** កម្រាលសម្រាប់ក្រាលលើខ្នងដំរី

១៥-**អស្សត្ថរះ** កម្រាលសម្រាប់ក្រាលលើខ្នងសេះ

១៦-**រថត្ថរះ** កម្រាលសម្រាប់ក្រាលលើរថ

១៧-**អជិនប្បវេណី** កម្រាលដែលគេធ្វើដោយស្បែកខ្លា

១៨-**កទលិមិគប្បវរប្បច្ចត្ថរណំ** កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វ

ឈ្លូស

១៩-**សឧត្តរច្ឆទំ** ខ្នើយមានពណិក្រហមទាំងពីរខាង

២០-**ឧភតោលោហិតកុបធាន** ព្រមទាំងពិដានដែលមានពណិក្រហម។

តែព្រះអង្គទ្រង់អនុញ្ញាត ថា:

**អនុជានាមិ ភិក្ខវេ ឋបេត្វា តីណិ**

**អាសន្ទឹ បល្លង្កំ តូលិកំ អវសេសំ**

**គិហិវិកដំ អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុំ ។**

ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឱ្យអង្គុយលើអាសនៈដ៏វិសេសជា គិហិវិកដៈគឺអាសនៈដែលប្លែកសម្រាប់គ្រហស្ថបានតែដេកមិនបាន វៀរលែង តែអាសនៈ៣យ៉ាងគឺ អាសន្ទិ ១ បល្លង្កៈ ១ តូលិកៈ ១ ។

បើដូច្នេះ បណ្តាអាសនៈទាំង២០នោះ អាសនៈ៣យ៉ាងគឺ អាសន្ទិ១ បល្លង្កៈ១ តូលិកៈ១ ទាំង៣នេះ ព្រះពុទ្ធដីកាទ្រង់ហាមជាដាច់ខាត ដេកក៏មិនបាន អង្គុយក៏មិនបាន។ ចំណែកអាសនៈ១៧ទៀត បើជារបស់គ្រហស្ថគេដាក់ តាក់តែងដោយខ្លួនឯងក្នុងទីទាំងឡាយមានធម្មាសនៈក្តី ទីដែលទាយកអង្គាស ក្នុងវត្តក្តី ភោជនសាលាក្តី ផ្ទះអ្នកស្រុកក្តី នោះទ្រង់អនុញ្ញាតឱ្យអង្គុយបាន តែ

ដេកមិនបានឡើយ ។ ម្យ៉ាងទៀត អាសនៈទាំង១៧ដែលទ្រង់អនុញ្ញាតឱ្យអង្គុយនោះ គឺអង្គុយបានចំពោះតែអាសនៈជារបស់គ្រហស្ថប៉ុណ្ណោះ បើជារបស់ខ្លួនមិនអាចអង្គុយបានឡើយ ។

# ពូក ៥យ៉ាងទ្រង់អនុញ្ញាត

ក្នុងគម្ពីចុល្លវគ្គ វិន័យបិដកលេខ១០ ទំព័រ២៧៥

**អនុជានាមិ ភិក្ខវេ បញ្ច ភិសិយោ ឧណ្ណភិសិ**

**ចោឡភិសី វាកភិសី តិណភិសី  បណ្ណភិសី ។**

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតពូក ៥យ៉ាង គឺៈ

១-**ឧណ្ណភិសី** ពូកញាត់រោមកែះ

២-**ចោឡភិសី** ពូកញាត់សំពត់

៣- **វាកភិសី** ពូកញាត់សម្បកឈើ

៤- **តិណភិសី** ពូកញាត់ស្មៅ

៥- **បណ្ណភិសី** ពូកញាត់ស្លឹកឈើ ។

# រឿង អម្ពវិមាន

អម្ពវិមាន មានសេចក្ដីថា **ទិព្វំ តេ អម្ពវនំ រម្មំ** ជាដើម។

អម្ពវិមាននោះកើតឡើងដូចម្ដេច ?

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់ក្នុងព្រះវិហារជេតពន ក្រុងសាវត្ថី។ សម័យនោះឧបាសិកាម្នាក់នៅក្នុងក្រុងសាវត្ថី ស្ដាប់ឮថាការថ្វាយអាវាសមានផលច្រើន និងមានអានិសង្ស ច្រើន កើតឆន្ទៈ ពេញចិត្តរីករាយ ថ្វាយបង្គំព្រះដ៏មានព្រះភាគជាម្ចាស់ហើយ ក្រាបទូលយ៉ាងនេះ ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីប្រាថ្នានឹងសាងអាវាសមួយ សូមព្រះមានព្រះភាគ ប្រោសត្រាស់ប្រាប់ឱកាស(ដល់ខ្ញុំព្រះអង្គ) ដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ឱ្យភិក្ខុទាំងឡាយ (សំដែងទីឱ្យដល់

ឧបាសិកានោះ) ភិក្ខុទាំងឡាយបានសំដែងទីដល់ឧបាសិកានោះ, ឧបាសិកា

បាន សាងអាវាសដែលគួរជាទីសប្បាយក្នុងទីនោះហើយឱ្យដាំដើមស្វាយ

នៅជុំវិញអាវាសនោះ ។

អាវាសនោះមានដើមស្វាយព័ទ្ធជុំវិញ សំម្បូរដោយម្លប់ត្រឈឹង

ត្រឈៃ និងទឹក មានទីធ្លាស្អាត ក្រាលពោរពេញដោយខ្សាច់ ប្រហាក់

ប្រហែលគ្នានឹងកែវមុក្តា (ជាទី) គួររីករាយក្រៃលែង ។

នាងតាក់តែងវិហារនោះ ដោយសំពត់មានពណ៌ផ្សេងៗ និង

ដោយភួងផ្កាឈើ និងកម្រង គ្រឿងក្រអូបជាដើម ហាក់ដូចជាវិមាននៃ

ពួកទេវតាបិទបាំងតាក់តែងស្រោចដោយប្រេង( ទឹកដោះ )និងយកសំ-

ពត់ថ្មីរុំដើមស្វាយទាំងឡាយ ហើយវេរថ្វាយចំពោះព្រះសង្ឃ ។

ក្រោយមក នាងធ្វើកាលកិរិយាហើយទៅបដិសន្ធិក្នុងឋានតាវ-តឹង្ស វិមានដ៏ធំអមទៅដោយសួនដើមស្វាយព័ទ្ធជុំវិញ បានកើតប្រាកដ ដល់នាង ។

នាងត្រូវបាន ហែហមចោមរោម ដោយបរិវារជាទេពអប្សរ សោយទិព្វសម្បត្តិនៅក្នុងវិមាននោះ, ព្រះមហាមោគ្គល្លានចូលទៅរក នាងហើយ សួរនាងដោយព្រះថេរៈដីកាជាគាថា ថា

ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយមានប្រាសាទ ខ្ពស់ ធំ ទូលាយក្នុងព្រៃស្វាយនុ៎ះសឹងរងំដោយតូរ្យតន្ត្រីផ្សេងៗគឹកកងដោយពួក ស្រីអប្សរ ទាំងប្រទីបផ្កាលាដ៏ធំជាវិការៈនៃមាស មាន ពួកឈើ ដែលផ្លែ

ចេញជាសំពត់ព័ទ្ធជុំវិញ ក៏ភ្លឺរុងរឿងក្នុងប្រាសាទនោះជានិច្ច ព្រៃស្វាយ

របស់នាង ជាទិព្វ គួរសប្បាយ មានប្រាសាទខ្ពស់ធំទូលាយ តើសម្រេច

ដោយបុណ្យដូចម្ដេច ? សម្បុររបស់នាងប្រាកដដូច្នោះតើសម្រេចដោយ

បុណ្យដូចម្ដេច? ទាំងសម្បុររបស់នាងក៏ភ្លឺច្បាស់សព្វទិស ។

ទេពធីតានោះដែលព្រះមោគ្គល្លានសួរហើយមានចិត្តត្រេកអរក្នុង

ផលនៃកម្មនេះថា ខ្ញុំកាលជាតិមុន កើតជាមនុស្ស ក្នុងពួកមនុស្ស នាម

មនុស្ស ខ្ញុំបានឱ្យជាងធ្វើវិហារ ឧទ្ទិសចំពោះសង្ឃ មានដើមស្វាយព័ទ្ធ

ជុំវិញ កាលធ្វើវិហាររួចស្រេចហើយបានធ្វើបុណ្យឆ្លងខ្ញុំបានដណ្ដប់រុំដើម-

ស្វាយទាំងឡាយធ្វើផ្លែទាំងឡាយជាវិការៈនៃសំពត់ អុជប្រទីបភ្លឺរុងរឿង

ក្នុងព្រៃស្វាយនោះ បានញ៉ាំងព្រះសង្ឃដ៏ឧត្តមជាងគណៈឱ្យឆាន់ក៏មានចិត្ត

ជ្រះថ្លាក៏បានវេរវិហារនោះចំពោះសង្ឃដោយដៃរបស់ខ្លួនដោយបុញ្ញកម្ម

នោះទើបខ្ញុំមានព្រៃស្វាយគួរសប្បាយ មានប្រាសាទ ខ្ពស់ធំទូលាយ ក្នុង

ព្រៃស្វាយនោះសឹងរងំដោយតូរ្យតន្ត្រីផ្សេងៗ គឺកកងដោយពួកស្រីអប្សរ ទាំង

ប្រទីបជ្វាលាដ៏ធំ ជាវិការៈនៃមាស មានពួកឈើផ្លែចេញជាសំពត់ព័ទ្ធជុំវិញ

ភ្លឺរុងរឿងក្នុងប្រាសាទ នោះជានិច្ចសម្បុររបស់ខ្ញុំប្រាកដដូច្នោះ សម្រេចដោយ

បុណ្យនោះ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺ ច្បាស់ សព្វទិស ។

**ចប់រឿង អម្ពវិមាន**

# ការជីកស្រះទឹក ឬអណ្តូងជាទាន

នៅក្នុងស្រុកមួយ ដែលមិនមានអណ្តូងទឹក ឬស្រះទឹកជាដើម មនុស្សសត្វទាំងឡាយមិនអាចរស់នៅ ក្នុងស្រុកនោះបានទេព្រោះការរស់នៅរបស់មនុស្សសត្វត្រូវអាស្រ័យទឹកយ៉ាងសំខាន់ ទើបអាចរស់នៅបាន។

មនុស្សឬសត្វទាំងឡាយតែងចង់ទៅរស់នៅ ទីកន្លែងណាដែលមានទឹកដូចជាទៅរស់នៅ ក្បែរទន្លេ បឹងបួ ស្រះជាដើមព្រោះជីវិតរស់នៅត្រូវការទឹកគ្រប់ពេលវេលា។

បុគ្គលណាបានជីកអណ្តូងឬស្រះជាទាន សម្រាប់មនុស្សសត្វទូទៅ

ឈ្មោះថាធ្វើឱ្យអ្នកដទៃ បាននូវសេចក្តីសុខព្រោះបានផឹកទឹក ឬបានងូត

ជំរះកាយជាដើម ។

ការជីកស្រះទឹកជាទាន គឺឈ្មោះថា បានឱ្យទឹកដល់មនុស្សសត្វ

ទាំងឡាយគ្រប់ពេលវេលា ។

អ្នកធ្វើស្រះទឹកជាទានជាដើមរមែងបាននូវសេចក្តីសុខក្នុងលោក

នោះនិងបរលោកខាងមុខ រហូតដល់និព្វាន ។

ហេតុដូច្នោះយើងទាំងអស់គ្នាត្រូវចេះជួយថែរក្សាទឹកសាធារណៈ

ដូចជាតាមស្រះ អណ្តូង ឬស្ទឹងជាដើមឱ្យមានអនាម័យល្អដើម្បីសុខភាព

ខ្លួនឯង និងសុខភាពមនុស្សសត្វទាំងឡាយ ។

# ការធ្វើផ្លូវផ្តល់ជាទាន

មនុស្សទាំងឡាយក្តី សត្វទាំងឡាយក្តី ដែលអាចធ្វើដំណើរទៅបានអាស្រ័យមានផ្លូវ បើមិនមានផ្លូវទេ មិនអាចធ្វើដំណើរដោយជើង ឬយានយន្តបានឡើយ ។ មធ្យោបាយរស់នៅរបស់មនុស្ស ចាំបាច់ត្រូវ-មានផ្លូវ ធ្វើដំណើរទៅមកទើបជាការងាយស្រួល ។

- ផ្លូវទៅផ្សារងាយស្រួលសម្រាប់អ្នកធ្វើដំណើរទៅផ្សារ
- ផ្លូវទៅជនបទងាយស្រួលសម្រាប់អ្នកធ្វើដំណើរទៅជនបទ
- ផ្លូវទៅវត្តងាយស្រួលសម្រាប់អ្នកធ្វើដំណើរទៅវត្ត

តើការធ្វើផ្លូវយ៉ាងដូចម្តេច ?

ការធ្វើផ្លូវគឺជាការធ្វើដីឱ្យរាបស្មើរល្អ បើមិនបានធ្វើដោយខ្លួនឯងទេ ក៏ប្រើកូនចៅ ញាតិមិត្ត ឬរួមចំណែកជាមួយអ្នកដទៃជួលជាប្រាក់ដើម្បីកសាងផ្លូវមួយខ្សែ វែងក៏ដោយ ខ្លីក៏ដោយ ឬបានធ្វើផ្លូវមុខផ្ទះរបស់ខ្លួនឱ្យបានស្អាតងាយស្រួលដល់អ្នកធ្វើដំណើរឆ្លងកាត់ទាំងឡាយ ។

អ្នកធ្វើផ្លូវថ្នល់ឬស្ពានរមែងបានអានិសង្សច្រើនគឺបានសេចក្តីសុខក្នុងលោកនេះនិងលោកខាងមុខ ។

សូមមេត្តាចូលរួមចំណែកកសាងផ្លូវថ្នល់ និងជួយថែរក្សាឱ្យបានគង់វង្សដើម្បីជាប្រយោជន៍ ដល់មនុស្សសត្វទូទៅ ។

## ឱ្យនូវទីសេនាសនៈ ឈ្មោះថាឱ្យនូវវត្ថុគ្រប់យ៉ាង

សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បឋមភាគលេខ ២៩ ក្នុងកិន្ទទសូត្រ

មានទេវតាមួយអង្គក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដោយពាក្យ

បាលីថា

**កឹទទោ ពលទោ ហោតិ**

**កឹទទោ ហោតិ វណ្ណទោ**

**កឹទទោ សុខទោ ហោតិ**

**កឹទទោ ហោតិ ចក្ខុទោ**

**យោ ច សព្វទទោ ហោតិ**

**តំ មេ អក្ខាហិ បុច្ឆិតោតិ ។**

ប្រែថា បុគ្គលឱ្យអ្វី ឈ្មោះថា ឱ្យនូវកម្លាំង?

បុគ្គលឱ្យអ្វី ឈ្មោះថា ឱ្យនូវពណ៌សម្បុរ?

បុគ្គលឱ្យអ្វី ឈ្មោះថា ឱ្យនូវសេចក្តីសុខ?

បុគ្គលឱ្យអ្វី ឈ្មោះថា ឱ្យនូវចក្ខុ គឺភ្នែក?

មួយទៀតបុគ្គលណា ឱ្យអ្វីឈ្មោះថា ឱ្យនូវវត្ថុគ្រប់យ៉ាង?

សូមព្រះអង្គសម្តែងប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គដែលជាអ្នកសួរ ។

ព្រះដ៏មានព្រះភាគបានឆ្លើយតបទៅទេវតានោះដោយគាថាដូច្នេះថា

**អន្នទោ ពលទោ ហោតិ**

**វត្ថទោ ហោតិ វណ្ណទោ**

**យានទោ សុខទោ ហោតិ**

**ទីបទោ ហោតិ ចក្ខុទោ**

**សោ ច សព្វទទោ ហោតិ**

**យោ ទទាតិ ឧបស្សយំ**

**អមតន្ទទោ ច សោ ហោតិ**

**យោ ធម្មមនុសាសតីតិ ។**

ប្រែថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលឱ្យបាយ ឈ្មោះថា ឱ្យកម្លាំង ឱ្យសំពត់ ឈ្មោះថា ឱ្យពណ៌ សម្បុរ ឱ្យយានជំនិះ ឈ្មោះថា ឱ្យសេចក្ដីសុខ ឱ្យប្រទីប ឈ្មោះថា ឱ្យចក្ខុ មួយទៀត បុគ្គលណា ឱ្យទីនៅអាស្រ័យ

បុគ្គលនោះ ឈ្មោះថា ឱ្យវត្ថុគ្រប់យ៉ាង បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះ ឈ្មោះថាឱ្យព្រះនិព្វាន ។

## សេនាសនទាន

គឺជាទានមួយដែលព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គទ្រង់ អនុញ្ញាតឱ្យសាវ័ករបស់ព្រះអង្គ មានភិក្ខុជាដើមទទួលប្រើប្រាស់ដើម្បីបាន សម្រេចប្រយោជន៍ទាំងអ្នកធ្វើ ទាំងអ្នកទទួល ដូចមានសេចក្តីដែលមាន សម្តែងក្នុងព្រះវិន័យបិដក ចុល្លវគ្គ ទុតិយភាគ សេនាសនក្ខន្ធកៈ ។

# រឿងមឃមាណព

ក្នុងអតីតកាល មាណពឈ្មោះ **មឃៈ** នៅក្នុងអចលគ្រាម ដែនមគធៈ

ទៅកាន់ទីជាទីធ្វើការងារនៃអ្នកស្រុក ឈូសនូវអាចម៍ដីដោយចុងជើងក្នុងទី

ដែលខ្លួនឈរហើយ បានធ្វើឱ្យជាទីមនោរម្យហើយឈរនៅ ។បុរសដទៃម្នាក់

ទៀតយកដៃច្រានគេនាំចេញចាកទីនោះហើយ បានឈរនៅក្នុងទីនោះឯង ។

មឃមាណពមិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឱ្យជាទីមនោរម្យ

ហើយឈរវិញបុរសដទៃក៏យកដៃច្រានមឃមាណពចេញអំពីទីនោះហើយ

បានឈរនៅក្នុងទីនោះឯងទៀត ។ មឃមាណពមិនក្រោធសូម្បីដល់បុគ្គល

នោះ បានធ្វើទីដទៃឱ្យជាទីមនោរម្យហើយ ក៏ឈរនៅក្នុងទីនោះទៀត បុរស

ទាំងឡាយដែលចេញទៅហើយៗអំពីផ្ទះ ក៏យកដៃច្រានមឃមាណពចេញអំពី

ទីដែលមឃមាណពជម្រះហើយៗដោយប្រការដូច្នេះ ។ មឃមាណពគិតថា

" ជនទាំងអស់គ្នា ជាអ្នកបានទទួលនូវសេចក្ដីសុខហើយ កម្មនេះរមែងជាកម្ម

ឱ្យនូវសេចក្ដីសុខដល់យើង" ។ ដូច្នេះហើយថ្ងៃស្អែកឡើងបានកាន់យកចបទៅ

ធ្វើនូវទីមានមណ្ឌលនៃលានឱ្យជារមណីយដ្ឋានហើយ ។ ជនទាំងពួងបានទៅ

ឈរសម្រាកក្នុងទីនោះឯង ។

សម័យថ្ងៃក្រោយមក លុះដល់រដូវរងា មឃមាណពបានបង្កាត់ភ្លើងឱ្យ

ដល់ជនទាំងនោះ ក្នុងរដូវក្ដៅបានឱ្យទឹក ។ ក្នុងលំដាប់នោះ មឃមាណពគិតថា

"ដែលឈ្មោះថា រមណីយដ្ឋាន រមែងជាទីស្រឡាញ់នៃជនទាំងពួង ដែលឈ្មោះ

ថា មិនជាទីស្រឡាញ់នៃជនទាំងពួងមិនមាន ចាប់ផ្ដើមអំពីនេះទៅយើងគួរ

ដើរធ្វើផ្លូវឱ្យរាបស្មើ" ដូច្នេះហើយ ក៏ចេញទៅអំពីផ្ទះពីព្រលឹមធ្វើផ្លូវឱ្យរាបស្មើ

កាត់ឫសឈើ មែកឈើ ដែលគួរកាត់ចេញ ។

## មយមាណពបានសម្លាញ់ ៣៣នាក់

ខាងក្រោយមក បុរសម្នាក់ទៀតឃើញមយមាណព ហើយពោលថា

" ម្នាលសម្លាញ់ អ្នកធ្វើអ្វី? "

**មឃៈ** :ម្នាលសម្លាញ់ ខ្ញុំធ្វើផ្លូវសម្រាប់ទៅកាន់ឋានសួគ៌របស់ខ្ញុំ ។

**បុរស** : បើដូច្នោះ សូម្បីខ្ញុំក៏នឹងជាសម្លាញ់របស់លោកដែរ ។

**មឃៈ**:ម្នាលសម្លាញ់អ្នកចូរជាសម្លាញ់របស់ខ្ញុំចុះធម្មតាឋានសួគ៌រមែង ជាទីស្រឡាញ់ជាទីពេញចិត្តនៃជនជាច្រើន ។ ចាប់តាំងអំពីកាលនោះមកក៏បាន បុរសនោះជាសម្លាញ់នឹងគ្នា ២នាក់ ។ សូម្បីបុរសដទៃទៀត ឃើញជនទាំងពីរ នាក់នោះហើយ សួរហើយដូចគ្នាដែរ លុះដឹងហើយក៏ជាសម្លាញ់នៃជនទាំង២-

នាក់នោះ សូម្បីជនដទៃៗទៀតក៏បានធ្វើហើយដោយប្រការយ៉ាងនោះ រួម

ទាំងអស់បាន ៣៣នាក់ដោយប្រការដូច្នេះ ។

## សម្លាញ់ទាំង៣៣នាក់ត្រូវបានចោទថាជាចោរ

ជនទាំងអស់នោះមានដៃកាន់វត្ថុមានចបជាដើមធ្វើផ្លូវឱ្យរាបស្មើទៅ

ដល់ទីប្រមាណ១យោជន៍និង២យោជន៍ ។

ចៅហ្វាយស្រុកឃើញបុរសទាំងនោះហើយគិតថា " មនុស្សទាំងនេះ

ប្រកបកិច្ចការងារក្នុងឋានៈដែលមិនគួរប្រកប ប្រសិនបើជនទាំងនេះ គប្បីនាំ

វត្ថុទាំងឡាយមានត្រី និងសាច់ជាដើមមកអំពីព្រៃ ឬធ្វើសុរាហើយផឹក ឬធ្វើ

កម្មដូច្នោះយ៉ាងដទៃ យើងគប្បីបានវត្ថុអ្វី១ខ្លះ" ។

គ្រានោះ ចៅហ្វាយស្រុកក៏បានបញ្ជាឱ្យគេហៅជនទាំងនោះមកសួរថា "ពួកឯងដើរធ្វើអ្វី? " **បុរសទាំងនោះ ៈ**បពិត្រនាយ ធ្វើផ្លូវសម្រាប់ដើរទៅកាន់ឋានសួគ៌ ។ **ចៅហ្វាយស្រុកៈ** ធម្មតាបុគ្គលដែលនៅគ្រប់គ្រងផ្ទះទាំងឡាយនឹងធ្វើយ៉ាងនោះមិនសមគួរ គួរនាំវត្ថុទាំងឡាយមានត្រី និងសាច់ជាដើមមកអំពីព្រៃ គួរធ្វើសុរាហើយផឹក និងគួរធ្វើការងារទាំងឡាយមានប្រការផ្សេងៗ ។ ជនទាំងនោះជំទាស់នឹងពាក្យរបស់ចៅហ្វាយស្រុកនោះ ។ សូម្បីត្រូវចៅហ្វាយស្រុកពោលរឿយៗក៏នៅតែជំទាស់រឿយៗដែរ ។ ចៅហ្វាយស្រុកក្រោធខឹងហើយ គិតថា "យើងនឹងញ៉ាំងពួកវាឱ្យវិនាស" ទើបទៅកាន់សំណាក់របស់ព្រះរាជា ក្រាបទូលថា "បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញចោរត្រាច់ទៅ

ដោយការចងគ្នាជាពួក" កាលព្រះរាជាត្រាស់ថា "អ្នកចូរទៅ ចូរចាប់ពួកវា

ហើយនាំមក " បានធ្វើតាមព្រះរាជបញ្ជា ហើយសម្ដែងជនទាំងនោះដល់

ព្រះរាជា ។

ព្រះរាជាមិនទាន់បានទ្រង់បានពិចារណា ទ្រង់ត្រាស់បង្គាប់ថា"ពួកអ្នក

ចូរញ៉ាំងដំរីឱ្យជាន់ពួកវា" ។

# ដំរីមិនជាន់ព្រោះអានុភាពនៃមេត្តា

មយមាណពបានឱ្យឱវាទដល់ជនដ៏សេសទាំងឡាយថា "ម្នាលសម្លាញ់ទាំងឡាយ វៀរមេត្តាចេញហើយទីពឹងយ៉ាងដទៃរបស់ពួកយើងមិនមាន អ្នកទាំងឡាយចូរកុំធ្វើនូវសេចក្តីក្រោធក្នុងបុគ្គលណាៗឡើយ ចូរជាអ្នកមានចិត្តស្មើដោយមេត្តាក្នុងព្រះរាជាផង ក្នុងចៅហ្វាយស្រុកផង ក្នុងដំរីដែលនឹងជាន់ផង និងក្នុងខ្លួនឯងផង" ជនទាំងនោះក៏បានធ្វើហើយដោយប្រការយ៉ាងនោះ ។

គ្រានោះ ដំរីក៏មិនហ៊ានចូលទៅជិត ព្រោះអានុភាពនៃមេត្តារបស់ជនទាំងនោះ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់នូវសេចក្តីនោះហើយត្រាស់ថា "ដំរីវាឃើញមនុស្សច្រើន ទើបវាមិនហ៊ានចូលទៅដើម្បីជាន់ អ្នកទាំងឡាយចូរទៅ

ចូរយកកន្ទេលផែងគ្របពួកវាហើយ ញ៉ាំងដំរីឱ្យជាន់ចុះ” ។

ដំរីដែលរាជបុរសទាំងឡាយយកកន្ទេលផែងគ្របជនទាំងនោះ ហើយ

បញ្ជូនទៅដើម្បីឱ្យជាន់ក៏ថយត្រឡប់ហើយអំពីចម្ងាយ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវព្រឹត្តិការណ៍នោះហើយទ្រង់ព្រះចិន្ដាថា”

ក្នុងរឿងនេះត្រូវមានហេតុភេទអ្វីជាពិតប្រាកដ” ហើយបញ្ជាឱ្យរាជបុរសហៅ

ជនទាំងនោះមកគាល់ ត្រាស់សួរថា “ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយអា

ស្រ័យយើង មិនបាននូវអ្វីឬ?”

**ពួកមឃះ :** បពិត្រព្រះសម្មតិទេព ហេតុហ្នឹងវាយ៉ាងម៉េច ?

**ព្រះរាជា** :បានឮថា ពួកឯងជាចោរត្រាច់ទៅក្នុងព្រៃ ដោយការចងគ្នា

ជាពួក ។

**ពួកមយៈ** : បពិត្រព្រះសម្មតិទេព នរណាទូលព្រះអង្គយ៉ាងនោះ?

**ព្រះរាជា** : ម្នាលអ្នកទាំងឡាយ ចៅហ្វាយស្រុកបានប្រាប់យើង ។

**ពួកមយៈ** បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំទាំងឡាយមិនមែនជាចោរទេប៉ុន្តែថាទូលព្រះបង្គំទាំងឡាយជម្រះផ្លូវសម្រាប់ទៅកាន់ឋានសួគ៌របស់ខ្លួនៗ ទើបធ្វើនូវកម្មនេះនិងកម្មនេះ ចៅហ្វាយស្រុកណែនាំពួកទូលព្រះបង្គំឱ្យធ្វើនូវអំពើអកុសលប្រាថ្នានឹងឱ្យទូលព្រះបង្គំទាំងឡាយដែលមិនធ្វើតាមពាក្យរបស់ខ្លួនវិនាស ក្រោធខឹងហើយ ទើបក្រាបទូលយ៉ាងនោះ ។

# ជនទាំង៣៣នាក់បានទទួលព្រះរាជទាន

គ្រានោះ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវវាចារបស់ជនទាំងនោះជាអ្នកដល់ហើយដោយសោមនស្ស ត្រាស់ថា" ម្នាលអ្នកទាំងឡាយ សត្វតិរច្ឆាននេះអាចដឹងនូវគុណរបស់អ្នកទាំងឡាយ ប៉ុន្តែយើងជាមនុស្សឱ្យស្រឡាំងក៏មិនអាចដឹងគុណនៃអ្នកទាំងឡាយ សូមអ្នកទាំងឡាយអត់ទោសឱ្យយើងផងចុះ" លុះត្រាស់យ៉ាងនោះហើយបានព្រះរាជទានចៅហ្វាយស្រុកព្រមទាំងបុត្រនិងភរិយាឱ្យជាទាសៈ ដំរីនោះឱ្យជា ពាហនៈសម្រាប់ជិះ ហើយព្រះរាជទានស្រុកនោះឱ្យជាគ្រឿងប្រើប្រាស់តាមសប្បាយដល់ជនទាំងនោះ ។

# មឃមាណព និងសម្លាញ់របស់ខ្លួនសាងសាលា

មឃមាណព និង សម្លាញ់របស់ខ្លួននិយាយគ្នាថា "ពួកយើងឃើញអានិសង្សនៃបុណ្យក្នុងបច្ចុប្បន្ននេះឯង" ម្នាក់ៗមានចិត្តជ្រះថ្លាយ៉ាងក្រៃលែង ផ្លាស់វេនគ្នាឡើងកាន់ដីរនោះធ្វើដំណើរទៅបណ្តើរប្រឹក្សាគ្នាបណ្តើរថា" ឥឡូវនេះ ពួកយើងគួរធ្វើបុណ្យឱ្យវិសេសក្រៃលែងឡើង" ម្នាក់ៗ ដេញដោលសួរគ្នាថា "ពួកយើងនឹងធ្វើយ៉ាងណា ?" ក៏សម្រេចគ្នាថា "នឹងសាងសាលាជាទីសម្រាកនៃមហាជនឱ្យជារបស់មាំមួនក្នុងផ្លូវធំបែកជា៤" ។ មឃមាណព និងសម្លាញ់របស់ខ្លួនក៏បានស្វែងរកជាងឈើមកហើយផ្តើមកសាងសាលាក៏ប៉ុន្តែថាព្រោះការដែលខ្លួនមិនពេញចិត្តក្នុងមាតុគ្រាម ទើបមិនបានឱ្យចំណែកបុណ្យ

ក្នុងសាលានោះដល់មាតុគ្រាម ទាំងឡាយ ។

## មាណពមានភរិយា ៤នាក់

ក៏ក្នុងផ្ទះរបស់មឃមាណពមាន ស្ត្រី៤នាក់ គឺ **នាងសុនន្ទា សុចិត្រា សុធម្មា សុជាតា** ។ បណ្តាស្ត្រីទាំង៤នាក់ នោះ នាងសុធម្មា ស៊ុមគ្រលុំជាមួយនឹងជាងឈើហើយពោលថា"បពិត្រអ្នកបង សូមបងធ្វើខ្ញុំឱ្យជាធំក្នុងសាលានេះចុះ"ដូច្នេះហើយបានឱ្យនូវសំណូក(ជាងឈើ)ជាងឈើនោះបានទទួលយល់ព្រមថា "បាន" ហើយហាលឈើសម្រាប់ធ្វើហោជាងឱ្យស្ងួតមុនវត្ថុដទៃហើយឈូសឆ្លាក់ធ្វើហោជាងឱ្យសម្រេចហើយ ឆ្លាក់អក្សរទាំងឡាយថា "សាលានេះឈ្មោះសុធម្មា" ដូច្នេះហើយយកសំពត់រុំទុក ។

## នាងសុធម្មាបានរួមកុសលសាងសាលាជាមួយមឃមាណព

លុះជាងឈើសាងសាលាស្រេចហើយក្នុងថ្ងៃលើកហោជាងក៏ពោល

ទៅកាន់ជនទាំង ៣៣នាក់ នោះថា "ស្លាប់ហើយនាយ ខ្ញុំបាទនឹកមិនឃើញនូវ

កិច្ចដែលគួរធ្វើមួយ" ។

**ពួកមឃៈ** : ម្នាលអ្នកដ៏ចម្រើន អ្នកនឹកមិនឃើញដល់កិច្ចអ្វី ?

**ជាង** : បពិត្រនាយ ហោជាង ។

**ពួកមឃៈ** :ម្នាលអ្នកដ៏ចម្រើន ហេតុនោះចូរលើកទុកសិនចុះពួកយើង

នឹងនាំហោជាងមកដោយខ្លួនឯង ។

**ជាង :** ខ្ញុំបាទអាចធ្វើដោយឈើដោយបុគ្គល ទើបតែកាត់ហើយឈ្ងួស

ហើយ ឆ្លាក់ហើយតម្កល់ទុកក្នុងកាលមុននោះឯងទើបសមគួរ ។

**ពួកមយៈ** : ឥឡូវនេះ ពួកយើងគួរធ្វើដូចម្តេច ?

**ជាងៈ** : ប្រសិនបើក្នុងផ្ទះរបស់អ្នកណា១ មានហោជាងសម្រាប់លក់ដែលគេធ្វើស្រាប់ហើយតម្កល់ទុកសោត គួរស្វែងរកហោជាងនោះមក ។

ពួកមយមាណពទាំង ៣៣នាក់ ស្វែងរកនូវហោជាងក៏ឃើញមាននៅក្នុងផ្ទះរបស់នាងសុធម្មា ហើយឱ្យទ្រព្យ ១000 ដើម្បីឱ្យនាងសុធម្មាប្រគល់នូវហោជាងដល់ខ្លួន ក៏មិនបានហោជាងនោះដោយទ្រព្យដែលជាតម្លៃ កាលនាងសុធម្មានិយាយថា" ប្រសិនបើពួកលោកធ្វើខ្ញុំឱ្យជាស្ត្រីមានចំណែកបុណ្យក្នុងសាលានោះសោត ខ្ញុំនឹងឱ្យ" ។ ឆ្លើយថា"ពួកខ្ញុំមិនឱ្យនូវចំណែកបុណ្យដល់ពួកមាតុគ្រាម" ។

គ្រានោះ ជាងឈើក៏បានពោលទៅកាន់ជនទាំងនោះថា "បពិត្រនាយ

លោកនិយាយអ្វី? វៀរព្រហ្មលោកចេញ ស្ថានទីដទៃដែលឈ្មោះថាជាទីវៀរ មាតុគ្រាមចេញ រមែងមិនមាន ពួកលោកចូរទទួលយកហោជាងចុះ កាលបើ ដូច្នោះ ការងាររបស់ពួកយើងក៏នឹងដល់នូវការសម្រេច" ។ ពួកជនទាំង ៣៣ នាក់នោះក៏ទទួលយល់ព្រមថា

"ប្រពៃហើយ" ហើយទទួលយកហោជាងនោះទៅ ញុំាងសាលាឱ្យ សម្រេចហើយបែងជា ៣ចំណែក គឺមួយចំណែកសម្រាប់ជាទីនៅនៃពួកឥស្សរ ជន មួយចំណែកសម្រាប់ទុគ្គិតជន មួយចំណែកទៀត សម្រាប់មនុស្សឈឺទាំង ឡាយ ។

# រឿងដីរឯភារិណ

ជនទាំង ៣៣នាក់ឱ្យគេក្រាលបន្ទះក្ដារ ៣៣បន្ទះ ហើយឱ្យសញ្ញាដល់ដីរថា "កាលភ្ញៀវមកអង្គុយលើបន្ទះក្ដារដែលបុគ្គលណាក្រាលទុកឯងចូរនាំភ្ញៀវនោះទៅកាន់ផ្ទះនៃបុគ្គលអ្នកជាម្ចាស់បន្ទះក្ដារនោះចុះ ការច្របាច់ជើង ការច្របាច់ខ្នង របស់ដែលគួរទំពាស៊ីនិងរបស់ដែលគប្បីបរិភោគ ទីដេកទាំងឡាយគ្រប់យ៉ាង និងជាភារៈនៃបុគ្គលដែលជាម្ចាស់នៃបន្ទះក្ដារនោះ" ។ ដីរទទួលអ្នកដែលមកហើយៗនាំទៅកាន់ផ្ទះបុគ្គលអ្នកជាម្ចាស់នៃបន្ទះក្ដារនោះឯង ។ ក្នុងថ្ងៃនោះ ម្ចាស់បន្ទះក្ដារនោះ រមែងធ្វើកិច្ចដែលគួរធ្វើដល់អ្នកដែលដីរនាំទៅនោះ ។ មឃមាណពដាំនូវដើមរលួសផ្គុងមួយដើម ក្នុងទីមិនឆ្ងាយ

អំពីសាលា ហើយក្រាលនូវថ្ពាំងថ្មក្បែរគល់ នៃដើមរលួសផ្អុងនោះ។

ពួកជនដែលចូលទៅកាន់សាលាហើយ ក្រឡេកមើលនូវហោជាងអាន អក្សរទាំងឡាយហើយ រមែងនិយាយ គ្នាថា"**សាលាឈ្មោះសុធម្មា**"ឈ្មោះ របស់ជនទាំង ៣៣នាក់មិនប្រាកដ។ នាងសុនន្ទាគិតថាជនទាំងនេះ កាលធ្វើ សាលា ធ្វើពួកយើងមិនឱ្យជាអ្នកមានចំណែកនៃបុណ្យផង ចំណែកឯនាង-សុធម្មា ក៏ធ្វើហោជាងចូលរួមចំណែកទាល់តែបាន ព្រោះភាវៈនៃខ្លួនជាស្ត្រី ឈ្លាសវៃ យើងក៏គួរនឹងធ្វើនូវកុសលកម្មអ្វីមួយ យើងហ្នឹងធ្វើនូវអ្វីហ្ន៎ ? គ្រា នោះឯង នាងក៏មានការគិតដូច្នេះថា"ពួកជនដែលមកកាន់សាលាគួរនឹងបាន ទឹកផឹកនិងទឹកងូត យើងនឹងឱ្យគេជីកស្រះបោក្ខរណី" នាងសុនន្ទាក៏បានញ៉ាំង

បុគ្គលឱ្យជីកស្រះបោក្ខរណីមួយ ។

នាងសុចិត្រាគិតថា "នាងសុធម្មា បានឱ្យហោជាង នាងសុនន្ទាបាន សាងស្រះបោក្ខរណី យើងក៏គួរសាងកុសលអ្វី មួយដែរ យើងនឹងធ្វើអ្វីហ្ន៎ ? "គ្រានោះនាងមានការគិតដូច្នេះថា "ក្នុងកាលដែលពួកជនមកកាន់សាលា ផឹកទឹក ងូតទឹកហើយទៅ គួរប្រដាប់ នូវកម្រងផ្កាហើយសឹមទៅ រមែងសមគួរ យើងនឹងសាងសួនច្បារ" នាងបានឱ្យគេសាងសួនច្បារមួយដ៏ជាទីមនោរម្យ ។ អ្នកដែលនឹងពោលថា "ដោយច្រើនក្នុងសួននោះមិនមានដើមឈើដែលចេញផ្កា ចេញផ្លែឯណោះ " ដូច្នេះរមែងមិនមាន ។

ចំណែកឯនាងសុជាតាគិតថា "យើងជាធីតានៃឪពុកធំរបស់ មឃមា-

ណពផង ទាំងជាបាទបរិចារិកា (ភរិយា) ផង។ កម្មដែលមយមាណពនោះ

ធ្វើហើយ ក៏ជារបស់យើងដែរ កម្មដែលយើងធ្វើហើយក៏ជារបស់មយមាណព

នោះដែរ " ដូច្នេះហើយមិនធ្វើនូវកុសលអ្វីៗ ទាំងអស់ ខំប្រឹងតែសំអិតសំអាង

រាងកាយរបស់ខ្លួនប៉ុណ្ណោះ ញ៉ាំងកាលឱ្យកន្លងហួសទៅ។

# មយមាណពបំពេញវត្តបទ ៧ប្រការ

ចំណែកមយមាណព បំពេញវត្តបទ៧ប្រការនេះ គឺបម្រើមាតា១ ប្រព្រឹត្តឱនលំទោនគោរពរៀមច្បងក្នុងត្រកូល១ ពោលពាក្យល្អិតទន់១ មិនពោលនូវវាចាទ្រគោះ១ មិនពោលពាក្យញុះញង់១ កំចាត់បង់នូវសេចក្តីកំណាញ់១ មិនក្រោធ១ដល់នូវភាពជាអ្នកគួរសរសើរយ៉ាងនេះថា ពួកទេវតានៅឋានតាវត្តឹង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា គោរពកោតក្រែងបុគ្គលជារៀមច្បងក្នុងត្រកូលមានវាចាល្អិតទន់ និយាយសម្តីផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបតែនៅក្នុងការកំចាត់បង់នូវសេចក្តីកំណាញ់មានវាចាទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯងថា ជាសប្បុរស ។ ក្នុងវេលា

អស់ជីវិតបានកើតជាសក្កទេវរាជក្នុងភពតាវត្តឹង្ស ។សម្លាញ់របស់មឃមាណព

ទាំងនោះ ក៏កើតក្នុងទីនោះដែរ ។ ជាងឈើកើតជាវិស្សុកម្មទេវបុត្រ ។

# ទេវតា និង អសុរធ្វើសង្គ្រាមជាមួយគ្នា

ក្នុងកាលនោះ ពួកអសុរនៅក្នុងភពតាវត្តិង្សទេវលោក អសុរទាំងនោះគិតថា "ទេវបុត្រថ្មីៗ កើតហើយ ទើបចាត់ចែងនូវទឹកបាន (ទឹកដែលបុគ្គលគប្បីផឹក) ដ៏ជាទិព្វ។ សក្កទេវរាជបានឱ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គ ដើម្បីប្រយោជន៍មិនឱ្យនរណាៗផឹក។ ពួកអសុរផឹកនូវទឹកបានដ៏ជាទិព្វ ស្រវឹងទាំងអស់គ្នា។ សក្កទេវរាជទ្រង់គិតថា "យើងនឹងត្រូវធ្វើដូចម្តេចទៅ ដោយភាពជារាជា ទូទៅដល់អសុរទាំងនេះ?" ទ្រង់ឱ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គហើយបញ្ជាឱ្យជួយគ្នាចាប់អសុរទាំងនោះ ព្វដ៏ជើងទាំងពីរ បោះទៅក្នុងមហាសមុទ្រ។ អសុរទាំងនោះមានក្បាលសំយុងចុះធ្លាក់ទៅក្នុងមហាសមុទ្រ ខណៈ

នោះ អសុរវិមានបានកើតនាផ្ទៃខាងក្រោមនៃភ្នំសិនេរុ ដោយអានុភាពបុណ្យ

របស់ពួកអសុរ ។ដើមឈើឈ្មោះចិត្តបាដិលិ ( ដើមច្រនៀង) ក៏កើតហើយដែរ ។

កាលសង្គ្រាមរវាងទេវតានឹងអសុរ( ប្រយុទ្ធគ្នាហើយ) លុះកាលពួកអសុរបរា-

ជ័យហើយ ទេពនគរក្នុងជាន់តាវត្តឹង្សប្រមាណ ១០០០០យោជន៍ កើតឡើង

ហើយ ។ ហើយក្នុងចន្លោះទ្វារដែលតាំងនៅទិសខាងកើតនិងទិសខាងលិចនៃ

ព្រះនគរនោះក៏មានផ្ទៃដីប្រមាណ១០០០០យោជន៍ដូចគ្នាដែរ ចន្លោះទ្វារទិស

ខាងត្បូង និងទិសខាងជើង ក៏មានផ្ទៃដីប្រមាណប៉ុណ្ណោះដែរ ។ម្យ៉ាងទៀតព្រះ

នគរនោះប្រកបដោយទ្វារ ១០០០ប្រដាប់ដោយឧទ្យាន និងស្រះបោក្ខរណី ។

ប្រាសាទឈ្មោះ **វេជយន្ត** កម្ពស់ ៧០០យោជន៍ សម្រេចហើយដោយកែវ

៧ប្រការ ប្រដាប់ដោយទង់ទាំងឡាយ កម្ពស់៣០០យោជន៍ ផុសឡើងហើយ

ដោយផលនៃសាលាត្រង់កណ្ដាលព្រះនគរនោះដងទង់ធ្វើអំពីមាសចំណែកទង់

ធ្វើអំពីកែវមណី ដងធ្វើអំពីកែវមណី ទង់ធ្វើអំពីមាស ដងធ្វើអំពីកែវប្រពាឡ

ទង់ក៏ធ្វើអំពីកែវមុក្តា ដងធ្វើអំពីកែវមុក្តាទង់ធ្វើអំពីកែវប្រពាឡទង់ដែលតាំង

នៅត្រង់កណ្ដាលមានកម្ពស់៣០០យោជន៍ ប្រាសាទមានកម្ពស់១០០០យោជន៍

សុទ្ធតែសម្រេចអំពីកែវ៧ប្រការ កើតហើយដោយផលនៃសាលាដោយប្រការ

ដូច្នេះ ។ ដើមបារិច្ឆត្តកព្រឹក្ស មានមណ្ឌល ( ផ្សាយទៅ) ៣០០យោជន៍ដោយ

ជុំវិញ កើតឡើងហើយដោយផល នៃការដាំដើមរលួសផ្ទុង ។**បណ្ឌុកម្ពលសិលា**

មានពណ៌លឿងស្រស់ ដូចជាពណ៌នៃផ្ការាជព្រឹក្ស និងពណ៌ក្រហមព្រឿង និង

ដូចពណិនៃទឹកល័ក្ត ដោយមានបណ្តោយ៦០យោជន៍ ទទឹង៥០យោជន៍ កម្ពស់ ១៥យោជន៍ បណ្ឌុកម្ពលសិលាសនៈនេះ ក្នុងកាលដែលសក្កទេវរាជគង់ ហើយ កាយពាក់កណ្តាលក៏លិចចូលទៅ ក្នុងកាលដែលសក្កទេវរាជក្រោក ឡើង រមែងប៉ោងឡើងពេញបរិបូណ៌ដូចដើមវិញ កើតឡើងហើយទៀបគល់ នៃដើមបារិច្ឆត្តកព្រឹក្ស ដោយផលនៃការក្រាលផ្ទាំងសិលា។

# ទេវបុត្រ ៣៣អង្គអង្គុយលើពោងដំរីឯរាវ័ណ

ចំណែកដំរីកើតជាទេវបុត្រឈ្មោះឯរាវ័ណ ។ពិតណាស់សត្វតិរច្ឆានទាំងឡាយ រមែងមិនមានក្នុងទេវលោក ព្រោះហេតុនោះក្នុងកាលដែលសក្កទេវ-រាជស្តេចចេញទៅ ដើម្បីក្រសាលនៅក្នុងឧទ្យាន ទេវបុត្រនោះក៏និម្មិតខ្លួនជាដំរីឈ្មោះឯរាវ័ណ កម្ពស់១៥០យោជន៍ ។ដំរីទេវបុត្រនោះ និម្មិតពោង៣៣ ដើម្បីប្រយោជន៍ ដល់ជនទាំង៣៣នាក់ ក្នុងបណ្តាពោងទាំងនោះ ពោងនី-មួយៗ ដោយចំណែកមូល៣គាវុតដោយចំណែកខាងបណ្តោយកន្លះយោជន៍ ។ទេវបុត្រនោះនិម្មិតពោងឈ្មោះសុទស្សនៈ ប្រមាណ៣០យោជន៍ ត្រង់កណ្តាលពោងទាំងអស់ ដើម្បីប្រយោជន៍ដល់សក្កទេវរាជ ខាងលើនៃពោងនោះមាន

មណ្ឌបកែវប្រមាណ១២យោជន៍ ទង់កែវ៧ប្រការកម្ពស់ ១យោជន៍តាំងឡើង

ក្នុងចន្លោះៗក្នុងមណ្ឌបកែវនោះ ។ សម្លេងនៃចង្កោមកណ្តឹង ដែលខ្យល់យ៉ាង

ស្រទន់បក់ត្រូវហើយ លាយនឹងសម្លេងនៃតន្ត្រីដែលប្រកបដោយអង្គ៥ រមែង

លាន់ចេញយ៉ាងពិរោះដូចជាសម្លេង**សង្គីត**ៈដ៏ជាទិព្វ ។   ចង្កោមនៃកណ្តឹងនោះ

ព្យួរនៅក្នុងទីបំផុតជុំវិញ ។បល្ល័ង្កកែវមណីប្រមាណ១យោជន៍ជាព្រះទីនាំង ជា

របស់ដែលបុញ្ញកម្មតាក់តែងល្អហើយ ដើម្បីសក្កទេវរាជត្រង់កណ្តាលមណ្ឌប

សក្កទេវរាជរមែងគង់លើបល្ល័ង្កនោះជានិច្ច ។ ទេវបុត្រ  ៣៣អង្គ    អង្គុយលើ

រតនបល្ល័ង្ក ក្នុងពោងរបស់ខ្លួន១ ។  បណ្តាពោងទាំង៣៣នោះក្នុងពោងនីមួយ១

ដំរីទេវបុត្រនោះនិម្មិតភ្លុកប្រាំពីរ១ ក្នុងបណ្តាភ្លុកទាំងនោះ ភ្លុកនីមួយ១ប្រវែង

ប្រមាណ៥០យោជន៍ ក្នុងភ្លុកនីមួយៗមានស្រះបោក្ខរណីប្រាំពីរៗ ក្នុងបណ្តា

ស្រះបោក្ខរណីទាំងនោះ ស្រះបោក្ខរណីនីមួយៗមានគុម្ពឈូកប្រាំពីរៗ ក្នុង

បណ្តាគុម្ពឈូកទាំង៧នោះក្នុងមួយគុម្ពៗមានផ្កា៧ៗ ក្នុងផ្កានីមួយៗមាន

ត្របក៧ៗ ក្នុងត្របកនីមួយៗ មានទេពធីតាឈររាំ៧អង្គ របាំនិងមហោស្រព

ទាំងឡាយ រមែងមានលើភ្លុកដំរីទាំង ឡាយក្នុងទីប្រមាណ ៥០យោជន៍ដោយ

ជុំវិញយ៉ាងនេះឯង ។ សក្កទេវរាជសោយយសដ៏ធំស្តេចត្រេចទៅដោយប្រការ

ដូច្នេះ ។

# ភរិយារបស់មឃមាណពពនាក់ក៏កើតក្នុងភពតាវតឹង្ស

សូម្បីនាងសុធម្មាធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងភពតាវត្តឹង្ស នោះដែរ ។ ទេវសភាឈ្មោះសុធម្មាមានប្រមាណ៥០០យោជន៍ បានកើតឡើង ហើយដើម្បីនាងសុធម្មានោះ ។ បានឮថា ដែលឈ្មោះថាទីដទៃ ដែលគួរជាទីរីករាយជាងទេវសភានោះ រមែងមិនមាន ។ ក្នុងថ្ងៃអដ្ឋមី( តិថីទី៨) នៃខែ រមែងមានការស្តាប់នូវព្រះធម៌ក្នុងទេវសភានោះឯង ។ រហូតដល់សព្វថ្ងៃនេះ ជនទាំងឡាយ ឃើញនូវទីណាមួយដែលគួរជាទីត្រេកអរ រមែងពោលថា "ហាក់ដូចជាទេវសភាឈ្មោះសុធម្មា" ។ សូម្បីនាងសុនន្ទា ធ្វើកាលកិរិយា- ហើយ ក៏បានទៅកើតក្នុងភពតាវត្តឹង្សនោះដែរ ។ ឧទ្យានឈ្មោះចិត្តលតាវ័ន

មានប្រមាណ ៥០០យោជន៏ដែលពួកទេវតានាំទេវបុត្រអ្នកមានបុញ្ញនិម្មិតកើត

ឡើងហើយឱ្យវង្វេងវង្វាន់ត្រាច់ទៅ កើតឡើងហើយដល់ នាងសុចិត្រានោះ ។

## សក្កទេវរាជឱ្យឱវាទដល់នាងសុជាតាដែលជាកុកញី

ចំណែកឯនាងសុជាតា ធ្វើកាលកិរិយាហើយ កើតជាកុកញីនៅនា

ជ្រោះភ្នំមួយ ។ សក្កទេវរាជ ទ្រង់រមិលមើលនាងបរិចារិការបស់ព្រះអង្គ ទ្រង់

ជ្រាបថា"នាងសុធម្មាកើតហើយក្នុងទីនេះដែរ ។ នាងសុនន្ទា និងនាងសុចិត្រាក៏

យ៉ាងនោះដែរ" ។ទ្រង់គិតទៅទៀតថា"នាងសុជាតាកើតទីណាហ្ន៎?"ឃើញនាង

កើតនៅនាជ្រោះភ្នំនោះហើយទ្រង់គិតថា "នាងសុជាតានេះជាស្រីពាលល្ងង់

ខ្លៅមិនធ្វើបុណ្យអ្វីៗ ឥឡូវនេះកើតហើយក្នុងកំណើតសត្វតិរច្ឆាន សូម្បីឥឡូវ

នេះ គួរយើងនឹងញ៉ាំងនាងសុជាតានោះឱ្យធ្វើនូវបុណ្យហើយនាំមកអំពីជ្រោះ

ភ្នំនោះ " ដូច្នេះហើយក៏ទ្រង់និម្មិតអត្តភាពស្តេចទៅកាន់សំណាក់របស់នាង

ដោយភេទដែលអ្នកដទៃមិនស្គាល់ ត្រាស់សួរថា"នាងដើរធ្វើអ្វីនៅនាជ្រោះ

ភ្នំនេះ?"**កុកញី** បពិត្រនាយ លោកជានរណា ? **សក្កទេវរាជ** យើងគឺជា

មឃមាណព ស្វាមីរបស់នាង ។ **កុកញី** បពិត្រនាយ លោកកើតនៅទីណា ?

**សក្កទេវរាជ** យើងកើតនៅក្នុងតាវត្តឹង្សទេវលោក ។ នាងដឹងថាស្ត្រីដែលជា

សម្លាញ់របស់នាងកើតទីណាហើយឬ? **កុកញី** បពិត្រនាយ ខ្ញុំមិនដឹងទេ ។

សក្កទេវរាជ ស្ត្រីទាំងនោះក៏កើតក្នុងសំណាក់របស់យើងដែរនាងប្រាថ្នាទៅសួរ

សុខទុក្ខស្ត្រីដែលជាសម្លាញ់របស់នាងដែរទេ ? **កុកញី** បពិត្រនាយ ខ្ញុំនឹងទៅ

កាន់ទីនោះបានដោយប្រការដូចម្ដេច ?**សក្កទេវរាជ** ត្រាស់ថា"យើងនឹងនាំនាង

ទៅកាន់ទីនោះ" ដូច្នេះហើយនាំនាងទៅកាន់ទេវលោក លែងទុកទៀបឆ្នេរ

ស្រះ បោក្ខរណីឈ្មោះនន្ទា ត្រាស់ប្រាប់ព្រះមហេសីទាំង ៣ក្រៅនេះថា "ពួក

នាងប្រាថ្នានឹងឃើញនាងសុជាតាដែលជាសម្លាញ់ របស់ពួកនាងដែរទេ?"

**មហេសី** បពិត្រព្រះឱបបត្តិទេព នាងសុជាតានៅទីណា ? **សក្កទេវរាជ** នាង

ឈរនៅទៀបឆ្នេរស្រះបោក្ខរណីឈ្មោះនន្ទា។ ព្រះមហេសីទាំង៣នោះ ស្ដេច-

ទៅកាន់ទីនោះ ធ្វើការចំអកថា"ឱ!រូបរបស់ព្រះនាងម្ចាស់ឱ!ផលនៃការស្អិត

ស្អាងខ្លួន ឥឡូវនេះ អ្នកទាំងឡាយចូរមើលនូវចំពុះ ចូរមើលនូវស្មងទាំងឡាយ

ចូរមើលនូវជើងទាំងឡាយ អត្តភាពរបស់ព្រះនាង ម្ចាស់ល្អណាស់ហ្ន៎ ដូច្នេះ

ហើយក៏ចៀសចេញទៅ ។ សក្កទេវរាជស្តេចទៅកាន់សំណាក់របស់នាងទៀត

ត្រាស់សួរថា "នាងបានជួបស្ត្រីដែលជាសម្លាញ់របស់នាងហើយឬ?" កាលនាង

ទូលថា" ព្រះមហេសីទាំង៣នោះ ខ្ញុំបានជួបហើយ( គេនាំគ្នា) ពោលចំអកដាក់

ខ្ញុំហើយ ក៏ចៀសចេញទៅ សូមព្រះអង្គមេត្តានាំខ្ញុំទៅកាន់ជ្រោះភ្នំនោះវិញ

ចុះ"ដូច្នេះហើយក៏ទ្រង់នាំមេកុកនោះទៅកាន់ជ្រោះភ្នំដូចដើមវិញលែងទុកក្នុង

ទីនោះហើយត្រាស់សួរថា "នាងឃើញសម្បត្តិរបស់ស្ត្រីទាំង៣នោះហើយឬ?"

**កុកញី** បពិត្រព្រះឱបបត្តិទេព ខ្ញុំបានឃើញហើយ ។ **សក្កទេវរាជ** សូម្បីនាងក៏

គួរធ្វើនូវឧបាយដែលជាហេតុនាំឱ្យកើតក្នុងទីនោះដែរ ។ **កុកញី** បពិត្រព្រះឱប

បត្តិទេព នឹងធ្វើនូវអ្វី ? **សក្កទេវរាជ** នាងនឹងរក្សានូវឱវាទរបស់យើងបានទេ?

**កុកញី** បពិត្រព្រះឱបបត្តិទេព ខ្ញុំរក្សាបាន។ គ្រានោះ សក្កទេវរាជក៏ប្រទាន

សីល៥ដល់មេកុក ហើយត្រាស់ថា "នាងចូរជាអ្នកមិនប្រមាទរក្សាចុះ" ដូច្នេះ

ហើយក៏ស្ដេចចៀសចេញទៅ។ ចាប់ដើមអំពីកាលនោះមក មេកុកក៏ដើរស្វែង

រកនូវត្រីដែលស្លាប់ឯងប៉ុណ្ណោះ។ ដោយកាលកន្លងទៅ២-៣ថ្ងៃ សក្កទេវរាជ

ទៅដើម្បីប្រាថ្នានឹងល្បងមើលនូវមេកុកនោះទើបទ្រង់និម្មិតខ្លួនដូចជាត្រីស្លាប់

ដេកផ្ងារពោះនៅឆ្នេរខ្សាច់។ កុកញីនោះឃើញត្រីនោះហើយ បានចឹកយក

ដោយសេចក្ដីសម្គាល់ថា "ត្រីស្លាប់ហើយ" ក្នុងកាលនឹងលេបត្រីនោះក៏ញុំាង

កន្ទុយឱ្យកម្រើក។ កុកញីនោះដឹងថា "ត្រីនៅរស់" ទើបលែងទៅក្នុងទឹក។

សក្កទេវរាជទ្រង់ញុំាងកាលបន្តិចឱ្យកន្លងទៅហើយ ក៏ទ្រង់ធ្វើដូចជាដេកផ្ងារ

ពោះនៅអំពីខាងមុខមេកុកទៀត មេកុកក៏ចឹកយកទៀត ដោយសម្គាល់ថា "ត្រីស្លាប់" ក្នុងកាលនឹងលេបឃើញចុងកន្ទុយនៅកម្រើកក៏លែងទៅដោយសម្គាល់ថា"ត្រីនៅរស់" សក្កទេវរាជទ្រង់ល្បងមើលអស់វារៈ៣ដង យ៉ាងនេះហើយត្រាស់ថា"នាងរក្សាសីលបានល្អ" ញ៉ាំងមេកុកឱ្យដឹងច្បាស់នូវព្រះអង្គហើយត្រាស់ថា"យើងមកដើម្បីប្រាថ្នានឹងល្បងមើលនាង នាងរក្សាសីលបាន-ល្អ កាលនាងរក្សាបានយ៉ាងនេះ មិនយូរប៉ុន្មានក៏នឹងបានទៅកើតក្នុងសំណាក់របស់យើងជាពិតប្រាកដ នាងចូរជាអ្នកមិនប្រមាទចុះ"ដូច្នេះហើយស្ដេចក៏ចៀសចេញទៅ ។

# នាងសុជាតាត្រាច់រង្គត់ទៅកាន់ភពផ្សេងៗ

ចាប់ផ្តើមអំពីកាលនោះមក ជួនកាលនាងបានត្រីដែលស្លាប់ឯង ជួនកាលមិនបាន កាលមិនបាន ដោយកាលកន្លងទៅ២-៣ ថ្ងៃប៉ុណ្ណោះ ក៏ស្គាំងស្គមធ្វើកាលកិរិយាហើយ ទៅកើតជាធីតានៃនាយស្មូនឆ្នាំងក្នុងក្រុងពារាណសីដោយផលនៃសីលនោះ។ គ្រានោះ ក្នុងកាលដែលនាងមានអាយុប្រហែល ១៥-១៦ឆ្នាំ សក្កទេវរាជទ្រង់ពិចារណាមើលថា "នាងកើតក្នុងទីណាហ្ន៎?" បានឃើញហើយទ្រង់គិតថា "ឥឡូវនេះ គួរយើងទៅកាន់ទីនោះ" ដូច្នេះហើយក៏ទ្រង់យកកែវ៧ប្រការដែលមានពណ៌ប្រាកដដូចជាពណ៌នៃផ្លែល្ពៅ ញុំាងយានតូចឱ្យពេញដោយរតនៈ៧ប្រការនោះ បរទៅកាន់ក្រុងពារាណសីស្តេចទៅកាន់

ផ្តល់ពពាយនាយ( អំពាវនាវ) ថា"ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយមក

យកផ្លែល្ពៅទាំងឡាយនេះចុះ"ប៉ុន្តែត្រាស់ទៅកាន់អ្នកដែលយកសណ្តែកខៀវ

និងសណ្តែករាជមាសជាដើមមកថា"ខ្ញុំមិនឱ្យដោយតម្លៃទេ"កាលជនទាំងនោះ

ទូលសួរថា"លោកនឹងឱ្យដោយប្រការដូចម្តេច?" ត្រាស់ថា "ខ្ញុំនឹងឱ្យដល់ស្ត្រី

អ្នករក្សាសីល" ។ **អ្នកក្រុង** បពិត្រនាយ ដែលឈ្មោះថា សីល តើដូចម្តេច មាន

ពណ៌ខ្មៅ ឬពណ៌ខៀវ ? **សក្កទេវរាជ** ពួកអ្នកទាំងឡាយមិនស្គាល់សីលថា

"ជាអ្វីផង" នឹងរក្សាសីលនោះដូចម្តេចកើត? ប៉ុន្តែយើងនឹងឱ្យដល់ស្ត្រីអ្នករក្សា

សីល ។ **អ្នកក្រុង** បពិត្រនាយ ធីតារបស់នាយស្នូនឆ្នាំងនោះត្រាច់ទៅនិយាយ

ថា ខ្ញុំរក្សាសីល សូមលោកចូរឱ្យដល់នាងនោះចុះ ។ សូម្បីធីតារបស់នាយស្នូន

ឆ្នាំងនោះ ក៏ពោលនឹង សក្កទេវរាជថា "បពិត្រនាយ បើដូច្នោះ ចូរឱ្យមក ខ្ញុំចុះ" ។ **សក្កទេវរាជ** នាងគឺជាអ្វី ? ធីតារបស់នាយស្នូនឆ្នាំងឆ្លើយថាខ្ញុំគឺជាស្ត្រី ដែលមិនលះបង់នូវសីល៥ ។ **សក្កទេវរាជ** ផ្លែល្ពៅទាំងនោះ ខ្ញុំក៏នាំមកដើម្បី នាងប៉ុណ្ណោះ ។ សក្កទេវរាជទ្រង់បរយានតូចទៅកាន់ផ្ទះរបស់នាង ហើយប្រ- ទានទ្រព្យ ដែលទេវតាគប្បីឱ្យដោយមានពណ៌ដូចជាផ្លែ ល្ពៅធ្វើមិនឱ្យជនដទៃ លួចយកទៅបាន ញុំាងធីតានៃនាយស្នូនឆ្នាំងឱ្យដឹងនូវព្រះអង្គហើយត្រាស់ថា" នេះជាទ្រព្យសម្រាប់ចិញ្ចឹមជីវិតរបស់នាង ។ នាងចូររក្សាសីល៥ កុំឱ្យដាច់ ហើយស្តេចក៏ចៀសចេញទៅ ។

# នាងសុជាតាជាធីតារបស់អសុរ

ចំណែកធីតារបស់នាយស្ទូនឆ្នាំងនោះចុតិចាកអត្តភាពនោះហើយកើតក្នុងភពអសុរដែលជាអ្នកមានពៀរចំពោះសក្កទេវរាជជាធីតា របស់អសុរក្នុងភពអសុរព្រោះការដែលនាងរក្សាសីលយ៉ាងល្អក្នុងពីរអត្តភាពទើបនាងបានជាស្ត្រី មានរូបស្រស់ស្អាត មានពណ៌សម្បុរដូចមាស ប្រកបដោយរូបសិរីមិនសាធារណៈ (ទូទៅ)។ ស្តេចអសុរដែលមាននាមថា**វេបចិត្តិ** និយាយនឹងអ្នកដែលមកហើយៗថា "ពួកអ្នកមិនសមគួរដល់ធីតារបស់យើងទេ" ហើយក៏មិនឱ្យធីតានោះដល់អ្នកណាមួយឡើយ គិតថា "ធីតារបស់យើងនឹងជ្រើសរើសបុរសដែលសមគួរដល់ខ្លួនដោយខ្លួនឯង" ដូច្នេះហើយ ទើបឱ្យពួកអសុរ

ប្រជុំគ្នា ហើយបានឱ្យភួងផ្កាក្នុងដៃនៃធីតានោះដោយពោលថា "នាងចូរជ្រើសរើសយកបុរសដែលសមគួរដល់នាងធ្វើជាស្វាមីចុះ" ។

## សក្កទេវរាជបន្លំធ្វើជាអសុរដណ្តើមនាងសុជាតា

ក្នុងខណៈនោះ សក្កទេវរាជទ្រង់ពិចារណារកមើល ទីដែលនាងកើតទ្រង់ជ្រាបនូវព្រឹត្តិការណ៍នោះហើយ ទ្រង់ត្រិះរិះថា ឥឡូវនេះសមគួរដែលយើងនឹងទៅនាំយកនាងមក ដូច្នេះហើយ បានទ្រង់និម្មិតភេទជាអសុរចាស់ទៅឈរខាងចុងបំផុតបរិស័ទ។ សូម្បីនាងអសុរកញ្ញានោះ កាលរមិលមើលខាងនោះ និងខាងនេះ លុះឃើញ សក្កទេវរាជនោះ ក៏ជាស្ត្រីមានហឫទ័យ គឺសេចក្តីស្រឡាញ់ដូចជាជំនន់ទឹកដ៏ធំកើតឡើងហើយ ដោយអំណាចបុព្វេសន្និ

វាសគ្រប់សង្កត់ហើយក៏ដាក់ចិត្តថា "នោះស្វាមីរបស់យើង" ទើបបោះភួងផ្កាទៅលើអសុរចាស់ សក្កទេវរាជនោះ ។ ពួកអសុរក៏ចំអកថា " ព្រះរាជារបស់ពួកយើងមិនបានអ្នក ដែលសមគួរដល់ធីតារហូតអស់កាលប្រមាណប៉ុណ្ណោះ ឥឡូវនេះបានហើយ អ្នកដែលចាស់ជាងអសុររូបនេះ ទើបសមគួរដល់ធីតារបស់ព្រះអង្គ"ដូច្នេះហើយក៏ចៀសចេញទៅ ។ ចំណែកឯ សក្កទេវរាជទ្រង់ចាប់ដៃអសុរកញ្ញានោះហើយទ្រង់ប្រកាសថា "យើងគឺជាសក្កទេវរាជ" ហើយទ្រង់ហោះទៅក្នុងអាកាស ។ ពួកអសុរដឹងថា "ពួកយើងត្រូវសក្កៈចាស់បញ្ឆោតហើយ" ទើបនាំគ្នាដេញតាមសក្កទេវរាជនោះទៅ ។ទេពសារថីឈ្មោះមាតលីនាំវេជយន្តរថមកបញ្ឈប់ចាំនៅពាក់កណ្តាលផ្លូវ ។ សក្កទេវរាជ

ទ្រង់លើកអសុរកញ្ញាឡើងកាន់វេជយន្តរថ នោះហើយមានមុខឆ្ពោះទៅកាន់ទេវនគរ បរវេជយន្តរថទៅ ។គ្រានោះ កូនគ្រុឌទាំងឡាយបានឮសូរសម្លេងរថហើយក៏ភ័យខ្លាចស្រែកយំ ។ សក្កទេវរាជទ្រង់ព្រះសណ្តាប់នូវសម្លេង យំរបស់កូនគ្រុឌហើយ ត្រាស់សួរមាតលីថា នុ៎ះជាសម្លេងស្រែកយំរបស់ពួកណា ? **មាតលី** បពិត្រមហារាជ សម្លេងយំរបស់កូន គ្រុឌ ។ **សក្កទេវរាជ** ព្រោះហេតុអ្វីទើបវាយំ ? **មាតលី** ព្រោះបានឮសម្លេងរថហើយ ខ្លាចស្លាប់ ។ **សក្កទេវរាជ** ត្រាស់ថា "ព្រោះអាស្រ័យយើងតែម្នាក់ បក្សីមានប្រមាណប៉ុណ្ណេះត្រូវកម្លាំងនៃរថឱ្យវិនាសហើយ ពួកវាកុំវិនាសឡើយ អ្នកចូរត្រឡប់រថវិញចុះ" ។ មាតលីទេវបុត្រនោះឱ្យសញ្ញាដល់សេះសន្ធពដោយរំពាត់ឱ្យត្រឡប់ ។ ពួកអសុរឃើញ

កិរិយានោះហើយគិតថា "សក្កចាស់ចៀសចេញទៅតាំងអំពីអសុរបុរី ឥឡូវ

ត្រឡប់រថមកវិញ នឹងបានអ្នកជំនួយជាពិតប្រាកដ" ទើបត្រឡប់ចូលទៅកាន់

អសុរបុរីតាមផ្លូវដែលមកហើយនោះឯង មិនងើបក្បាលឡើងទៀត ។ចំណែក

សក្កទេវរាជ ទ្រង់នាំអសុរកញ្ញាឈ្មោះសុជាតាទៅកាន់ទេពនគរហើយ ទ្រង់

ស្ថាបនាទុកក្នុងតំណែងប្រធាននាងទេពអប្សរ២កោដិកន្លះ ។ អសុរកញ្ញាទូល

សូមពរសក្កទេវរាជថា"សូមតេជៈ មហារាជ មាតា បិតា បងប្រុស បងស្រី

របស់ខ្ញុំព្រះអង្គក្នុងទេវលោកនេះមិនមាន ព្រះអង្គនឹងស្ដេចទៅកាន់ទីណាៗ

គប្បីទ្រង់ព្រះករុណា ) នាំខ្ញុំព្រះអង្គទៅកាន់ទីនោះផង សក្កទេវរាជបានព្រះ-

រាជទានប្ដេជ្ញាដល់អសុរកញ្ញាថា "បាន" ។

# ពួកអសុរខ្លាចសក្កទេវរាជ

ក៏ចាប់ផ្តើមអំពីកាលនោះមក កាលផ្កាចិត្តបាដលិ រីក ពួកអសុរប្រាថ្នា ដើម្បីនឹងច្បាំងនឹងសក្កទេវរាជ ឡើងមកដើម្បីប្រយោជន៏ដល់ការច្បាំង ដោយសម្គាល់ថា ជាកាលដែលផ្កាបារិច្ឆត្តកព្រឹក្សដ៏ជាទិព្វរបស់យើងទាំងឡាយរីក ។

សក្កទេវរាជបានទទួលនូវការរក្សាអំពីពួកនាគដែលនៅខាងក្រោមនៃសមុទ្រ ។ បន្ទាប់អំពីនោះ ពួកគ្រុឌ បន្ទាប់អំពីនោះ ពួកកុម្ភណ្ឌ បន្ទាប់អំពីនោះ ពួកយក្សបន្ទាប់អំពីនោះ ពួកទេវតាចាតុម្មហារាជិកា ចំណែកជាន់លើជាងគេបង្អស់ ប្រតិស្ថានរូបចម្លាក់ព្រះឥន្ទ ដែលមានអាវុធពេជ្រក្នុងព្រះហស្តត្រង់ទ្វារនៃទេពនគរទាំងឡាយ ។ ពួកអសុរ សូម្បីឈ្នះពួកនាគជាដើមមកហើយឃើញ

រូបប្រៀបរបស់ព្រះឥន្ទអំពីចម្ងាយ ក៏រមែងរត់ទៅ ដោយគិតថា សក្កទេវរាជស្តេច ចេញមកហើយ" ។

## អានិសង្សក្នុងសេចក្តីមិនប្រមាទ

ព្រះសាស្តាត្រាស់ថា "បពិត្រ **មហាលិ** មឃមាណពបដិបត្តិអប្បមាទបដិបទាយ៉ាងនេះ លុះមឃមាណពនោះជាអ្នកមិនប្រមាទហើយយ៉ាងនេះ ទ្រង់សោយរាជក្នុងទេវលោកទាំង២ ដែលឈ្មោះថា សេចក្តីមិនប្រមាទនោះ បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម សរសើរហើយ ព្រោះថាការសម្រេចគុណវិសេសដែលជាលោកិយៈ និងលោកុត្តរៈសូម្បីទាំងអស់រមែងមានទៅបាន ព្រោះអាស្រ័យសេចក្តីមិនប្រមាទ"ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**

**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា។**

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុតជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ត្មិះតិះដៀលនូវសេចក្តីប្រមាទសព្វៗកាល។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បមាទេន** គឺព្រោះតែសេចក្តីមិនប្រមាទ ដែលខ្លួនធ្វើទុក តាំងអំពីការសំអាតភូមិប្រទេសក្នុងអចលគ្រាមជាដើម។ បទថា **មឃវា** ជាដើម សេចក្តីថាមឃមាណពដែលប្រាកដឈ្មោះថា "**មឃវៈ**"

ឥឡូវនេះឈ្មោះថាដល់ភាពជាអ្នកប្រសើរជាទីបំផុតជាងទេវតាទាំងឡាយ

ព្រោះភាពជាព្រះរាជានៃទេវតាទាំង ២ជាន់ ។ បទថា **បសំសន្តិ** សេចក្តីថា

បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម រមែងសរសើរសេចក្តីមិនប្រមាទតែ

ម្យ៉ាង ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះសេចក្តីមិនប្រមាទជាហេតុនាំ

ឱ្យបានសម្រេចនូវគុណវិសេសដែលជាលោកិយនិងលោកុត្តរៈទាំងអស់ ។

បាទព្រះគាថាថា **បមាទោ គរហិតោ សទា** សេចក្តីថា ចំណែកសេចក្តីប្រមាទ

ព្រះអរិយៈទាំងឡាយរមែងតិះដៀល គឺនិន្ទាហើយជានិច្ច ។ សួរថាព្រោះហេតុ

អ្វី? ឆ្លើយថា ព្រោះសេចក្តីប្រមាទ ជាឫសគល់នៃគុណវិបត្តិគ្រប់យ៉ាង ។

ពិតណាស់ ភាពជាអ្នកជួបគ្រោះអាក្រក់ក្នុងមនុស្សគ្គិ ការចូលដល់អបាយភូមិ

ក្តី សុទ្ធតែមានសេចក្តីប្រមាទជាមូលទាំងអស់ ។ ក្នុងកាលចប់ព្រះគាថា ស្តេច

លិច្ឆវីនាមថា មហាលិ ទ្រង់តាំងនៅក្នុងសោតាបត្តិផល ។ សូម្បីបរិស័ទដែលប្រ

ជុំគ្នាច្រើននោះ ក៏បានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើមដែរ ។

**ចប់រឿងមឃមាណព**

# អានិសង្សសាងសាលា

## រឿងនន្ទិយៈឧបាសក

បានឮថា ក្នុងក្រុងពារាណសី មានបុត្រមួយនៃត្រកូលដែលដល់ព្រមដោយសទ្ធា ឈ្មោះថា **នន្ទិយៈ** នន្ទិយៈនោះជាអ្នកបរិបូរណ៍ដោយសទ្ធាក្នុងព្រះពុទ្ធសាសនា បានទំនុកបម្រុងព្រះភិក្ខុសង្ឃ និងមាតាបិតា ក្នុងកាលដែលនន្ទិយៈកុមារនោះចម្រើនវ័យ (កំលោះ) មាតាបិតារបស់លោកបានមានបំណងនាំធីតាម្នាក់ឈ្មោះ **រេវតី** អំពីផ្ទះអ៊ុំប្រុសដើម្បីជាភរិយារបស់នាយនន្ទិយៈនោះតែនាងរេវតីនោះជាស្ត្រីដែលមិនមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទើបនាយនន្ទិយៈមិនប្រាថ្នាចង់យកនាងធ្វើជាភរិយាទេ ។

លំដាប់នោះ មាតារបស់គេពោលនឹងនាងរេវតីថា កូនចូររៀបចំកន្លែងរបស់ភិក្ខុសង្ឃ ហើយចូរក្រាលអាសនទុកក្នុងផ្ទះនេះចូរតាំងជើងបាត្រទុកក្នុងពេលដែលភិក្ខុសង្ឃទាំងឡាយនិមន្តមកដល់ហើយ រេវតីកូនត្រូវទទួលបាត្រនិមន្តឱ្យលោកគង់ក្នុងអាសនៈដ៏សមគួរហើយយកសំពត់តំរងទឹកត្រងទឹកថ្វាយភិក្ខុសង្ឃ ហើយលាងបាត្រក្នុងពេលភិក្ខុសង្ឃលោកឆាន់រួច រេវតីកាលបើនាងធ្វើយ៉ាងនេះបាន នាងនឹងជាទីស្រឡាញ់នៃបុត្ររបស់យើង ។ នាងបានធ្វើយ៉ាងនោះហើយតមកទៀតមាតាបិតាបានពណ៌នាគុណរបស់នាងរេវតីប្រាប់ដល់នន្ទិយៈថានាងជាមនុស្សអត់ធន់ចំពោះពាក្យទូន្មានជាដើមនន្ទិយៈបានស្តាប់ហើយក៏ទទួលថាល្អហើយ ទើបកំណត់ថ្ងៃធ្វើអាវាហមង្គល ។

នាយនន្ទិយៈបានពោលនឹងនាងថា ប្រសិនបើអ្នកបម្រើភិក្ខុសង្ឃ និង មាតាបិតារបស់ខ្ញុំដូច្នេះនាងនឹងបានជាម្ចាស់នៃផ្ទះនេះ ដូច្នេះចូរនាងកុំប្រមាទ នាងទទួលថាល្អហើយ ហើយនាងបានធ្វើជាអ្នកមានសទ្ធាប្រមាណជាពីរបីថ្ងៃ ប៉ុណ្ណោះរហូតប្រសូត្របុត្រពីរនាក់ មាតាបិតារបស់នាយនន្ទិយៈបានស្លាប់ ហើយ ភាពជាធំក្នុងផ្ទះក៏បានធ្លាក់ក្នុងដៃនៃនាងរេវតីតែម្តង ។

## នន្ទិយៈតាំងក្នុងតំណែងជាម្ចាស់ទាន

ចាប់ផ្តើមតាំងតែមាតាបិតាស្លាប់ទៅ នាយនន្ទិយៈ ក៏ជា**មហាទានបតី** ធ្វើទានចំពោះភិក្ខុសង្ឃ ឱ្យអាហារសម្រាប់មនុស្សក្រីក្រកំព្រា និងមនុស្សដើរ ផ្លូវឆ្ងាយជាដើមខាងមុខផ្ទះរបស់ខ្លួន ។ ក្នុងកាលតមកគេបានស្តាប់ធម៌

ទេសនារបស់ព្រះសាស្តាហើយបានកំណត់ដឹងអានិសង្សក្នុងការថ្វាយអាវាស

(វត្ត) នន្ទិយៈបានសាងសាលាមុខ៤ ប្រដាប់ដោយបន្ទប់៤ផងដែរក្នុងមហា

វិហារនៃព្រៃឥសិបតនៈមិគទាយវ័ន និងរៀបចំគ្រែតាំងជាដើម កាលធ្វើស្រេច

ហើយក៏បង្ហោនថ្វាយនូវទីសេនាសនៈទីអាវាសដល់ព្រះសង្ឃ ដែលមានព្រះពុទ្ធ

ជាប្រធាន ហើយបានទឹកទក្ខិណោទក ដល់ព្រះតថាគត ។ ក្នុងមួយរំពេចនោះ

ឯងប្រាសាទទិព្វសម្រេចដោយរតនៈ៧ប្រការ បរិបូរណ៍ដោយពួកនារីដ៏ច្រើន

ប្រាសាទមានទំហំ១២យោជន៏ កម្ពស់ប្រមាណ១០០យោជន៏ផុសឡើងក្នុង

ស្ថានតាវតឹង្សព្រមដោយការច្រូចទឹកទក្ខិណោទក ក្នុងព្រះហស្តរបស់ព្រះសា-

ស្តាតែម្តង ។

# ព្រះមហាមោគ្គល្លាននិមន្តទៅសាកសួរពួកទេវតា

ក្រោយមក ថ្ងៃមួយព្រះមហាមោគ្គលានបាននិមន្តទៅកាន់ស្ថានទេវលោក លោកបានឈរនៅមិនឆ្ងាយអំពីប្រាសាទនោះ លោកបានសួរទៅដល់ទេវបុត្រទាំងឡាយដែលមកគាល់លោកថា តើប្រាសាទទិព្វដែលពេញដោយនាងទេពអប្សរនោះកើតឡើងដើម្បីអ្នកណា ? ពួកទេវបុត្រនោះបានពិត្យថ្វាយព្រះមោគ្គលានថា លោកដ៏ចម្រើនវិមានទិព្វនោះកើតឡើងដើម្បីប្រយោជន៏ដល់បុត្ររបស់គហបតីឈ្មោះនន្ទិយៈដែលជាអ្នកសាងនូវទីសេនាសនៈថ្វាយដល់ព្រះសាស្តាក្នុងព្រៃឥសិបតនៈមិគទាយវន័ ចំណែកពួកនាងទេពអប្សរបានឃើញព្រះថេរៈហើយ ក៏ចុះអំពីប្រាសាទ ពោលថាបពិត្រព្រះគុណម្ចាស់ ខ្ញុំ

កើតក្នុងទីនេះដោយសង្ឃឹមថានឹងជាអ្នកបម្រើរបស់នាយនន្ទិយៈ តែកាលមិន

បានជួបនាយនន្ទិយៈនោះពួកយើងក៏អផ្សុកជាខ្លាំងពួកនាងជាទេពអប្សរទាំង-

អស់បានផ្ញើដំណឹងទៅកាន់នាយនន្ទិយៈដែលនៅស្ថានមនុស្សថា សូមលោក

ព្រះគុណម្ចាស់ប្រាប់ដល់គេថា ការលះសម្បត្តិមនុស្សហើយយកសម្បត្តិទេវតា

គឺប្រៀបដូចជាទម្លាយថាសដីហើយកាន់យកថាសមាសដូច្នោះ ។

## ទិព្វសម្បត្តិកើតទទួលសម្រាប់អ្នកធ្វើបុណ្យ

ព្រះថេរៈត្រឡប់ពីស្ថានទេវលោកហើយ ចូលគាល់ព្រះសាស្តាទូល

សួរថា បពិត្រព្រះអង្គដ៏ចម្រើនទិព្វសម្បត្តិរមែងកើតឡើងដល់បុគ្គលអ្នកធ្វើល្អ

នៅក្នុងមនុស្សលោកនេះឬទេ ?

ព្រះអង្គត្រាស់ថា ម្នាលមោគ្គល្លានទិព្វសម្បត្តិដែលកើតក្នុងទេវលោក សម្រាប់នាយនន្ទិយៈដែលអ្នកបានឃើញហើយឬ ហេតុអ្វីទើបសួរតថាគតទៀត **មោគ្គលាន**ទូលថា ទិព្វសម្បត្តិកើតឡើងយ៉ាងនោះមែនឬព្រះអង្គ លំ-ដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា ម្នាលមោគ្គលានអ្នកនិយាយអ្វីហ្នឹង ឧបមាថាអ្នកណាដែលឈរនៅនឹងទ្វារផ្ទះបានឃើញបុត្រឬបងប្អូនដែលទៅក្នុងទីផ្សេងៗ ហើយត្រឡប់មកវិញ ពួកញាតិរបស់គេក៏ត្រេកអររីករាយហើយក៏ពោលថា ឪពុកមកដល់ហើយយ៉ាងណាមិញពួកទេវតាទាំងឡាយកាន់យកនូវគ្រឿងបណ្ណាការដ៏ជាទិព្វ១០យ៉ាង ដោយគិតថា យើងមុន យើងមុន ហើយរមែងត្រេកអរដ៏ក្រៃលែងនឹងស្ត្រី ឬបុរសអ្នកធ្វើសេចក្តីត្រេកអរក្នុងទេវលោក

នេះ ព្រះសាស្តាបានត្រាស់ព្រះគាថានេះថា

**ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ**

**ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ**

**តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ**

**បញ្ញានិ បដិគណ្ហន្តិ បិយំ ញាតីវ អាគតំ ។**

ពួកញាតិក្តី មិត្តក្តី សំឡាញ់ក្តី រមែងត្រេកអរនឹងបុរស

ដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្តី

មកដល់ហើយ យ៉ាងណាមិញបុណ្យទាំងឡាយ តែងទទួល

បុគ្គល ដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោកនេះ ទៅ

កាន់លោកខាងមុខ    ដូចញាតិទាំងឡាយទទួលបុរសជាទី

ស្រឡាញ់ទើបមកដល់ ដូច្នោះឯង ។

# រឿងអនាថបិណ្ឌិកសេដ្ឋី និងរឿង រាជគហសេដ្ឋី

សម័យនោះឯង អនាថបិណ្ឌិកគហបតិជាប្ដីប្អូនស្រីរបស់រាជគហសេដ្ឋី គឺជាប្អូនថ្លៃរាជគហសេដ្ឋី ។ គ្រានោះ អនាថបិណ្ឌិកគហបតិបានទៅកាន់ ក្រុងរាជ-គ្រឹះ ដោយកិច្ចការនីមួយ ។ សម័យនោះឯង រាជគហសេដ្ឋីនិមន្តព្រះសង្ឃមានព្រះពុទ្ធអង្គជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ ឯរាជគហសេដ្ឋីក៏បានបង្គាប់ខ្ញុំប្រុសស្រីខ្លះ និងពួកអ្នកធ្វើការឈ្នួលខ្លះថា នែនាយរាល់គ្នា បើដូច្នោះចូរអ្នករាល់គ្នាក្រោកពីព្រលឹមហើយ ចំអិនបបរ ចំអិនបាយ ចាត់ចែងសម្ល និងគាត់តែងសម្លឧត្តរិភង្គៈ(ឱ្យល្អ) ។

លំដាប់នោះ អនាថបិណ្ឌិកគហបតិមានសេចក្ដីត្រិះរិះថាកាលពីដើមបើ

អញបានមកដល់ហើយគហបតិនេះ  ក៏រមែងតែបញ្ឈប់កិច្ចការទាំងពួងហើយ

និយាយរាក់ទាក់មកនឹងអញ ក៏ឥឡូវគហបតិនេះជាអ្នកតោះតើយ (បែរទៅ)

ជាបង្គាប់ខ្ញុំប្រុសស្រីខ្លះ  ពួកអ្នកធ្វើការឈ្នួលខ្លះថា  នែនាយរាល់គ្នា បើ

ដូច្នោះ ចូរអ្នក រាល់គ្នាក្រោកពីព្រលឹម ហើយចំអិនបបរ ចំអិនបាយចាត់ចែង

សម្ល និងតាក់តែង សម្លឧត្តរិភង្គៈ(ឱ្យល្អ) ប្រហែលជាគហបតិនេះ មានអាវាហ

មង្គល  ឬវិវាហមង្គល ឬក៏មហាយញ្ញពិធី  ឬពុំនោះគាត់អញ្ជើញព្រះបាទ

ពិម្ពិសារមគធសេនិយរាជ  ព្រមទាំងពួកពលឱ្យមកទទួលក្រយាហារក្នុងថ្ងៃ

ស្អែកទេដឹង ។

គ្រានោះ  រាជគហសេដ្ឋីបង្គាប់ខ្ញុំប្រុសស្រីខ្លះ  ពួកអ្នកធ្វើការឈ្នួលខ្លះ

រួចហើយ ទើបចូលទៅរកអនាថបិណ្ឌិកគហបតិ លុះចូលទៅដល់ហើយក៏

និយាយរាក់ទាក់ ជាមួយនឹងអនាថបិណ្ឌិកគហបតិហើយក៏អង្គុយក្នុងទីដ៏សម

គួរ ។ អនាថបិណ្ឌិកគហបតិ និយាយនឹងរាជគហសេដ្ឋីដែលអង្គុយក្នុងទីដ៏សម

គួរដោយ ពាក្យដូច្នេះថា នែគហបតិកាលពីដើមបើខ្ញុំបានមកដល់ហើយ អ្នក

រមែងតែបញ្ឈប់កិច្ចការទាំងពួង ហើយនិយាយរាក់ទាក់មកជាមួយនឹងខ្ញុំ ក៏

ឥឡូវនេះ អ្នក ធ្វើ តោះតើយ បែរជាបង្គាប់ខ្ញុំប្រុសស្រីខ្លះពួកអ្នកធ្វើការឈ្នួល

ខ្លះថា នែនាយ រាល់គ្នា បើដូច្នេះចូរអ្នករាល់គ្នាក្រោកពីព្រលឹម ហើយចំអិន

បបរ ចំអិនបាយ ចាត់ចែងសម្ល និងតាត់តែងសម្លឧត្តរិភង្គៈ (ឱ្យល្អ) នែ

គហបតិអាវាហវិវាហមង្គល ឬ មហាយញ្ញពិធីនឹងកើតមានឡើងប្រាកដដល់

អ្នកឬអ្វី ឬមួយអ្នកបាន អញ្ជើញ ព្រះបាទពិម្ពិសារមគធសេនិយរាជព្រមទាំង

ពួកពល ឱ្យមកទទួល ក្រយាហារ ក្នុងថ្ងៃស្អែក។ រាជគហសេដ្ឋីនិយាយថា នែ

គហបតិ អាវាហវិវាហមង្គល របស់ខ្ញុំមិនមានទេ ឬមួយខ្ញុំអញ្ជើញព្រះបាទ

ពិម្ពិសារមគធសេនិយរាជ ព្រមទាំងពួកពល ឱ្យមកទទួលក្រយាហារក្នុងថ្ងៃ

ស្អែកនេះក៏ទេដែរ ខ្ញុំមានតែមហាយញ្ញពិធីមែន គឺ និមន្តព្រះសង្ឃមានព្រះពុទ្ធ

អង្គជាប្រធានមកទទួលភត្តក្នុងថ្ងៃស្អែកនេះ។ អនាថបិណ្ឌិកគហបតិសួរថា នែ

គហបតិ អ្នកពោលថា **ពុទ្ធោ** ដូច្នេះឬ ? រាជគហ សេដ្ឋីតបថា អើគហបតិ ខ្ញុំ

ពោលថា **ពុទ្ធោ** ដូច្នេះមែន។ អនាថបិណ្ឌិក គហបតិ សួរថា នែគហបតិអ្នក

ពោលថា **ពុទ្ធោ** ដូច្នេះឬ? រាជគហសេដ្ឋីតបថា អើ គហបតិ ខ្ញុំពោលថា **ពុទ្ធោ**

ដូច្នេះមែន ។ អនាថបិណ្ឌិកគហបតិសួរថា នែគហបតិអ្នកពោល ថា **ពុទ្ធោ** ដូច្នេះឬ? រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា **ពុទ្ធោ** ដូច្នេះ មែន ។ អនាថបិណ្ឌិកគហបតិពោលទៀតថា អើគហបតិ សម្លេងគឹកកងថា **ពុទ្ធោ** ដូច្នេះ នេះជាសម្លេងដែលគេរកបាន ដោយកម្រក្នុងលោក ម្នាលគហបតិ តើខ្ញុំនឹងអាចចូលទៅគាល់ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ទាន់ក្នុងពេលនេះ បានដែរឬ? រាជគហសេដ្ឋីតបថា ម្នាលគហបតិ កាលនេះជាកាលមិនគួរដើម្បីនឹង ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធទាន់ក្នុងពេលនេះទេ ចាំដល់ វេលាថ្ងៃស្អែកសឹមអ្នកចូលទៅគាល់ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ទើបគួរ ។

គ្រានោះ អនាថបិណ្ឌិកគហបតិគិតថា ឥឡូវនេះវេលាថ្ងៃស្អែកនេះ អញនឹងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះទើបគួរ គិតហើយក៏ដំកល់ស្មារតី ចំពោះទៅរកព្រះពុទ្ធជាអារម្មណ៍ ហើយក៏ដេកទៅក៏ក្នុង វេលាយប់ (នោះ) អនាថបិណ្ឌិកគហបតិ ស្មានថាភ្លឺហើយ ក៏ក្រោកឡើង ៣ ដង។ លំដាប់នោះ អនាថបិណ្ឌិកគហបតិចូលទៅកាន់ ទ្វារសីតវ៉ន (ព្រៃត្រជាក់) ។ ពួក មនុស្សក៏នាំគ្នាបើកទ្វារឱ្យ។ កាលអនាថបិណ្ឌិកគហបតិ ចេញផុតអំពីនគរហើយ ពន្លឺ ក៏បាត់ទៅវិញ។ ស្រាប់តែមានងងឹតកើតឡើង។ ភ័យសេចក្តីតក់ស្លុតនិងព្រឺ រោម ក៏កើតឡើង។ អនាថបិណ្ឌិកគហបតិចង់ត្រឡប់អំពីនោះមកវិញ។

គ្រានោះ សិវកយក្សដែលបាត់ទៅ ក៏បញ្ចេញសម្លេងឡើងថា

**សតំ ហត្ថី សតំ អស្សា សតំ អស្សតរីរថា**

**សតំ កញ្ញា សហស្សានិ អាមុត្តមណិកុណ្ឌលា**

**ឯកស្ស បទវីតិហារស្ស កលំ នាគ្ឃន្តិ សោឡសឹ។**

**អភិក្កម គហបតិ អភិក្កម គហបតិ អភិក្កន្តន្តេ**

**សេយ្យោ នោ បដិក្កន្តន្តិ។**

ដំរី ១ សែន សេះ ១ សែន រថទឹមដោយមេសេះអស្សតរ ១ សែន ស្រីជំទង់ដែលប្រដាប់ដោយកុណ្ឌល ជាវិការៈនៃកែវមណី ១ សែន ក៏មិនដល់មួយចំណិត នៃការឈានទៅ ១ ជំហាន

ដែលបណ្ឌិតចែកឱ្យជាចំណែក ១៦ អស់វារៈ ១៦ ដង ទេ។

ម្នាលគហបតិ អ្នកចូរឈានដើរទៅ ម្នាលគហបតិ អ្នកចូរឈាន

ដើរទៅការឈានដើរទៅរបស់អ្នកប្រសើរណាស់ការត្រឡប់ទៅវិញ

មិនប្រសើរទេ ។

លំដាប់នោះ អនាថបិណ្ឌិកគហបតិ ក៏បាត់ងងឹតទៅវិញ។ ពន្លឺក៏កើត

ប្រាកដ ឡើង។ ភ័យសេចក្តីតក់ស្លុតព្រឺរោមនោះឯង ក៏រម្ងាប់បាត់ទៅ។

អនាថបិណ្ឌិកគហបតិ ក៏បាត់ពន្លឺអស់វារៈពីរដងផង។ បេ។ អស់វារៈបីដង

ផង។ ងងឹតក៏កើត ប្រាកដឡើង។ ភ័យសេចក្តីតក់ស្លុតព្រឺរោមក៏កើតឡើង។

អនាថបិណ្ឌិកគហបតិ ចង់ត្រឡប់អំពីទីនោះមកវិញ សីវកយក្សដែលបាត់ទៅ

ហើយនោះ ស្រាប់តែ បញ្ចេញសម្លេងអស់វារៈជាគំរប់បីដងថា

**សតំ ហត្ថី សតំ អស្សា សតំ អស្សតរីរថា**

**សតំ កញ្ញា សហស្សានិ អាមុត្តមណិកុណ្ឌលា**

**ឯកស្ស បទវីតិហារស្ស កលំ នាគ្ឃន្តិ សោឡសឹ។**

**អភិក្កម គហបតិ អភិក្កម គហបតិ**

**អភិក្កន្តន្តេ សេយ្យោ នោ បដិក្កន្តន្តិ។**

ដំរី ១ សែន សេះ ១ សែន រថទឹមដោយមេសេះអស្សតរ ១ សែន ស្រីជំទង់ដែលប្រដាប់ដោយ**កុណ្ឌល** ជាវិការៈនៃកែវមណី ១ សែន ក៏មិនដល់មួយចំណិត នៃការឈានទៅ ១ ជំហាន ដែលបណ្ឌិតចែកឱ្យជាចំណែក ១៦ អស់វារៈ ១៦ ដង ទេ។

ម្នាលគហបតិ អ្នកចូរឈានដើរទៅ ម្នាលគហបតិ អ្នកចូរឈាន

ដើរទៅការឈានដើរទៅរបស់អ្នកប្រសើរណាស់ការត្រឡប់ទៅ

វិញមិនប្រសើរទេ ។

អនាថបិណ្ឌិកគហបតិ ក៏បាត់ងងឹតទៅវិញអស់វារះបីដង ។ ពន្លឺក៏កើត

ប្រាកដឡើង ។ ភ័យសេចក្តីតក់ស្លុតព្រឺរោមនោះឯង ក៏រម្ងាប់បាត់ទៅ ។

លំដាប់នោះ អនាថបិណ្ឌិកគហបតិចូលទៅកាន់សីតវ័ន ។

សម័យនោះឯង ព្រះមានព្រះភាគទ្រង់តើនឡើង ក្នុងបច្ចូសសម័យនៃ

រាត្រីហើយទ្រង់ចង្រ្កមក្នុងទីវាល ។ ព្រះមានព្រះភាគទ្រង់ទតឃើញអនាថបិ-

ណ្ឌិកគហបតិដើរមកពីចម្ងាយលឹម១លុះទតឃើញហើយក៏ថយចុះអំពីទីចង្រ្កម

ទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយស្រាប់ ។ ព្រះមានព្រះភាគទ្រង់គង់

ហើយទើបមានព្រះបន្ទូលនេះទៅនឹងអនាថបិណ្ឌិកគហបតិថា ម្នាលសុទត្តអ្នក

ចូរមកនេះ ។ ឯអនាថបិណ្ឌិកគហបតិ មានចិត្តត្រេកអររីករាយ ដោយគិតថា

ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលត្រាស់ហៅ អាត្មាអញចំឈ្មោះ ហើយ

ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទៀបព្រះបាទ

ទាំងគូរនៃព្រះមានព្រះភាគហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រ

ព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ផ្ទុំស្កល់ស្រួលទេឬ ?

ព្រះមានព្រះភាគត្រាស់ថា

**សព្វទា វេ សុខំ សេតិ**

**ព្រាហ្មណោ បរិនិព្វុតោ**

**យោ ន លិម្បតិ កាមេសុ**

**សីភូតោ និរូបធិ ។**

**សព្វា អាសត្តិយោ ឆេត្វា**

**វិនេយ្យ ហទយេ ទរំ**

**ឧបសន្តោ សុខំ សេតិ**

**សន្តឹ បប្បុយ្យ ចេតសោ ។**

បុគ្គលណាមានចិត្តត្រជាក់ មិនមានកិលេសគ្រឿងសៅហ្មង

មិនជាប់នៅក្នុងកាមទាំងឡាយ បុគ្គលនោះឈ្មោះថាព្រាហ្មណ៍

អ្នកមានទុក្ខរំលត់ហើយ រមែងដេកនៅជាសុខគ្រប់កាលទាំង-

ពួង ។ ( មនុស្សណា) កាត់បង់នូវសេចក្តីប្រាថ្នា ក្នុងភពទាំង

ពួង ហើយនាំបង់នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យចេញ

( មនុស្សនោះ) ឈ្មោះថាជាអ្នកស្ងប់រម្ងាប់ ដល់ហើយនូវ

សេចក្តីរម្ងាប់នៃចិត្ត រមែងដេកនៅជាសុខ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់សម្តែងអនុបុព្វីកថា ដល់អនាថ-

បិណ្ឌិកគហបតិ ។ អនុបុព្វីកថានោះគឺជាអ្វី? អនុបុព្វីកថានោះគឺ ទ្រង់ប្រកាស

នូវទានកថា១ សីលកថា ១ សគ្គកថា ១ កាមាទីនវៈដ៏លាមកសៅហ្មង ១ និង

អានិសង្សក្នុងការចេញកសាងផ្នួស ១ ។ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ថា

អនាថបិណ្ឌិកគហបតិ មានចិត្តស្រួលមានចិត្តទន់មានចិត្តប្រាសចាកនីវរណធម៌

មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លាក្នុងពេលណា ក៏ធម្មទេសនាដែលព្រះពុទ្ធ

ទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង ព្រះអង្គទ្រង់ប្រកាសនូវ

ធម្មទេសនានោះគឺ ទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ មគ្គសច្ចៈ ក្នុងពេល

នោះ។ សំពត់ដ៏ស្អាត ដែល មិនមានពណ៌ខ្មៅតែងទទួលយកនូវទឹកជ្រលក់

ដោយប្រពៃយ៉ាងណាមិញ ក៏ដូចជា ធម្មចក្ខុ គឺ សោតាបត្តិផលមានធូលីទៅ

ប្រាសហើយ មានមន្ទិលទៅប្រាសហើយ ក៏បានកើតឡើងដល់អនាថបិណ្ឌិក-

គហបតិ លើអសនៈនោះដូច្នេះថា ធម្មជាតិឯណានីមួយ មានសភាពកើតឡើង

ហើយជាធម្មតា ធម្មជាតិទាំងអស់នោះមានសភាព រលត់ទៅវិញជាធម្មតា។

គ្រានោះ អនាថបិណ្ឌិកគហបតិបានឃើញធម៌ហើយបានលុះធម៌ហើយ បាន ជ្រាបច្បាស់ធម៌ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងចាកសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លាលែងជឿនូវពាក្យបុគ្គលដទៃក្នុងសាសនា របស់ព្រះសាស្តា ហើយបានក្រាបបង្គំ ទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើនធម៌ដែលព្រះអង្គ ទ្រង់សម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជា មនុស្សបើកវត្ថុដែលគេផ្កាប់ឱ្យផ្ងារឡើង ឬដូចជាមនុស្សបើកបង្ហាញរបស់ដែលគេ លាក់បិទបាំងទុក ពុំនោះសោតដូចជាមនុស្សប្រាប់

ផ្លូវ ដល់អ្នកវង្វេង ឬដូចមនុស្ស កាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹតដោយគិត

ថាមនុស្សដែលមានភ្នែកនឹងមើល ឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏

ចំរើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះ មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះ

សង្ឃផង ថាជាទីពឹងទីរលឹក សូមព្រះ មានព្រះភាគទ្រង់ជ្រាប នូវខ្ញុំព្រះអង្គ

ថាជាឧបាសកដល់ហើយនូវត្រៃសរណគមន៍ ស្មើដោយជីវិតចាប់ដើមតាំងអំពី

ថ្ងៃនេះជាដើមរៀងទៅ បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀតសូមព្រះមានព្រះ

ភាគមួយអន្លើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះ អង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃ

ស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយ តុណ្ហីភាព ។ គ្រានោះ អនាថ

បិណ្ឌិកគហបតិដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ ទទួលនិមន្តហើយ ក៏ក្រោក

ចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណ ចៀសចេញទៅ ។

រាជគហសេដ្ឋីបានឮថា អនាថបិណ្ឌិកគហបតិ និមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែកដូច្នេះហើយ ។ ចំណែកឯរាជគហសេដ្ឋីបាន និយាយពាក្យនេះនឹងអនាថបិណ្ឌិកគហបតិថា ម្នាលគហបតិ បានឮថាអ្នកនិមន្ត ព្រះសង្ឃមានព្រះពុទ្ធជាប្រធានដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈនឹងធ្វើភត្តដើម្បីព្រះសង្ឃមានព្រះពុទ្ធជាប្រធានដោយវត្ថុសម្រាប់ចាយវាយ( ស្បៀង) ឯណា ម្នាលគហបតិ ខ្ញុំនឹងឱ្យវត្ថុសម្រាប់ចាយវាយនោះដល់អ្នក ។ អនាថបិណ្ឌិក គហបតិឆ្លើយថា ម្នាលគហបតិ កុំចុះខ្ញុំមានវត្ថុសម្រាប់ចាយវាយធ្វើភត្តដើម្បី សង្ឃមានព្រះពុទ្ធជាប្រធានហើយ ។

អ្នកនិគមក្រុងរាជគ្រឹះ បានឮដំណឹងច្បាស់ថា អនាថបិណ្ឌិកគហបតិបាននិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ វេលានោះ អ្នកនិគមក្រុងរាជគ្រឹះបាននិយាយពាក្យនេះទៅនឹងអនាថបិណ្ឌិកគហបតិថា បពិត្រគហបតិ ឮថា អ្នកបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ច ក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តកិច្ចដើម្បីព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយវត្ថុសម្រាប់ចាយវាយឯណា ម្នាលគហបតិខ្ញុំឱ្យវត្ថុសម្រាប់ចាយ វាយនោះដល់អ្នក ។ អនាថបិណ្ឌិកគហបតិឆ្លើយថា នែអ្នក កុំចុះ ខ្ញុំមានវត្ថុ សម្រាប់ចាយវាយ ធ្វើភត្តសម្រាប់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយ ។

ព្រះបាទពិម្ពិសារមាគធសេនិយរាជជ្រាបច្បាស់ថាឮថា អនាថបិណ្ឌិកគហបតិ  បាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក។ ឯព្រះបាទពិម្ពិសារមាគធសេនិយរាជ ទ្រង់មានបន្ទូលនេះទៅនឹងអនាថបិណ្ឌិកគហបតិថា ម្នាលគហបតិ ឮថា អ្នកបាននិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈនឹងធ្វើភត្តដើម្បីព្រះសង្ឃមានព្រះ ពុទ្ធជាប្រធាន ដោយវត្ថុសម្រាប់ចាយវាយឯណា យើងនឹងឱ្យវត្ថុសម្រាប់ចាយ វាយនោះដល់អ្នក។    អនាថបិណ្ឌិកគហបតិក្រាបទូលថា   បពិត្រព្រះសម្មតិទេព ពុំបាច់ទេ     ខ្ញុំព្រះអង្គមានវត្ថុសម្រាប់ចាយវាយធ្វើភត្ត ដើម្បីព្រះសង្ឃមានព្រះពុទ្ធជាប្រធានហើយ។

គ្រានោះ អនាថបិណ្ឌិកគហបតិ លុះកន្លងរាត្រីនោះទៅ ក៏ឱ្យជនតាក់តែង ខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងលំនៅរបស់រាជគហសេដ្ឋី ហើយឱ្យជនក្រាប បង្គំទូលភត្តកាលចំពោះព្រះមានបុណ្យថា បពិត្រព្រះអង្គដ៏ចំរើនកាលគួរហើយ ភត្តក៏សម្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់និងបាតចីវរ ក្នុង បុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់រាជគហសេដ្ឋី លុះចូលទៅដល់ហើយក៏គង់លើអាសនៈ ដែលបុគ្គលក្រាលថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ លំដាប់ នោះអនាថបិណ្ឌិកគហបតិបានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែកលែងទទួល

ទៀត លុះព្រះមានព្រះភាគទ្រង់សោយ ស្រេចលែងលូកព្រះហស្តទៅក្នុងបាត្រ

ហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ អនាថបិណ្ឌិកគហបតិលុះអង្គុយក្នុងទីដ៏សម

គួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថាបពិត្រព្រះ

អង្គដ៏ចំរើន សូមព្រះមានព្រះភាគព្រមទាំង ភិក្ខុ សង្ឃ ទទួលនិមន្តគង់ចាំវស្សា

ក្នុងក្រុងសាវត្ថីរបស់ខ្ញុំព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតិ

ព្រះតថាគតទាំងឡាយរមែងត្រេកអរ ចំពោះក្នុងលំនៅ ដ៏ស្ងាត់ តែម្យ៉ាង ។

អនាថបិណ្ឌិកគហបតិក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គដឹង

ច្បាស់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងច្បាស់ហើយ ។ គ្រានោះ ព្រះមាន

ព្រះភាគទ្រង់ពន្យល់អនាថបិណ្ឌិកគហបតិឱ្យឃើញព្រម ឱ្យកាន់យកព្រម ឱ្យ

ឧស្សាហ៍ព្រម ឱ្យរីករាយព្រម ដោយធម្មីកថា ហើយព្រះអង្គក្រោកចាក

អាសនៈទ្រង់ពុទ្ធដំណើរចៀសចេញទៅ ។

សម័យនោះឯង អនាថបិណ្ឌិកគហបតិ ជាបុគ្គលមានមិត្តច្រើន មាន

សម្លាញ់ច្រើន មានវាចាគួរឱ្យអ្នកផងកាន់យក ។ ទើបអនាថបិណ្ឌិកគហបតិ

ពិចារណា នូវកិច្ចដែលគួរធ្វើនោះ ក្នុងក្រុងរាជគ្រឹះ រួចស្រេចក៏ត្រឡប់មក

ក្រុងសាវត្ថីវិញ។ លុះដល់ពាក់កណ្ដាលផ្លូវ អនាថបិណ្ឌិកគហបតិបង្គាប់

មនុស្សទាំងឡាយថា ម្នាលអ្នកទាំងឡាយ ចូរអ្នករាល់គ្នាធ្វើអារាម សាង

វិហារ និងផ្ដើមធ្វើនូវទាន ឥឡូវ នេះព្រះពុទ្ធត្រាស់ហើយក្នុងលោក ឯព្រះអង្គ

នោះសោត ខ្ញុំក៏បាននិមន្តហើយ ព្រះអង្គនឹងទ្រង់ពុទ្ធដំណើរមកតាមផ្លូវនេះ។

គ្រានោះ ពួកមនុស្សដែលអនាថបិណ្ឌិកគហបតិបញ្ជូនទៅនោះ ក៏បានធ្វើ

អារាម សាងវិហារ នឹងផ្ដើមធ្វើនូវទាន ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ

ទៅដល់ក្រុងសាវត្ថីហើយក៏គយគន់មើល(កន្លែង) ក្នុងក្រុងសាវត្ថីគ្រប់អន្លើ

ដោយគិតថាព្រះមានព្រះភាគសមនឹងគង់ក្នុងទីណាហ្ន៎ ទីណាមិនជិតពេក មិន

ឆ្ងាយពេក អំពីស្រុក ល្មមទៅល្មមមកបាន ល្មមពួកមនុស្ស ដែលត្រូវការ

ដោយប្រយោជន៍ងាយនឹងទៅមក ជាទីមិនច្រឡូកច្រឡំក្នុងវេលាថ្ងៃ មាន

សម្លេងតិច ឥតមានសម្លេងគឹកកងជាទីប្រាសចាកខ្យល់បក់មកអំពីសរីរៈ នៃ

ជន គួរជាទីធ្វើការសម្ងាត់នៃមនុស្ស និងជាទីគួរដល់វិវេកក្នុងវេលាយប់ ។

អនាថបិណ្ឌិកគហបតិ បានឃើញឧទ្យានរបស់រាជកុមារឈ្មោះ**ជេត** ជាទីមិន

ឆ្ងាយពេក មិនជិតពេកអំពីស្រុក ល្មមទៅមកបាន ល្មមពួកមនុស្សដែលត្រូវ

ការដោយ ប្រយោជន៍ងាយទៅមកបាន មិនច្រឡូកច្រឡំក្នុងវេលាថ្ងៃ មាន

សម្លេងតិច ឥតមានសម្លេងគឹកកងជាទីប្រាសចាកខ្យល់បក់មកអំពីសរីរៈនៃ

មនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ លុះ

ឃើញហើយក៏ចូលទៅរកព្រះរាជកុមារឈ្មោះជេត លុះចូលទៅដល់ហើយ

បានពោលពាក្យនេះ នឹងព្រះរាជកុមារឈ្មោះជេតថា បពិត្រព្រះអយ្យបុត្រ

សូមព្រះអង្គប្រទានឧទ្យានមកខ្ញុំ ព្រះអង្គដើម្បីនឹងធ្វើអារាម ។ ជេតរាជកុមារ

ឆ្លើយថា ម្នាលគហបតិ អារាមខ្ញុំឱ្យ (អ្នកទទេ) មិនបានទេ លុះតែ(អ្នកឱ្យ

ថ្លៃ) គឺក្រាលដោយកោដិនៃកហាបណៈ(ទើបឱ្យបាន) ។ អនាថបិណ្ឌិកគហបតិ

ឆ្លើយថា បពិត្រព្រះអយ្យបុត្រ អារាមខ្ញុំព្រះអង្គមុខជានឹងយកហើយ ។ ជេតរាជកុមារឆ្លើយថា ម្នាលគហបតិអ្នកកុំអាលយកអារាម (ចាំយើងសួរពួកមហាមាត្រអ្នកវិនិច្ឆ័យសេចក្ដីសិន) ។ ជេតរាជកុមារ និងអនាថបិណ្ឌិកគហបតិក៏សួរពួកមហាមាត្រអ្នកវិនិច្ឆ័យសេចក្ដី អារាមគួរឱ្យអនាថបិណ្ឌិកគហបតិយក ឬមិនឱ្យយកទេ ។ ពួកមហាមាត្រពោលយ៉ាងនេះថា បពិត្រព្រះអយ្យ-បុត្រ ព្រះអង្គបានកាត់ថ្លៃអារាមចំនួនប៉ុន្មាន ក៏ឱ្យអនាថបិណ្ឌិក គហបតិទទួលយក ដោយថ្លៃប៉ុណ្ណោះចុះ ។ លំដាប់នោះអនាថបិណ្ឌិកគហបតិឱ្យ គេផ្ទុកប្រាក់ដោយរទេះទាំងឡាយ ហើយឱ្យក្រាលតំរៀបដោយកោដិនៃកហាបណៈក្នុងព្រៃរបស់ជេតរាជកុមារ ។ ប្រាក់ដែលជញ្ជូនយកមកតែម្ដងប៉ុណ្ណោះ មិនគ្រាន់

ត្រង់ទីឱកាសបន្តិចជុំវិញខ្លោងទ្វារ ។ ឯអនាថបិណ្ឌិកគហបតិក៏បានបង្គាប់ ពួកមនុស្សថា នែនាយរាល់គ្នា ចូរអ្នកទៅនាំយកប្រាក់មកទៀត យើងនឹងក្រាលត្រង់ទីឱកាសនេះ ។ គ្រានោះ ជេតរាជកុមារមានសេចក្តីត្រិះរិះដូច្នេះថា គហបតិនេះចំណាយប្រាក់ច្រើនដល់ម្ល៉េះ ចំពោះកិច្ចណា កិច្ចនោះមិនមែនជារបស់ថោក ទាបទេ ។ វេលានោះ ជេតរាជកុមារពោលនូវពាក្យនេះ នឹងអនាថបិណ្ឌិកគហបតិថា ណ្ហើយគហបតិ អ្នកកុំឱ្យក្រាលទីឱកាសនោះឡើយ អ្នកចូរឱ្យទីឱកាសនោះដល់ខ្ញុំ ទាននោះនឹងមានដល់ខ្ញុំ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ បានថ្វាយទីឱកាស នោះដល់ជេតរាជកុមារដោយគិតថា ជេតរាជកុមារនេះ ជាមនុស្សល្បីល្បាញ មានមនុស្សស្គាល់( ច្រើន ) មានឫទ្ធិច្រើន ឯ

សេចក្តីជ្រះថ្លាក្នុងធម្មវិន័យនេះ(នឹងមាន) ដល់ពួកមនុស្សដែលគេស្គាល់ មាន

សភាពយ៉ាងនេះ ។ គ្រានោះ ជេតរាជកុមារបាន កសាងខ្លោងទ្វារក្នុងទីឱកាស

នោះ ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ឱ្យគេធ្វើវិហារ ឱ្យគេធ្វើបរិវេណ

ឱ្យធ្វើបន្ទប់ ឱ្យធ្វើឧបដ្ឋានសាលា ឱ្យធ្វើរោងភ្លើង ឱ្យធ្វើ កប្បិយកុដិ ឱ្យធ្វើវច្ចកុដិ ឱ្យធ្វើទីចង្ក្រម ឱ្យធ្វើសាលាសម្រាប់ចង្ក្រម ឱ្យធ្វើសាលា ទៀបរោងភ្លើង

ឱ្យធ្វើស្រះបោក្ខរណី ឱ្យធ្វើបណ្តុបក្នុងវត្តជេតវ័ន ។

# អានិសង្សបោសសំអាតទីសេនាសនៈសង្ឃ

បានឮថា សម័យមួយ ព្រះអនុរុទ្ធដ៏មានអាយុ បាននិមន្តទៅក្រុងកបិល-វត្ថុ ព្រមដោយពួកភិក្ខុទាំងឡាយ ៥០០រូប ។ គ្រានោះពួកញាតិរបស់លោក ដឹងដំណឹងថា ព្រះថេរៈនិមន្តមក ទើបនាំគ្នាទៅសំណាក់របស់ព្រះថេរៈ មិនបានទៅតែព្រះនាងរោហិណីដែលជាប្អូនរបស់ព្រះថេរៈ ។ ព្រះថេរៈមានថេរៈដីកាសួរពួកញាតិថា "ព្រះនាងរោហិណីនៅឯណា ?"

ពួកញាតិ : បពិត្រលោកម្ចាស់នៅក្នុងដំណាក់ ។

ព្រះថេរៈ : ហេតុអ្វី? ទើបនាងមិនមក ។

ពួកញាតិ : បពិត្រលោកម្ចាស់ ព្រះនាងមិនយាងមកព្រោះថា ព្រះនាងខ្មាស់ ដោយសាររោគសើស្បែក ដែលកើតលើខ្លួនព្រះនាង ។

ព្រះថេរៈពោលថា "អ្នកទាំងឡាយចូរទៅយាងព្រះនាងមកចុះ" ឱ្យពួកញាតិទៅយាងព្រះនាងមកហើយ ទើបពោលយ៉ាងនេះនឹងព្រះនាងជាប្អូនដែលមក

ដល់ហើយនោះថា "រោហិណី ហេតុអ្វី? ទើបនាងមិនមក" ។

ព្រះនាងរោហិណី : បពិត្រលោកម្ចាស់ដ៏ចំរើនរោគសើស្បែកកើតឡើង

ពេញសរីរៈរបស់ខ្ញុំព្រះករុណា ហេតុនោះហើយទើបខ្ញុំព្រះករុណាមិនមក ។

ព្រះថេរៈ : ក៏ការដែលអ្នកធ្វើបុណ្យមិនគួរឬ?

ព្រះនាងរោហិណី : នឹងធ្វើអ្វីទៅលោកម្ចាស់ ?

ព្រះថេរៈ : ចូរឱ្យគេសាងសាលាឆាន់ ។

ព្រះនាងរោហិណី : សាងសាលាឆាន់នឹងយកអ្វីទៅធ្វើ ?

ព្រះថេរៈ : ក៏គ្រឿងប្រដាប់របស់នាងមិនមានឬ ?

ព្រះនាងរោហិណី : បពិត្រលោកម្ចាស់គ្រឿងប្រដាប់ខ្ញុំម្ចាស់មាន ។

ព្រះថេរៈ : (គ្រឿងប្រដាប់នោះមាន) តម្លៃប៉ុន្មាន ?

ព្រះនាងរោហិណី : បពិត្រលោកម្ចាស់មានតម្លៃ១ម៉ឺន (កហាបណៈ) ។

ព្រះថេរៈ : ប្រសិនបើនឹងធ្វើ ចូរចាយវាយដោយគ្រឿងប្រដាប់នោះឱ្យ

កសាងសាលាឆាន់ចុះ ។

ព្រះនាងរោហិណី : បពិត្រលោកម្ចាស់ អ្នកណាជាអ្នកទទួលភារៈធ្វើ ។

ព្រះថេរៈក្រឡេកមើលពួកញាតិដែលឈរនៅក្នុងទីជិតហើយពោលថា

ចូរជាភារៈរបស់ពួកអ្នកទាំងឡាយ ។

ពួកញាតិ : បពិត្រលោកម្ចាស់ លោកម្ចាស់នឹងធ្វើអ្វីឬ ?

ព្រះថេរៈ : អាត្មាភាពនឹងនៅក្នុងទីនេះដូចគ្នា បើសិនជាធ្វើនោះពួកអ្នក

ចូរនាំយកទព្វសម្ភារៈមកដើម្បីសាលាឆាន់នេះ ។

ពួកញាតិនោះ ទទួលថា "ព្រះករុណាលោកម្ចាស់" ទើបនាំយកសម្ភារៈមក ។

ព្រះថេរៈ : កាលនឹងចាត់ចែងធ្វើសាលាឆាន់ ទើបពោលនឹងព្រះនាង

រោហិណីថា នាងចូរឱ្យគេធ្វើសាលាឆាន់ពីរជាន់ ចាប់តាំងអំពីកាលដែលឱ្យគេ

ធ្វើជាន់ខាងលើរៀបរយស្រេចហើយ ចូរបោសសំអាតផ្ទៃនៃទីផ្លាសាលាជាន់

ខាងក្រោម ហើយចូរក្រាលអាសនៈទុកឱ្យស្មើៗគ្នា ចូររៀបចំទឹកទុកសម្រាប់

ឆាន់ឱ្យស្មើៗគ្នា ។

ព្រះនាងរោហិណី ទទួលដោយពាក្យថា ព្រះករុណាលោកម្ចាស់ហើយ ចាត់ចែងចំណាយដោយគ្រឿងប្រដាប់អលង្ការ ឱ្យគេធ្វើសាលាឆាន់ពីរជាន់ ចាប់តាំង អំពីឱ្យគេធ្វើសាលាឆាន់រួចហើយនោះ ព្រះនាងបានធ្វើកិច្ចមានការ បោសសំអាត ផ្ទៃនៃសាលាជាន់ខាងក្រោម ជាដើមញយៗ ។ ពួកភិក្ខុក៏អង្គុយ ស្មើគ្នា ។ លំដាប់នោះកាលព្រះនាងបោសសំអាតសាលាឆាន់ហើយនោះ ។ រោគ សើស្បែកនោះក៏ស្រាប់តែរាបអស់ទៅ ។ កាលដែលធ្វើសាលាឆាន់រួចសព្វគ្រប់ ហើយព្រះនាងក៏និមន្តភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធានហើយបានថ្វាយ នូវខាទនីយៈ និងភោជនីយាហារដ៏ប្រណីតដល់ភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធ ជាប្រធានដែលនិមន្តគង់ពេញត្រៀបត្រាក្នុងសាលាឆាន់ ។ ព្រះសាស្តាទ្រង់ធ្វើ ភត្តកិច្ចស្រេចហើយ ទ្រង់ត្រាស់សួរថា "នេះជាទានរបស់អ្នកណា" ។

ព្រះអនុរុទ្ធ : បពិត្រព្រះអង្គដ៏ចម្រើន ( ជាទានរបស់) ព្រះនាងរោហិណី

ជាប្អូនរបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តា : ចុះនាងទៅណាហើយ ?

ព្រះអនុរុទ្ធ : បពិត្រព្រះអង្គដ៏ចម្រើន (នាង) នៅក្នុងដំណាក់ ។

ព្រះសាស្តា : ពួកអ្នកចូរទៅហៅនាងមក ។

ព្រះនាងមិនចង់មក ។ ពេលនោះព្រះសាស្តាត្រាស់ឱ្យហៅព្រះនាងនោះ

ទាល់តែមក ក៏ឯព្រះសាស្តាទ្រង់ត្រាស់នឹងព្រះនាងដែលមកថ្វាយបង្គំហើយ

អង្គុយក្នុងទីដ៏សមគួរថា "រោហិណី ហេតុអ្វីទើបនាងមិនមក ?"

ព្រះនាងរោហិណី : បពិទ្រព្រះអង្គដ៏ចម្រើន រោគសើស្បែកកើតឡើង

ពាសពេញសរីរៈរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គខ្មាស់អៀនដោយសាររោគនោះ

ទើបខ្ញុំព្រះអង្គមិនមក ។

ព្រះសាស្តា : តើនាងដឹងទេថារោគនោះអាស្រ័យកម្មអ្វីទើបកើតឡើង?

ព្រះនាងរោហិណី : បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹងទេ

ព្រះសាស្ដា : រោគនោះ (កើតឡើង) អាស្រ័យសេចក្ដីក្រោធរបស់នាង ទើបកើតឡើង ។

ព្រះនាងរោហិណី : បពិត្រព្រះអង្គដ៏ចម្រើនចុះខ្ញុំព្រះអង្គធ្វើកម្មអ្វីទុក?

## បុព្វកម្មរបស់ព្រះនាងរោហិណី

លំដាប់នោះ ព្រះសាស្ដាទ្រង់នាំអតីតនិទានមក (ត្រាស់ប្រាប់ដល់ព្រះនាងរោហិណី) ថា :

ក្នុងអតីតកាល ព្រះអគ្គមហេសីរបស់ព្រះចៅក្រុងពារាណសី បានចងអាឃាតព្យាបាទក្នុងស្រីជាអ្នករាំរបាំរបស់ព្រះរាជាមួយអង្គ ។ (អគ្គមហេសីនោះ) ត្រិះរិះថា "យើងនឹងធ្វើឱ្យស្រីនោះកើតទុក្ខ" ហើយឱ្យគេនាំយកខ្ទេយ៉ាងច្រើនមក បញ្ជាឱ្យគេហៅស្រីរបាំនោះមកកាន់សំណាក់របស់ខ្លួន ហើយឱ្យលាបកម្ទេចខ្ទេនឹងខ្ទើយ ដាក់លើកន្ទេលដេក ដាក់លើសំពត់ដណ្ដប់ និងដាក់លើគ្រប់វត្ថុប្រើប្រាស់ មានសំពត់ក្រាលដេកជាដើមរបស់ស្រីរបាំនោះ ដោយ

ពេលដែលនាងមិនដឹងខ្លួន ។ បាចរោយពេញទាំងខ្លួនរបស់នាង ហាក់ដូចជាធ្វើល្បែងសើចលេង មួយរំពេចនោះឯង សរីរៈរបស់ស្រីនោះបានពុះពងឡើងជាដុំប៉ោងតូចធំ ។ នាងអេះក្រញាំ( លើស្បែកខ្លួនឯង) ហើយក៏ទៅដេកលើទីដេក ( របស់នាង) ។ កាលនាងត្រូវកំទេចខ្ទៃរោល( ដែលគេដាក់លើ) ទីដេកនោះ ( ទុក្ខ) វេទនាដ៏ក្រៃលែងបានកើតមានហើយ( ដល់នាង) ។

ព្រះអគ្គមហេសីក្នុងកាលនោះ បានមកជាព្រះនាងរោហិណី( នេះឯង) ។

ព្រះសាស្តាកាលដែលទ្រង់សំដែងអតីតនិទាននេះមក ហើយត្រាស់ថា :

"រោហិណី ក៏កម្មនោះដែលនាងបានធ្វើហើយក្នុងកាលនោះ សេចក្តីក្រោធក្តី សេចក្តីឫស្យាក្តី ទោះបីមានប្រមាណតិចតួច ក៏មិនគួរធ្វើឡើយ" ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា:

**កោធំ ជហេ វិប្បជហេយ្យ មានំ**

**សញ្ញោជនំ សព្វមតិក្កមេយ្យ**

**តន្នាមរូបស្មិ មសជ្ជមានំ**

**អកិញ្ចនំ នានុបតន្តិ ទុក្ខា ។**

បុគ្គល គួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ

គួរកន្លងសញ្ញោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយ

តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ ក្នុងនាមនិងរូប មិន

មានកិលេស គ្រឿងកង្វល់ឡើយ ។

ក្នុងកាលជាទីបញ្ចប់នៃព្រះធម៌ទេសនា ជនមានប្រមាណច្រើនបានបន្លុះហើយ នូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ សូម្បីព្រះនាងរោហិណី ក៏តាំងនៅក្នុងសោតាបត្តិផល ។ សរីរៈរបស់ព្រះនាង កើតមានពណ៌សម្បុរដូចមាស កើតក្នុងខណៈនោះឯង ។ ព្រះនាងចុតិអំពីអត្តភាពនោះហើយ កើតក្នុងចន្លោះព្រំប្រទល់ នៃកន្លែងរបស់ទេវបុត្របួនអង្គ ក្នុងឋានតាវតឹង្ស ជាអ្នកមានមុខស្រស់ថ្លា ដល់ព្រមដោយរូបសម្បត្តិល្អ

ស្អាតក្រៃលែង ទេវបុត្រទាំងបួនអង្គឃើញនាងហើយ ក៏កើតសេចក្តីស្រឡាញ់ពេញចិត្ត ហើយក៏កើតវិវាទទាស់ទែងគ្នាថា "នាងកើតក្នុងដែនរបស់យើង នាងកើតក្នុងដែនរបស់យើង" ទៅកាន់សំណាក់របស់សក្កទេវរាជ ក្រាបទូលថា "បពិត្រសក្កទេវរាជ (ជាស្តេចនៃទេវតា) ខ្ញុំព្រះអង្គទាំងបួនអ្នក កើតក្តីវិវាទឡើង ព្រោះអាស្រ័យទេពធីតានេះ សូមព្រះអង្គទ្រង់វិនិច្ឆ័យក្តីនេះ" ។ សូម្បីសក្កទេវរាជ គ្រាន់តែបានឃើញព្រះនាងភ្លាមក៏កើតសេចក្តីស្រឡាញ់ភ្លាម ត្រាស់យ៉ាងនេះថា "តាំងអំពីពួកលោកឃើញទេពធីតានេះហើយ ចិត្តអស់លោកតែងកើតឡើងដូចម្តេច ?"

លំដាប់នោះ ទេវបុត្រមួយអង្គក្រាបទូលថា "ចិត្តរបស់ខ្ញុំព្រះអង្គកើតឡើងដូចស្គរ (ដែលគេវាយ) ក្នុងពេលសង្គ្រាមមិនអាចនឹងស្គាល់បានឡើយ" ។ អង្គទីពីរ : ចិត្តរបស់ខ្ញុំព្រះអង្គ (កើតឡើង) ដូចទឹកជ្រោះហូរធ្លាក់ពីលើភ្នំរមែងប្រព្រឹត្តិទៅឆាប់រហ័សភ្លាមតែម្តង ។

អង្គទីបី : តាំងតែអំពីខ្ញុំព្រះអង្គឃើញនាងនេះហើយ ភ្នែកទាំងពីររបស់ខ្ញុំព្រះអង្គក៏ល្មៀនចេញ ដូចភ្នែកក្ដាម ។

អង្គទីបួន : ចិត្តរបស់ខ្ញុំព្រះអង្គ ដូចទង់ដែលគេដាក់លើកំពូលចេតីយ៍ មិនអាចនឹងនៅស្ងៀមបានឡើយ ។

គ្រានោះ សក្កទេវរាជ ពោលនឹងទេវបុត្រទាំងបួននោះថា " ទេវបុត្រទាំងឡាយ ចិត្តរបស់ពួកលោក នៅល្មមឃុំគ្រងបានទេ ចំណែកឯយើងវិញពេលបានឃើញទេពធីតានេះហើយ យើងនឹងស្លាប់បើមិនបាននាងទេ បើបាននាងទើបយើងរស់នៅបាន" ។

ពួកទេវបុត្រទើបក្រាបទូលថា "បពិត្រមហារាជ ពួកខ្ញុំព្រះអង្គមិនត្រូវការដោយសេចក្ដីស្លាប់របស់ព្រះអង្គទេ" ហើយនាំគ្នាលះ ទេពធីតានោះថ្វាយដល់សក្កទេវរាជ ក៏នាំគ្នាចេញទៅ ។ ទេពធីតានោះ បានជាទីស្រឡាញ់គាប់ព្រះហឫទ័យរបស់សក្កទេវរាជ ។ កាលបើនាងក្រាបទូលថា "ខ្ញុំព្រះអង្គនឹងទៅ

កាន់កន្លែងកំសាន្តឯនោះ” សក្កទេវរាជ ក៏មិនអាចនឹងបដិសេធពាក្យរបស់នាង

បានឡើយ ដូច្នេះឯង ។

ចប់រឿងព្រះនាងរោហិណី

# រឿងអជគរៈប្រេត

សេចក្ដីផ្ដើម

ព្រះសាស្ដា កាលទ្រង់គង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអជគរៈប្រេត ត្រាស់ព្រះធម្មទេសនា យ៉ាងនេះថា "**អថ បាបានិ កម្មានិ** "ជាដើម ។

## ព្រះមហាមោគ្គល្លានឃើញប្រេតត្រូវភ្លើងឆេះ

សេចក្ដីពិស្ដារថា ក្នុងសម័យមួយ ព្រះមហាមោគ្គល្លានត្ថេរ និងព្រះមហាលក្ខណត្ថេរ ចុះអំពីកំពូលភ្នំគិជ្ឈកូដ បានឃើញសត្វឈ្មោះអជគរប្រេតប្រមាណ២៥យោជន៏ ដោយចក្ខុទិព្វ ។ អណ្ដាតភ្លើងឆេះឡើងអំពីក្បាលនៃប្រេតនោះ រាលដល់កន្ទុយ ឆេះឡើងអំពីកន្ទុយ រាលដល់ក្បាល ។ ឆេះឡើងអំពីក្បាលនិងកន្ទុយទៅទល់គ្នាត្រង់កណ្ដាលខ្លួន ។

# ព្រះមហាមោគ្គល្លានត្ថេរពោលការឃើញប្រេតឱ្យព្រះលក្ខណត្ថេរស្តាប់

ព្រះមហាមោគ្គល្លានត្ថេរ ពេលឃើញប្រេតនោះហើយ ទើបញញឹម, កាលព្រះលក្ខណត្ថេរសួរហេតុនៃការញញឹមហើយ ក៏ឆ្លើយថា "អ្នកមានអាយុ កាលនេះ មិនមែនជាកាលគួរព្យាករណ៍បញ្ហានេះទេលោកចាំសួរខ្ញុំក្នុងសំណាក់នៃព្រះមានព្រះភាគចុះ" និមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ,ក្នុងកាលទៅកាន់សំ-ណាក់របស់ព្រះសាស្តា ព្រះលក្ខណត្ថេរសួរហើយ ទើបឆ្លើយថា" អ្នកមានអាយុ ខ្ញុំបានឃើញប្រេតមួយរូបក្នុងទីនោះ ។ អត្តភាពរបស់សត្វនោះ មានរូបយ៉ាងនេះ, ខ្ញុំពេលដែលបានឃើញហើយ បានធ្វើការញញឹមឱ្យប្រាកដ ក៏ដោយការគិតថា អត្តភាពបែបនេះ យើងមិនធ្លាប់ឃើញឡើយ ។

# ព្រះសាស្តា ក៏ធ្លាប់ទ្រង់ឃើញប្រេតនោះ

ព្រះសាស្តា កាលនឹងត្រាស់ពាក្យជាដើមថា "ភិក្ខុទាំងឡាយ សាវ័ករបស់តថាគតជាអ្នកមានចក្ខុហើយហ្ន៎" ព្រះសាស្តាទ្រង់ទទួលស្គាល់ ថេរដីការបស់ព្រះមហាមោគ្គល្លានត្ថេរហើយ ទើបត្រាស់ថា " ភិក្ខុទាំងឡាយ ប្រេតនោះ តថាគតក៏បានឃើញហើយ នៅឯពោធិមណ្ឌលស្ថានដូចគ្នា, ប៉ុន្តែតថាគតមិនពោល ព្រោះតថាគតត្រិះរិះថា, ក៏ឯជនទាំងឡាយណា មិនជឿពាក្យរបស់តថាគត ការមិនជឿនោះរបស់អ្នកទាំងនោះ មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ឡើយ តែពេលនេះ តថាគតបានមោគ្គល្លានជាសាក្សីហើយទើបពោលបាន។

កាលដែលពួកភិក្ខុទាំងឡាយ ទូលសួរអំពីបុព្វកម្មរបស់ប្រេតនោះហើយ ទើបទ្រង់ព្យាករណ៏(ដូចតទៅនេះ) ថា :

# បុព្វកម្មរបស់អជគរប្រេត

បានឮមកថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ សេដ្ឋីឈ្មោះថាសុមង្គល បានក្រាលលើផ្ទៃដីដោយឥដ្ឋមាស ឱ្យគេសាងវិហារក្នុងទីប្រមាណ២០ឧសភៈដោយទ្រព្យប្រមាណប៉ុណ្ណោះទៀតដូចគ្នា ។ថ្ងៃមួយ លោកសេដ្ឋីទៅកាន់សំណាក់ព្រះមានព្រះភាគតាំងពីព្រលឹម ឃើញចោរម្នាក់ដេកដោយយកសំពត់កាសាវៈ មកហ៊ុមព័ទ្ធខ្លួនរហូតដល់ក្បាល ទាំងមានជើងប្រឡាក់ទៅដោយភក់ នៅក្នុងសាលាមួយខ្នង ជិតទ្វារព្រះនគរ ហើយពោលថា "គេម្នាក់នេះ មានជើងប្រឡាក់សុទ្ធតែភក់ដូចជាមនុស្សដែលដើរឥតគោលដៅក្នុងពេលយប់ហើយមកដេក ។

# កម្មអាក្រក់ឱ្យផលអាក្រក់

ចោរបើកមុខឃើញសេដ្ឋីហើយ គិតក្នុងចិត្តថា" ចាំមើលចុះ យើងនឹងធ្វើកម្មដែលគួរធ្វើដល់វាហើយ" ដូច្នេះហើយ ក៏ចងអាឃាតព្យាបាទទុកក្នុងចិត្ត បានដុតស្រែរបស់សេដ្ឋី៧ដង កាត់ជើងគោទាំងឡាយរបស់សេដ្ឋី៧ដង ដុតផ្ទះ៧ដង គេមិនអាចបញ្ឈប់គុំនុំព្យាបាទនោះបាន ទោះបីដោយការធ្វើកម្មមានប្រមាណប៉ុណ្ណោះ ទើបទៅទំនាក់ទំនងធ្វើជាស្និទ្ធស្នាលនឹងអ្នកបម្រើរបស់សេដ្ឋីនោះហើយ សួរថា, "តើអ្វីជាទីស្រលាញ់របស់លោកសេដ្ឋីរបស់អ្នក ? ស្តាប់បានថា វត្ថុដែលជាទីស្រលាញ់ដ៏ក្រៃលែងរបស់សេដ្ឋី ដទៃក្រៅអំពីព្រះគន្ធកុដិមិនមាន" គិតថា "អើ,(បើដូច្នោះ) យើងនឹងដុតព្រះគន្ធកុដិ ដើម្បីញ៉ាំងការឈឺចិត្តរបស់យើងឱ្យបាត់ក្តៅក្រហាយ" ក្នុងកាលដែលព្រះសាស្តាទ្រង់យាងទៅបិណ្ឌបាត ទើប(ចោរនោះ)វាយបំបែកឆ្នាំងទឹកសម្រាប់បរិភោគ និង ឆ្នាំងទឹកសម្រាប់ប្រើប្រាស់ ហើយក៏បានដុតព្រះគន្ធកុដិ(ឱ្យឆេះអស់ទៅ)។

សេដ្ឋីបានជ្រាបថា "ព្រះគន្ធកុដិត្រូវភ្លើងឆេះ "ដើរមកហើយក្នុងពេលដែលព្រះ គន្ធកុដិត្រូវភ្លើងឆេះខ្ទេចខ្ទីអស់ទើបមកដល់ សំឡឹងមើលព្រះគន្ធកុដិដែលត្រូវភ្លើងឆេះ មិនបានសំដែងអាការៈខូចចិត្តឬអាក់អន់ចិត្តសូម្បីតែប៉ុនចុងនៃរោមសត្វឡើយ លើកដៃខាងឆ្វេងមកទះដោយដៃខាងស្តាំយ៉ាងខ្លាំង (ពេញទំហឹង) ។

គ្រានោះឯង ពួកជនទាំងឡាយដែលឈរនៅទីជិត(លោកសេដ្ឋីនោះ) សួរលោកសេដ្ឋីថា" លោកម្ចាស់ហេតុអ្វីទើបលោកទះដៃ ក្នុងពេលព្រះគន្ធកុដិដែលលោកចំណាយទ្រព្យអស់ប្រមាណប៉ុណ្ណេះសាងទុកហើយ ត្រូវភ្លើងឆេះ (ដូច្នេះ)? "

សេដ្ឋីឆ្លើយថា"ពុកម៉ែទាំងឡាយ ខ្ញុំធ្វើកម្មប្រមាណប៉ុណ្ណេះ(ឈ្មោះថា) បានកប់ទ្រព្យទុកក្នុងព្រះពុទ្ធសាសនាជាទីមិនសាធារណៈ ដល់អន្តរាយទាំងឡាយមានភ្លើងជាដើម,ទើបខ្ញុំមានចិត្តត្រេកអរ ទះដៃដោយគិតថា"យើងនឹង

បានលះទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិ(ថ្វាយ)ចំពោះព្រះសាស្ដាទៀត។

លោកសេដ្ឋី លះទ្រព្យប្រមាណប៉ុណ្ណោះសាងព្រះគន្ធកុដិទៀត បានថ្វាយដល់ព្រះសាស្ដាដែលមានភិក្ខុសង្ឃពីរម៉ឺនអង្គជាបរិវារ។

ចោរឃើញកិរិយានោះហើយ គិតថា "បើយើងមិនសម្លាប់សេដ្ឋីនេះទេ នឹងមិនអាចធ្វើឱ្យគេខ្លាចរអាបានទេ ណ្ហើយចុះ, យើងនឹងសម្លាប់(សេដ្ឋីនោះ) ចោល" ដូច្នេះហើយ ទើបលាក់កាំបិតយ៉ាងមុតទុកក្នុងសំពត់ស្លៀក ដើរទៅមកៗ រង់ចាំនៅក្នុងវិហារអស់រយៈពេល៧ថ្ងៃ ក៏មិនបានឱកាស។

ចំណែកឯលោកសេដ្ឋីវិញ ថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់រយៈពេល៧ថ្ងៃ ថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបទូលថា"បពិត្រព្រះអង្គដ៏ចំរើន បុរសម្នាក់ដុតស្រែរបស់ខ្ញុំព្រះអង្គ៧ដង,កាត់ជើងគោក្នុងក្រោល៧ដង ដុតផ្ទះ៧ដង,ឥឡូវនេះសូម្បីតែព្រះគន្ធកុដិក៏ប្រហែលជាគេម្នាក់នោះដុតដែរ,

ខ្ញុំព្រះអង្គសូមចែកនូវបុណ្យកុសលដែលកើតឡើងអំពីការធ្វើទាននេះឱ្យដល់គេនោះផង"។

## កុសលកម្មរមែងឈ្នះអកុសលកម្ម

ចោរបានឮពាក្យនោះហើយ ក៏ក្រៀមក្រំកើតទុក្ខក្នុងចិត្តថា "យើងធ្វើកម្មដ៏ធ្ងន់ធ្ងរ ទោះបីដូច្នោះក៏ដោយ បុរសនេះក៏មិនបានធ្វើចិត្តឱ្យខឹងសូម្បីតែបន្តិចដល់យើងដែលជាអ្នកធ្វើខុសសោះ , (ប្រែជា) ចែករំលែកនូវបុណ្យកុសលក្នុងទាននេះដល់យើងទៀតផង, យើងមានគំនិតប្រទូស្តរាយក្នុងបុរសនេះ( មិនគួរឡើយ) សូម្បីទេវទណ្ឌត្រូវធ្លាក់លើក្បាលរបស់យើង (ក៏នៅមិនស្មើនឹងកំហុសរបស់យើងឡើយ) យើងមិនគួរឱ្យបុរសបែបនេះអត់ទោសឱ្យ(យើងទេ)" ដូច្នេះហើយ ទើបចូលទៅក្រាបចុះទៀបនឹងជើងរបស់លោកសេដ្ឋី ពោលថា, "លោកម្ចាស់ សូមលោកម្ចាស់ករុណាដល់ខ្ញុំផងចុះ", លោកសេដ្ឋីសួរថា " ហេតុអ្វីទៅហ្នឹង" ទើបរៀបរាប់ថា " បពិត្រលោកសេដ្ឋី ខ្ញុំបាន

ធ្វើកម្ម ប្រមាណប៉ុណ្ណេះៗ , សូមលោកម្ចាស់ អត់នូវទោសកំហុសនោះដល់ខ្ញុំផងចុះ ,"។

ពេលនោះ សេដ្ឋីសួរកម្មគ្រប់ៗយ៉ាងនឹងគេនោះថា "អ្នកធ្វើកម្មនេះផងនេះផងប្រមាណប៉ុណ្ណេះដល់យើងឬ ?" កាលបើគេទទួលសារភាពថា "បាទលោក ម្ចាស់ ខ្ញុំធ្វើមែន" ទើបសួរ (តទៅទៀត) ថា "យើងមិនធ្លាប់ឃើញអ្នកទេ,ហេតុអ្វីទើបអ្នកខឹងក្រោធនឹងយើងហើយបានធ្វើកម្មយ៉ាងនេះដល់យើង?"

ចោរបានរំលឹកឱ្យសេដ្ឋីរលឹកដល់ពាក្យដែលខ្លួនពោលក្នុងពេលដែលចាកចេញអំពីព្រះនគរក្នុងថ្ងៃមួយ និយាយហើយ បានប្រាប់ថា "ខ្ញុំកើតការគុំគួនឡើងព្រោះហេតុនេះឯង។"

សេដ្ឋីរលឹកឃើញដល់ភារៈ នៃពាក្យសំដីដែលខ្លួននិយាយបានហើយ ឱ្យចោរអត់ទោសឱ្យដោយពាក្យថា " អើ, ពាក្យនេះយើងនិយាយមែន, អ្នកចូរ

អត់ទោសកំហុសនោះដល់យើងផងចុះ" ហើយពោលថា " ក្រោកឡើង ចុះ យើងអត់ទោសឱ្យដល់អ្នកណា៎, អ្នកចូរទៅចុះ ។"

ចោរ : លោកម្ចាស់ បើលោកម្ចាស់អត់ទោសដល់ខ្ញុំ , ខ្ញុំព្រមទាំងបុត្រ និងភរិយា សូមធ្វើជាទាសៈ ( អ្នកបំរើ ) ក្នុងផ្ទះរបស់លោកម្ចាស់ផង ។

សេដ្ឋី : នែអ្នក កាលយើងពោលពាក្យមានប្រមាណប៉ុណ្ណេះ, អ្នកក៏បាន ធ្វើកម្មបែបនេះ, ( ដល់យើង ) យើងមិនអាចនឹងពោលពាក្យយ៉ាងណាៗជាមួយ អ្នកបានឡើយ ។ យើងមិនមានកិច្ចដោយអ្នកនឹងនៅក្នុងផ្ទះ ( របស់យើង ), យើងអត់ទោសឱ្យដល់អ្នក, អ្នកទៅចុះ ។

ចោរបានធ្វើកម្មនោះហើយ ក្នុងកាលអស់អាយុទៅ បានកើតហើយក្នុង អវិចី ឆេះក្នុងអវិចីអស់កាលដ៏យូរ ក្នុងកាលឥឡូវនេះ បានកើតជាអជគរប្រេត នៅ ទៀបជើងភ្នំគិជ្ឈកូដ ដោយវិបាក ( នៃកម្ម ) ដែលនៅសេសសល់ ។

ព្រះសាស្តា បានត្រាស់សំដែងបុព្វកម្មរបស់ប្រេតនោះយ៉ាងនេះហើយ ទើបត្រាស់ថា "ភិក្ខុទាំងឡាយ ធម្មតាបុគ្គលពាល ធ្វើកម្មដ៏លាមកហើយ រមែងមិនដឹង,តែខាងក្រោយមក ទើបក្តៅក្រហាយព្រោះកម្មដែលខ្លួនបានធ្វើហើយ ប្រៀបដូចជាភ្លើងឆេះព្រៃ ដោយខ្លួនឯង" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា :

**អថ បាបានិ កម្មានិ    ករំ ពាលោ ន ពុជ្ឈតិ**

**សេហិ កម្មេហិ ទុម្មេធោ    អគ្គិទឌ្ឍោវ តប្បតិ ។**

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

ក្នុងកាលជាទីបញ្ចប់នៃព្រះធម្មទេសនា ជនដ៏ច្រើន បានបន្លុះអរិយផល ទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះ ។

**រឿងអជគរប្រេតចប់**

# អានិសង្សបោសសំអាតទីលានពោធិព្រឹក្ស

## តិបុប្ផិយត្ថេរាបទាន

ក្នុងកាលមុន ខ្ញុំកើតជាព្រានម្រឹគនៅក្នុងព្រៃធំ បានឃើញដើមច្រនៀង (ជាពោធិព្រឹក្ស) មានពណ៌ខៀវបំព្រង ហើយខ្ញុំរោយផ្កាពទងត្រង់គល់ច្រនៀងនោះ។ កាលនោះ ខ្ញុំរើសស្លឹកស្ងួតៗ យកទៅចោលខាងក្រៅ ហើយថ្វាយបង្គំដើមច្រនៀងនោះ ដូចជាថ្វាយបង្គំព្រះសម្ពុទ្ធព្រះនាមវិបស្សីជាលោកនាយកទ្រង់ស្អាតខាងក្នុង ស្អាតខាងក្រៅ មានព្រះទ័យផុតស្រឡះចាកកិលេស មិនមានអាសវៈ ក្នុងទីចំពោះមុខ ហើយធ្វើកាលកិរិយាក្នុងទីនោះ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះដែលខ្ញុំ បានបូជាដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផល នៃការបូជាដើមពោធិព្រឹក្ស។ ក្នុងកប្បទី៣០អំពីកប្ប នេះ ខ្ញុំបានជាស្តេចចក្រពត្តិ១៣ដង ព្រះនាមសមន្តបាសាទិកៈដូចគ្នាទ្រង់មាន កម្លាំងច្រើន។ បដិសម្ភិទា៤ វិមោក្ខ៨ អភិញ្ញា៦នេះ ខ្ញុំបានធ្វើឱ្យជាក់-

ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ចប់ តិបុប្ផិយត្ថេរាបទាន

# អានិសង្សស្រោចដើមពោធិព្រឹក្ស

ពោធិសិញ្ចកត្ថេរាបទាន

មានពិធីឆ្លងព្រះមហាពោធិព្រឹក្សរបស់ព្រះមានព្រះភាគព្រះនាមវិបស្សី ក្នុងកាលនោះ ខ្ញុំជាអ្នកបួសមានចិត្តស្ងប់រម្ងាប់ ដើរចូលទៅ ជិតដើមពោធិព្រឹក្ស ។ ខ្ញុំដងទឹកត្រពាំងស្រោចដើមពោធិព្រឹក្ស ដោយគិតថា ព្រះវិបស្សីសម្ពុទ្ធ ទ្រង់រួចចាកទុក្ខហើយ និងញុំាងយើងឱ្យរួចទុក្ខផង ទ្រង់រំលត់ទុក្ខហើយ និងញុំាងយើងឱ្យរលត់ទុក្ខផង ។ ក្នុងកប្បទី៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានស្រោចស្រពដើមពោធិព្រឹក្ស ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការស្រោចស្រពពោធិព្រឹក្ស ។ កាលកប្បទី៣៣ កំពុងប្រព្រឹត្តទៅ ខ្ញុំបានជាស្តេចចក្រពត្តិ៨ដង ជាធំលើពួកជន ទ្រង់ព្រះនាមឧទកសេចនៈ ដូចគ្នា ។ បដិសម្ភិទា៤ វិមោក្ខ៨ អភិញ្ញា៦នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ ហើយទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ចប់ ពោធិសិញ្ចកត្ថេរាបទាន

# អានិសង្សបូជាព្រះពោធិព្រឹក្ស

គន្ធោទកទាយកត្ថេរាបទាន

កាលគេធ្វើពិធីឆ្លងមហាពោធិព្រឹក្សរបស់ព្រះពុទ្ធព្រះនាម **បទុមុត្តរៈ** ខ្ញុំបានយកទឹកក្រអូបមួយក្អមដ៏វិចិត្រ ហើយស្រោចទឹកក្រអូបនោះ លើដើមពោធិនោះ ។ ក្នុងកាលដែលកំពុងតែស្រោចដើមពោធិ មហាមេឃក៏បង្អុរភ្លៀងផ្គរលាន់គឹកកងយ៉ាងខ្លាំង ព្រមទាំងរន្ទះបាញ់ ក៏កើតឡើង ។ខ្ញុំក៏បានធ្វើមរណៈកាល ត្រង់កន្លែងនោះ ដោយកម្លាំងនៃរន្ទះនោះបាញ់ត្រូវ ខ្ញុំបានទៅឋិតនៅទេវលោក ហើយសំដែងគាថានេះថា ឱហ្ន៎ព្រះពុទ្ធ ឱហ្ន៎ព្រះធម៌ ឱហ្ន៎សម្បទានៃព្រះសាស្តារបស់ខ្ញុំ ឱសាកសពរបស់ខ្ញុំ ធ្លាក់ចុះហើយ ខ្ញុំបានមកត្រេកអរក្នុងទេវលោកនេះ ។ ភពជាទីនៅរបស់ខ្ញុំ មានជាន់៧ ខ្ពស់ត្រដែតត្រដឹម ពួកនាងកញ្ញាមួយសែន តែងចោមរោមខ្ញុំ សព្វៗកាល ។ ខ្ញុំមិនមានអាពាធ ខ្ញុំមិនមានសោក ខ្ញុំមិនជួបសេចក្តីក្រហល់ក្រហាយ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី

២.៨០០ ខ្ញុំបានជាស្ដេចចក្រពត្តិ គ្រប់គ្រងផែនដី បរិបូរណ៍ដោយកែវ៧ប្រការ មានកម្លាំងច្រើន។ បដិសម្ភិទា៤ វិមោក្ខ៨ អភិញ្ញា៦នេះ ខ្ញុំបានធ្វើឱ្យជាក់-ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ។

ចប់គន្ថោទកទាយកត្ថេរាបទាន

# អានិសង្សថ្វាយបង្គំស្នាមព្រះបាទ

## បទសញ្ញកត្ថេរាបទាន

ខ្ញុំបានឃើញស្នាមព្រះបាទ របស់ព្រះតិស្សសម្មាសម្ពុទ្ធ ព្រះអង្គជាព្រះ-អាទិច្ចពន្ធុទ្រង់ជាន់ទុកហើយខ្ញុំមានចិត្តត្រេកអររីករាយបានញុំាំងចិត្តឱ្យជ្រះថ្លាចំ ពោះស្នាមព្រះបាទនោះ ។ ក្នុងកប្បទី៩២អំពីកប្បនេះព្រោះហេតុដែលខ្ញុំបាននៅសេចក្ដីសំគាល់ ក្នុងស្នាមព្រះបាទក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃសេចក្ដីសំគាល់ក្នុងស្នាមនៃព្រះបាទ ។ក្នុងកប្បទី៧អំពីកប្បនេះខ្ញុំបានជាក្សត្រឈ្មោះសុមេធៈជាស្ដេចចក្រពត្តិមានកម្លាំងច្រើនបរិបូរណ៍ដោយរតនៈ៧ប្រការ ។ បដិសម្ភិទា៤ វិមោក្ខ៨ អភិញ្ញា៦នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ចប់ បទសញ្ញកត្ថេរាបទាន

# អានិសង្សយានជំនិះ

ខទិរវនិយរេវតត្ថេរាបទាន

មានស្ទឹងមួយ ឈ្មោះភាគីរសី ហូរចេញអំពីព្រៃហិមពាន្ត កាលនោះ ខ្ញុំ-កើតជានាយទូកក្នុងកំពង់មិនល្អ ជាកំពង់សម្រាប់ឆ្លងមកកាន់ត្រើយអាយ ។ ព្រះសម្ពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ បម្រុងនឹងឆ្លងខ្សែរទឹកក្នុងស្ទឹង ជាមួយនឹងភិក្ខុសង្ឃមួយសែនអង្គ ។ ខ្ញុំបានប្រ-មូលទូកជាច្រើនមក ហើយធ្វើដំបូលទូក ដែលពួកជាងឈើ តាក់តែងល្អហើយ ទៅទទួលព្រះនរាសភៈ ។ ព្រះសម្ពុទ្ធទ្រង់ស្តេចមកឡើងគង់លើទូក ព្រះសាស្តាទ្រង់ឋិតត្រង់កណ្តាលទឹកស្ទឹង ហើយត្រាស់គាថាទាំងនេះថា:

បុគ្គលណា បានចម្លងព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ ជាអ្នកមិនមានអា-សវៈ បុគ្គលនោះនឹងត្រេកអរក្នុងទេវលោក ដោយចិត្តជ្រះថ្លានោះឯង ។ វិមានមានសណ្ឋានដូចទូក ដែលបុញ្ញកម្មធ្វើល្អហើយ នឹងកើតដល់អ្នក វិមាននោះនឹង

ទ្រទ្រង់នូវដំបូល ជាវិការៈនៃផ្កាព្ធដ៏អាកាសសព្វកាល ។ក្នុងកប្បទី៥៨ បុគ្គល

នោះ នឹងបានជាស្ដេចចក្រពត្តិព្រះនាម តារណៈ ជាឥស្សរៈ លើផែនដី មាន

សមុទ្រទាំង៤ ជាទីបំផុត ទ្រង់ឈ្នះសង្គ្រាម ។ ក្នុងកប្បទី៥៧ និងបានជាស្ដេច

ព្រះចម្ពកៈ មានកម្លាំងច្រើន រុងរឿងដូចព្រះអាទិត្យកំពុងរះ ។ក្នុងកប្បទីមួយ-

សែន ព្រះសាស្ដា ព្រះនាមគោត្តម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុង

លោក ។ ស្ដេចចម្ពកៈនោះ ច្យុតចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹង

កើតជាព្រាហ្មណ៍ ឈ្មោះរេវតៈ ។ រេវតកុមារនោះ ត្រូវកុសលមូលដាស់តឿន

នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះនាមគោត្តម ។

រេវតភិក្ខុនោះ លុះបួសរួចហើយ ក្នុងកាលជាខាងក្រោយ ប្រកបស្ដេចក្ដីព្យា-

យាម ខំចម្រើនវិបស្សនា កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ

នឹងបរិនិព្វាន ។

សេចក្តីព្យាយាមរបស់ខ្ញុំគួរដើម្បីនាំមកនូវធុរៈជាទីនាំមកនូវធមិដ៏ក្សេម ចាកយោគៈ ខ្ញុំទ្រទ្រង់រាងកាយ មានក្នុងទីបំផុត គឺ**បច្ឆិមជាតិ** ក្នុងសាសនានៃព្រះសម្ពុទ្ធ។ បដិសម្ភិទា៤ វិមោក្ខ៨ អភិញ្ញា៦នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់-ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ។

ចប់ខទិរវនិយរេវតត្ថេរាបទាន

# ការបូជាពីរយ៉ាង

ឈ្មោះថា ការបូជាមានពីតយ៉ាង គឺ **អាមិស្សបូជា** និង **បដិបត្តិបូជា** ។

បណ្ដាការបូជាទាំង២យ៉ាងនោះ ការបូជាដោយគ្រឿងសក្ការៈ មានផ្កា-ឈើជាដើម និងដោយបច្ច័យ៤ ឈ្មោះថា **អាមិស្សបូជា** ។ ការបូជាដោយសេចក្ដីប្រតិបត្តិ ឈ្មោះថា បដិបត្តិបូជា ។ ក្នុងព្រះអដ្ឋកថា លោកសំដែង ថា ការធ្វើសក្ការៈគោរព រាប់អាន និងកិរិយាក្រាបថ្វាយបង្គំ ឈ្មោះថា ការបូជា ។ ដោយការកំណត់យកបុគ្គលដែលប្រសើរខ្ពង់ខ្ពស់បំផុត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវ័កទាំងឡាយ ឈ្មោះថា បុគ្គលដែលគួរបូជា ។ ពិតមែនបុគ្គលដ៏ប្រសើរទាំងឡាយ មានព្រះដ៏មានព្រះភាគជាដើមនោះ លោកហៅថា ជាបូជនេយ្យបុគ្គល ព្រោះធ្វើនូវភារៈនៃការបូជាដែលបុគ្គលបានធ្វើហើយ ក្នុងខ្លួនទោះជាតិចតួចក៏ដោយ នាំប្រយោជន៍ និងសេចក្ដីសុខមកឱ្យបាន អស់កាលដ៏យូរអង្វែង ព្រោះហេតុ ជាទក្ខិណេយ្យបុគ្គល ។

# អានិសង្សបូជាព្រះចេតីយ៍ដំកល់ព្រះសារីរិកធាតុ

រឿង កោសាតកីទេពធីតា

កាលបើព្រះបាទ **អជាសត្រូវ** ទ្រង់បាននាំយកព្រះសារីរិកធាតុ របស់ព្រះដ៏មានព្រះភាគ ទ្រង់បានបរិនិព្វានកន្លងទៅហើយ ទ្រង់បានកសាងព្រះស្តូប និង ការឆ្លងព្រះស្តូប, ឧបាសិកាអ្នកអាស្រ័យនៅក្នុងក្រុងរាជគ្រឹះម្នាក់ជម្រះសរីរៈរាងកាយតាំងពីព្រលឹមស្រាងៗ កាន់យកផ្កាវល្លិ៍នទោងព្រៃបួនទងដោយតាំងចិត្តថា អាត្មាអញនឹងបូជាព្រះចេតីយ របស់ព្រះសាស្តា ដូច្នេះ ជាអ្នក មានចិត្ត គឹកម្លាំងនៃសទ្ធា ឱ្យប្រឹងប្រែងព្រមហើយ មិនទាន់បាន ពិនិត្យមើល នូវសេចក្តីអន្តរាយតាមផ្លូវផង ក៏បានដើរ មានមុខឆ្ពោះទៅព្រះចេតីយ៍ ។

គ្រានោះ មេគោកូនខ្ចី បោលឆ្ពោះទៅ យ៉ាងលឿន ជលនាងឱ្យដល់នូវការអស់ទៅនៃជីវិតហើយ ។ នាងបានធ្វើកាលកិរិយាក្នុងទីនោះមួយរំពេចហើយ ក៏បានទៅកើតក្នុងពួកទេវតាជាន់តាវតឹង្ស បានប្រាកដហើយ ព្រមទាំង

រថ ក្នុងកណ្តាលនៃបរិវាររបស់ស្តេចសក្កទេវរាជ ដែលទ្រង់ស្តេចយាងទៅដើម្បីទ្រង់ព្រះក្រសាលក្នុងព្រះឧទ្យាន។ ស្តេចសក្កទេវរាជទ្រង់ទតព្រះនេត្រឃើញនាងហើយ កាលទ្រង់ត្រាស់សួរ ទ្រង់បានត្រាស់ហើយ នូវគាថាទាំង-ឡាយនេះ ថា ៖

**ម្នាលនាងដ៏ចំរើន អ្នកមានសំពត់លឿង មានទង់លឿង**

**ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មាន**

**អាវយវៈ លាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កា**

**ឧប្បលលឿង មានប្រាសាទនិងទីដេកលឿង**

**មានទីអង្គុយលឿង មានភោជនពណ៌លឿង**

**មានឆ័ត្រលឿង មានរថលឿង មានផ្លិតលឿង**

**ក្នុងភពជាមនុស្ស ក្នុងកាលមុន នាងបានធ្វើ**

**កម្មដូចម្តេច ? ម្នាលទេពធីតា យើងសួរហើយ**

**នាងចូរប្រាប់ចុះ, នេះគឺ ជាផលនៃកម្មអ្វី ? ។**

លំដាប់នោះ ទេពធីតានោះ កាលនឹងទ្រង់ក្រាបទូលដល់សក្កទេវរាជនោះ ទើបបានពោលគាថាទាំងនេះថាៈ

**បពិត្រព្រះអង្គដ៏ចំរើន មានវល្លិ៍នោងព្រៃ**

**ជាវល្លិ៍មានជាតិល្វីង ដែលគេមិនត្រូវការ**

**ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បានយកផ្កានោង**

**ព្រៃនោះ បូនទង ទៅបូជាព្រះចេតីយ៍**

**ឧទ្ទិសចំពោះព្រះសរីរៈ របស់ព្រះសាស្តា**

**ខ្ញុំម្ចាស់ កំពុងមានចិត្តប្រព្រឹត្តទៅ ក្នុងព្រះធាតុ**

**នៃព្រះដ៏មានព្រះភាគនោះ មិនបានក្រឡេក**

**មើលផ្លូវមេគោនោះផង, គ្រានោះ ស្រាប់តែ**

**មេគោ មកជល់ខ្ញុំម្ចាស់ ដែលមានអធ្យាស្រ័យ**

**មិនទាន់ដល់ព្រះចេតីយ៍(ស្លាប់ទៅ)បើខ្ញុំម្ចាស់**

**គប្បីសន្សំបុណ្យនោះសម្រេច, ម្ល៉េះ សមជា**

**មានសម្បត្តិដ៏លើសលប់ ជាងនេះមិនខាន**

**បពិត្រព្រះអង្គជាធំជាងទេវតា នាម មឃវៈ**

**ជា ទេវកុញ្ជរៈ ខ្ញុំម្ចាស់ បានលះបង់រាងកាយ**

**ជាមនុស្ស មកកើតជាមួយនឹងព្រះអង្គព្រោះ**

**កម្មនោះ។**

## ស្ដេចសក្កទេវរាជសំដែងធមិដល់ពួកទេវតា

ស្ដេចសក្កទេវរាជ ទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ កាលនឹងសំដែងធមិដពួកទេវតា មាន **មាតលិទេវបុត្រ** ជាប្រធាន ទើបទ្រង់បានត្រាស់នូវគាថាទាំងឡាយនេះថា:

**ម្នាលមាតលិ អ្នកចូរមើលនូវសេចក្ដីអស្ចារ្យ**

នេះជាផលនៃកម្មដ៏វិចិត្រ ទេយ្យធម៌សូម្បីតែ

មន្តិចបន្តួច ដែលបុគ្គលបានធ្វើហើយ បុណ្យ

ត្រឡប់ទៅជាមានផលច្រើន, កាលបើចិត្ត

ជ្រះថ្លាហើយ ចំពោះព្រះតថាគត ជាព្រះ

សម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ឬសាវ័ក របស់

តថាគតនោះ, ទក្ខិណាទាន ឈ្មោះថា

មានផលតិចតួច មិនមាននោះឡើយ

ម្នាលមាតលិ អ្នកចូរមកចុះ, សូម្បីយើង

ទាំងឡាយ ក៏នឹងបូជាព្រះធាតុ របស់

ព្រះតថាគត ឱ្យលើសលុប ជាងនេះទៅទៀត

ការសន្សំនូវបុណ្យទាំងឡាយ ជាហេតុនាំឱ្យ

**មានសេចក្ដីសុខ កាលព្រះតថាគត ទ្រង់ឋិត**

**នៅក្ដី បរិនិព្វានទៅហើយក្ដី បើតាំងចិត្តស្មើ**

**ក៏មានផលស្មើ ព្រោះថា សត្វទាំងឡាយ អ្នក**

**មានការតម្កល់ចិត្តទុកជាហេតុ ទើបទៅកាន់**

**សុគតិបាន ទាយកទាំងឡាយ រមែងទៅកាន់**

**ឋានសួគ៌បាន ព្រោះធ្វើការបូជា ចំពោះព្រះ**

**តថាគតទាំងឡាយណា, ព្រះតថាគតទាំង**

**ឡាយនោះ ទ្រង់កើតឡើងក្នុងលោក ដើម្បី**

**ប្រយោជន៍ដល់ជនដ៏ច្រើនហ្ន៎ ។**

បុណ្យដែលបុគ្គលបានធ្វើហើយ្ត បន្តិចបន្តួច ក្នុងបុញ្ញខេត្តណា ជាបុណ្យមានផលច្រើន, ឥឡូវនេះ ស្ដេចសក្កទេវរាជ កាលនឹងសំដែងនូវ

បុញ្ញខេត្ត(ស្រែបុណ្យ)នោះធ្វើឱ្យបានប្រាកដ ទើបទ្រង់ត្រាស់នូវគាថាថា **នត្ថិ ចិត្តេ** ដូច្នេះជាដើម ។

ស្ដេចសក្កទេវរាជ លុះទ្រង់ត្រាស់សំដែង ដូច្នេះហើយ ទ្រង់រម្ងាប់នូវព្រះឧស្សាហ៍ ក្នុងការស្ដេចយាងទៅព្រះពាត ក្នុងព្រះឧទ្យាន ស្ដេចយាងត្រឡប់អំពីទីនោះឯងហើយ ទ្រង់ធ្វើការបូជា ក្នុងព្រះ **ចូឡាមណី-ចេតិយ** រហូតមួយសប្ដាហ៍ ក្នុងកាលក្រោយមក ទ្រង់បានត្រាស់នូវរឿងរ៉ាយនោះ ដល់ព្រះ **នារទត្ថេរ** ដ៏មានអាយុដែលកំពុងតែត្រាច់ទៅកាន់ចារិកក្នុងទេវលោក ដោយគាថាទាំងឡាយនេះ ។ ក្នុងពេលដែលធ្វើ **បឋមសង្គាយនា** ព្រះថេរៈ បានសម្ដែងប្រាប់ហើយ ដល់ព្រះ **ធម្មសង្គា-ហកាចារ្យ**ទាំងឡាយ ។ ព្រះថេរៈ ទាំងឡាយបានលើកយកពាក្យនោះឡើងកាន់ **សង្គាយនា** ហើយ ដូច្នោះឯង ។

**ចប់រឿងនាងកោសាតកីទេពធីតា**

# ប្រវត្តិដើមពោធិព្រឹក្ស នៅពុទ្ធគយា

តាមប្រវត្តិរឿងរ៉ាវ មហាពោធិព្រឹក្សនៅពុទ្ធគយា ដែលជាកន្លែង ដើមកំណើតព្រះពុទ្ធសាសនា ។ ក្រោយពីព្រះពោធិសត្វបំពេញទុក្ករកិរិយាអស់៦ឆ្នាំនៅភ្នំ**ដុង្គសិរិ**តំបន់**ឧរុវេលសេនានិគម**ទ្រង់លះបង់នូវការធ្វើ**អត្តកិលមថានុយោគ** ហើយទ្រង់ប្រព្រឹត្តជាកណ្តាលវិញដោយទ្រង់យាងបិណ្ឌបាត្រសោយចង្ហាន់តាមប្រក្រតី ។ ព្រះសិទ្ធត្ថពោធិសត្វក្រោយពីព្រះអង្គ បានទទួលមធុបាយាសពីនាងសុជាតា ទ្រង់សោយមធុបាយាសរួចហើយ ធ្វើកិច្ចអធិដ្ឋានបណ្តែតថាសមាសក្នុងស្ទឹង**នេរញ្ជរា** ហើយទ្រង់ឆ្លងទឹកស្ទឹងនេរញ្ជរាមកកាន់ពោធិមណ្ឌល ។ ក្នុងខណៈដែលព្រះអង្គកំពុងយាងទៅកាន់មណ្ឌលពោធិព្រឹក្ស សោត្ថិយព្រាហ្មណ៍នៅជិតផ្លូវនោះ កំពុងច្រូតស្បូវភ្លាំង ឃើញព្រះពោធិសត្វហើយបានថ្វាយស្បូវភ្លាំង៨ក្តាប់ដល់ព្រះអង្គ ។ ព្រះពោធិសត្វទ្រង់កាន់យក មកក្រាលគង់នៅក្រោមដើមពោធិ ។ មហាពោធិព្រឹក្សនេះ ជាសហជាតិវត្ថុដែលបានកើតឡើង

ក្នុងថ្ងៃដែលព្រះពោធិសត្វទ្រង់ប្រសូត្រ  គឺ មានអាយុដំណាលគ្នានឹងព្រះអង្គ សហជាតិវត្ថុ៧ដែលបានកើតឡើងក្នុងថ្ងៃពេញបូណ៌មីខែវិសាខមុនពុទ្ធស័ករាជ៨០ឆ្នាំ។ ១-ព្រះនាង យសោធរា ពិម្ពា ២-ព្រះអានន្ទពុទ្ធុបដ្ឋាកៈ៣-កាឡុទាយីអាមាត្យ  ៤-នាយឆន្នអាមាត្យ ៥-សេះកណ្ឋកៈ ៦-ដើមអស្សត្ថព្រឹក្ស គឺដើមពោធិព្រឹក្ស ៧-កំណប់ទ្រព្យទាំងបួន។ ព្រះពោធិសត្វយកស្បូវភ្លាំងទៅក្រាលជិតគល់ពោធិព្រឹក្ស នៅទិសខាងកើត  ទ្រង់គង់ប្រថាប់តាំងសច្ចាធិដ្ឋានដោយអង់អាចថា "សាច់ឈាមចូររីងស្ងួតចុះ! សូម្បីនៅសល់តែស្បែកសរសៃនិងឆ្អឹងក៏ដោយបើអាត្មាអញមិនបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណទេនឹងមិនលាព្រះភ្នែនក្រោកចាកទីនេះជាដាច់ខាត។ ក្នុងថ្ងៃពេញបូណ៌មី វិសាខមាសនក្ខត្តសម័យនៃរាត្រីនោះព្រះអង្គបានត្រាស់ដឹងនូវសព្វញ្ញុត្តញ្ញាណ  ជាព្រះពុទ្ធមង្គុដក្នុងលោក។  ព្រះមានព្រះភាគទ្រង់គង់ប្រថាប់ លើបល្ល័ង្ករតនី

ទៀបគល់ពោធិព្រឹក្សនេះអស់៧ថ្ងៃ ទ្រង់សោយវិមុត្តិសុខ ទើបព្រះអង្គក្រោក ចាកពីគល់ពោធិព្រឹក្ស យាងទៅឈរនៅទិសខាងកើត ហើយសម្លឹងមើលមហាពោធិព្រឹក្សដោយមិនប៉ប្រិចព្រះនេត្រ អស់៧ទិវា ទ្រង់សំដែងកតញ្ញូចំពោះមហាពោធិព្រឹក្ស ។ បឋមពោធិព្រឹក្ស គឺមហាពោធិព្រឹក្សដើមទីមួយនេះជាទីជ្រះថ្លាគោរពបូជារបស់មហាជនពុទ្ធសាសនិក និងជាបូជនីយដ្ឋានធំទី២ ដែលមានរៀបរាប់ក្នុងមហាបរិនិព្វានសូត្រ គម្ពីរទីឃនិកាយ ។ ហើយទីកន្លែងត្រាស់ដឹងត្រង់មហាពោធិព្រឹក្សនេះ មានមហាជនគោរពបូជាច្រើនជាងគេ ។ បណ្តាបូជនីយដ្ឋានទាំង ៤ **គឺកន្លែងព្រះសូត្រ កន្លែងត្រាស់ដឹង កន្លែងសំដែងធម្មចក្រ និងកន្លែងបរិនិព្វាន** ។ កន្លែងត្រាស់ដឹងនៅត្រង់ មណ្ឌលពោធិព្រឹក្សពុទ្ធគយា មានមហាជនមកគោរពបូជាច្រើនជាងគេទាំងថ្ងៃទាំងយប់មិនដែលដាច់រយៈ ។ តមកបឋមពោធិព្រឹក្សនេះ មានអាយុបាន ៣៥២ឆ្នាំ មកដល់រជ្ជកាលសម័យព្រះបាទ ធម្មាសោកមហារាជ ។ មហាពោធិព្រឹក្សទីមួយនេះស្លាប់ដោយស្នាដៃ

នៃ ព្រះអគ្គមហេសីអង្គទី៤របស់ព្រះរាជាអសោកមហារាជ ដោយសេចក្ដីច្រ-ណែន ចំពោះមហាពោធិព្រឹក្ស ។ ក្នុងសម័យពុទ្ធស័ករាជ ២១៨ឆ្នាំព្រះរាជាអភិសេក ឡើងគ្រងរាជសម្បត្តិ ដឹកនាំប្រទេសប្រកបដោយធមិ ក្រោយពីព្រះថេរៈមោគ្គលីបុត្តតិស្សត្ថេរៈ ញ៉ាំងព្រះរាជាឱ្យមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ឧបត្ថម្ភព្រះពុទ្ធសាសនាឱ្យរុងរឿង ព្រះអង្គបានឱ្យសេនាមាត្យកសាងមហាវិហារនៅជុំវិញមហាពោធិព្រឹក្ស និងកំពែងការពារជុំវិញ ព្រះស្រីមហាពោធិព្រឹក្ស ។ ក្នុងរជ្ជកាលរបស់ព្រះបាទធម្មាសោកមហារាជព្រះពុទ្ធសាសនារីកចម្រើនផ្សព្វផ្សាយទូលំទូលាយទូទាំងទ្វីបអាសុី ព្រះរាជាមានសទ្ធាមោះមុតក្នុងព្រះពុទ្ធសាសនា បានឱ្យព្រះរាជបុត្រ២ព្រះអង្គ បួសក្នុងព្រះពុទ្ធសាសនាបានជាអរហន្តាខីណាស្រព គឺ ព្រះមហិន្ទត្ថេរៈ និងព្រះសង្ឃមិត្តាថេរីឯកសារជាវត្ថុសំគាល់ មាននៅសល់គ្រប់ទីកន្លែង ក្នុងប្រទេសឥណ្ឌាព្រះអង្គបានកសាងសាសនវត្ថុជាច្រើនហើយព្រះអង្គចាប់អារម្មណ៏ជាងគេនោះ

គឺពេញព្រះទ័យត្រង់ទីកន្លែងត្រាស់ដឹង ព្រះអង្គតែងមកគោរពបូជាអង្គុយស-មាធិរៀងរាល់សប្តាហ៍មិនដែលខាន ឱ្យគេសំអាតរក្សាមហាពោធិព្រឹក្ស មាន-ពេលខ្លះព្រះអង្គបានប្រគល់រាជកិច្ចឱ្យពួកមន្ត្រីសេនាបតីធ្វើកិច្ចការជំនួសព្រះអង្គ ហើយព្រះអង្គយាងមកគង់ប្រថាប់នៅព្រះរាជដំណាក់ជិតមហាពោធិ -ព្រឹក្សពុទ្ធគយាចំនួនមួយសប្តាហ៍ខ្លះពីរសប្តាហ៍ខ្លះទ្រង់អង្គុយសមាធិនៅក្រោមព្រះស្រីមហាពោធិជារៀងរាល់ទិវារាត្រី ។ ដោយព្រះអង្គយកព្រះទ័យទុកដាក់គោរពបូជាចំរើនព្រះកម្មដ្ឋាននៅក្រោមម្លប់មហាពោធិព្រឹក្ស មិនសូវរវល់នឹងកិច្ចការក្នុងព្រះរាជវាំង ធ្វើឱ្យព្រះអគ្គមហេសីព្រះនាម"**មហីសុន្ទរី**" ឬហៅថាព្រះនាង **តិស្សរក្សិតា** មហេសីអង្គទីបួន ទ្រង់តូចព្រះទ័យមិនសប្បាយចិត្តដោយព្រះរាជាមិនសូវរវល់ ព្រះអង្គគិតតែ ធ្វើបុណ្យ ធ្វើសមាធិ ។

គ្រាដំបូងព្រះនាងប្រើស្នំឈ្មោះ **នគរា** ទៅទូលព្រះរាជាឱ្យយាងត្រឡប់មកព្រះរាជវាំងវិញ តែព្រះរាជាពុំយកព្រះទ័យស្តាប់ការទូលរបស់នាងស្នំ ព្រះ

អង្គុលិតតែពីការអង្គុយចំរើនកម្មដ្ឋាន ធ្វើឱ្យនាងស្នំ **នគរា** ក្រោធខឹងជាខ្លាំង

ហើយត្រឡប់មកទូលព្រះនាង **មហីសុន្ទរី** ដោយសព្វគ្រប់ ធ្វើឱ្យព្រះនាង

**មហីសុន្ទរី** ក្រោធខ្ទាល់មិនសប្បាយព្រះទ័យ ចងកម្មចងពៀរនឹងដើមមហា-

ពោធិព្រឹក្ស ច្រណែនឥស្សានឹងមហាពោធិព្រឹក្សរកឧបាយសម្លាប់ពោធិព្រឹក្ស ។

តមកព្រះនាងបានបញ្ជាឱ្យនាងស្នំឈ្មោះ **នគរា** ជាស្ត្រីបំរើជិតស្និទ្ធបំរើព្រះរាជា

លបលួចយកថ្នាំពុលខ្ចប់ដាក់ជាប់នឹងខ្លួនចូលទៅបំរើព្រះរាជាក្នុងបរិវេណពោ-

ធិមណ្ឌល  ស្ត្រីស្នំនោះធ្វើអាកប្បកិរិយាហាក់ដូចជាខ្លួនជ្រះថ្លានឹងមហាពោធិ-

ព្រឹក្សណាស់ ដើរប្រទក្សិណមហាពោធិព្រឹក្ស  ខណៈដែលព្រះរាជាគង់ប្រថាប់

ចំរើនព្រះកម្មដ្ឋានបិទព្រះនេត្រហើយ បានឱកាសស្រីស្នំនោះយកថ្នាំពុលលាយ

នឹងទឹកក្តៅចាក់ស្រោចតាមគល់តាមឫសច្រើនដង នៅពេលដែលនាងមកបំរើ

ព្រះរាជាក្នុងពោធិមណ្ឌល មិនបានប៉ុន្មានថ្ងៃដើមមហាពោធិព្រឹក្ស  ដែលមាន

អាយុបាន **៣៩២**ឆ្នាំត្រូវជាតិថ្នាំពុលក៏ស្វិតស្រពោនជ្រុះស្លឹកស្លាប់ក្នុងកាលនោះ

ដោយស្នាដៃឥស្សារបស់ព្រះនាង **មហីសុន្ទរី** ។ ព្រះរាជា **ធម្មាសោកមហារាជ** ទតឃើញព្រះស្រីមហាពោធិព្រឹក្សមានភាពមិនប្រក្រតី ស្វិតស្រពោនជ្រុះស្លឹក ដូច្នោះ មានព្រះទ័យទោមនស្សតូចព្រះទ័យគិតថា នេះជាបាបកម្មរបស់អាត្មាអញទេដឹង បានជាមហាពោធិព្រឹក្សស្លាប់ដូច្នេះ ។ ព្រះរាជាទ្រង់វិលត្រឡប់មកកាន់ព្រះរាជវាំងវិញ ។ ព្រះនាង **មហីសុន្ទរី** ឃើញព្រះរាជាមកកាន់ព្រះរាជវាំងវិញ មានចិត្តត្រេកអរណាស់ ព្រោះជាផលសម្រេចសមតាមសេចក្តីប្រាថ្នា របស់នាងដែលព្រះនាងបានឱ្យនាង **នគរា** យកថ្នាំពិសទៅដាក់សម្លាប់ដើមពោធិព្រឹក្ស តែព្រះរាជា **ធម្មាសោកមហារាជ** ព្រះអង្គមានព្រះទ័យកើតទុក្ខកង្វល់ទោមនស្ស មិនរីករាយព្រះទ័យដោយនឹកដល់មហាពោធិព្រឹក្សដែលស្លាប់ដោយមិនដឹងមូលហេតុ ក្រៀមក្រំព្រះទ័យទ្រង់ផ្ទុំសញ្ជប់សញ្ជឹងដល់បាបកម្មរបស់ខ្លួន ដែលព្រះអង្គបានធ្វើពីកាលមុន បានជាមហាពោធិព្រឹក្សស្លាប់ដោយឆាប់រហ័សដូច្នេះ ព្រះរាជាមានកង្វល់យ៉ាងខ្លាំងធ្វើព្រះកាយស្រុតចុះមានព្រះ-

ឈួនកើតខ្យល់វិលមុខទ្រង់ដួលទាំងជិហរសន្លប់ព្រះស្មារតី ខណៈនោះព្រះនាង **មហីសុន្ទរី** ឃើញហេតុការណ៍ដូច្នោះក៏ស្ទុះមកលើកត្រកងព្រះស្វាមីដោយអា-ការៈភ័យតក់ស្លុត ព្រះនាងទ្រង់ត្រកងព្យាបាលដោយព្រះអង្គឯង រហូតដល់ព្រះរាជាមានស្មារតីឡើងវិញ ។ ទើបព្រះនាងគិតថាបើអាត្មាអញមិនប្រាប់រឿងពិតដល់ព្រះអង្គទេ ប្រាកដជាព្រះរាជស្វាមីទ្រង់ទិវង្គតដោយពិត ព្រោះព្រះអង្គមិនសប្បាយព្រះទ័យសោះ ។ ខណៈនោះ ព្រះនាង **មហីសុន្ទរី** ទ្រង់ក្រាបបង្គំទូលតាមរឿងពិតពីរឿងមហាពោធិព្រឹក្សត្រូវស្លាប់ដោយស្នាដៃព្រះនាង ដោយសព្វគ្រប់ព្រះចៅ**ធម្មាសោកមហារាជ** ព្រះអង្គមានព្រះទ័យធូរ-ស្បើយឡើយវិញ ដោយពុំបានយកទោសពៃរ៍អ្វី ដល់ព្រះនាងនឹងនាងស្នំ ទើបព្រះរាជាវិលត្រឡប់ទៅកាន់ពោធិមណ្ឌលវិញ បញ្ជាឱ្យសេនាមាត្យសំអាតត្រង់ ពោធិព្រឹក្សដែលស្លាប់នោះ ធ្វើដីឱ្យស្អាតឡើងវិញហើយឱ្យយកទឹក ដោះគោ បរិសុទ្ធស្អាតចំនួន១០០មេ យកស្រោចត្រង់កន្លែងដើមពោធិដែលស្លាប់

នោះ ហើយព្រះអង្គគង់ប្រថាប់ចំរើនកម្មដ្ឋានសច្ចាធិដ្ឋានថា បើមិនមានដើម-ពោធិដុះមានពន្លកកើតឡើង ត្រង់កន្លែងនេះព្រះអង្គនឹងមិនក្រោកចេញពីទីនេះព្រះអង្គថ្វាយបូជាជីវិតក្នុងទីនេះ ។ គួរឱ្យអស្ចារ្យមែន ក្នុងរយៈពេលតែពីរបី ថ្ងៃប៉ុណ្ណោះ ក៏មានត្រួយពន្លកដុះចេញមកនៅត្រង់កន្លែងដើម ព្រះរាជាបានទតឃើញហើយ មានព្រះទ័យសប្បាយសោមនស្សរីករាយជាខ្លាំងត្រាស់បញ្ជាកងសេនាឱ្យធ្វើកំពែងការពារ មិនឱ្យអ្នកណាចេញចូលរហេតរហូត ដោយគ្មានការអនុញ្ញាត និងត្រួតពិនិត្យយ៉ាងតឹងរឹង ។ មហាពោធិព្រឹក្សដើមទីមួយ មានអាយុបាន**៣៥២**ឆ្នាំ គឺព្រះសម្ពុទ្ធបរិនិព្វានកន្លងទៅបាន **២៧២** វស្សា ។

# ពោធិព្រឹក្សទី២

ពន្លកត្រួយខ្ចីនៃពោធិព្រឹក្ស ដែលព្រះរាជា **ធម្មាសោកមហារាជ** ព្យាព្យាយាម ថែរក្សាដោយយកព្រះទ័យទុកដាក់ មានសេនានៅយាមការពារទាំងយប់ ទាំងថ្ងៃ មហាពោធិព្រឹក្សដើមទី២នេះ មានភាពចំរើនលូតលាស់ល្អជាទីគោរព បូជារបស់ព្រះចៅ **ធម្មាសោកមហារាជ** ។ ជាលំដាប់តមកពោធិព្រឹក្សទី២នេះជា ទីជ្រះថ្លានៃមហាជនគឺមានពុទ្ធបរិស័ទមកពីជិតឆ្ងាយចូលមកគោរពបូជាយ៉ាង ច្រើន ទាំងយប់ទាំងថ្ងៃមានមនុស្សចូលមកបូជាគ្រប់រដ្ឋក្នុងប្រទេស ឥណ្ឌានាក្នុងសម័យនោះ ។ ក្នុងខេត្រគយាសីសប្រទេស តំបន់ពុទ្ធគយានេះ សាសនាដទៃសាបសូន្យអន់ថយមិនមានលាភសក្ការៈ មិនមានបរិស័ទគោរព ជឿតាមគឺម្នាក់ៗមានមុខឆ្ពោះទៅកាន់បរិវេណពោធិមណ្ឌលធ្វើការបដិបត្តិបូជានិងអាមិសបូជាសម័យនោះព្រះពុទ្ធសាសនា ផ្សព្វផ្សាយទូលំទូលាយគ្រប់ទិសទីក្រោមការឧបត្ថម្ភរបស់ព្រះរាជាក្នុងដែនមគធៈ មហាពោធិព្រឹក្ស

នេះចំរើនរុងរឿងមកដល់ពុទ្ធសតវត្សទី១១ គឺពុទ្ធស័ករាជ ១១៦៣ មានភាពរីករវរឥស្សានឹងមហាពោធិព្រឹក្ស មានព្រះរាជាមួយអង្គ ព្រះនាម **សាសង្កា** ផ្អែកសាសនាហិន្ទូ នៅ**រដ្ឋបេង្គាល** ភាគខាងកើតនៃប្រទេសឥណ្ឌាបច្ចុប្បន្ន ប្រកាសខ្លួនជារដ្ឋឯករាជ្យ មិនចំណុះជាមួយព្រះចៅ **បុរណាវរមាមគធរដ្ឋ** តទៅទៀត។ បានប្រមូលកងទ័ពរាប់ពាន់ចូលមកកាន់បរិវេណពោធិមណ្ឌល ដោយក្រោធខឹងនឹងមហាពោធិព្រឹក្ស ដែលធ្វើឱ្យសាសនារបស់ខ្លួនសាបសូន្យ នៅក្នុងតំបន់ពុទ្ធគយានេះ បានបញ្ជាឱ្យសេនាកំទេចបំផ្លាញដើមពោធិព្រឹក្ស ដែលមានអាយុបាន ៨៩១ឆ្នាំ កាប់ចិញ្ច្រាំមែកស្លឹក ជីកកាយយកឫសដុតឱ្យទៅជាផេះធ្យូង ដុតបំពក់នៅត្រង់រណ្ដៅដែលជីកកាយយកឫសដោយចិត្តឫស្យា ក្រោធខឹងនឹងមហាពោធិព្រឹក្ស ដោយប្រាថ្នាថាឱ្យផុតពូជពោធិព្រឹក្សមិនឱ្យកើតឡើងបានទៀតនៅទីនេះ បញ្ជាឱ្យកងសេនាបំផ្លាញវិហារ នៅជុំវិញពោធិព្រឹក្សនិងនៅក្នុងតំបន់ពុទ្ធគយាទាំងមូល បញ្ជាឱ្យបំផ្លាញវត្តបំផ្លាញវិហារ

បំផ្លាញព្រះពុទ្ធរូបទាំងឡាយក្នុងទីនោះ មានព្រះពុទ្ធរូបមួយអង្គទ្រង់មារវិជ័យ ព្រះពុទ្ធរូបមួយអង្គនេះធំគ្រាន់នៅក្នុងមហាវិហារជិតមហាពោធិព្រឹក្សព្រះបាទ **សាសង្កា** បញ្ជាឱ្យសេនាបតីមួយរូប យកព្រះពុទ្ធរូបនេះចេញពីវិហារជិតពោធិព្រឹក្ស សេនាបតីនោះបានទទួលព្រះរាជបញ្ជាហើយទៅពិនិត្យមើលព្រះពុទ្ធរូបក្នុងមហាវិហារ ព្រះពុទ្ធរូបនោះឆ្លាក់ពីថ្មស្អាត ដោយសេនាបតីនោះជាអ្នកជ្រះថ្លាគោរពព្រះពុទ្ធសាសនា ដោយមានចិត្តស្លុតសង្វេគគិតពិចារណាថា បើអាត្មាអញមិនធ្វើតាមបញ្ជាតាមស្តេចរូបនេះ ជីវិតរបស់អញត្រូវដាច់ តែបើអញធ្វើបាបកម្មនេះ អាត្មាអញនឹងមានផលវិបាកយ៉ាងធ្ងន់ នឹងមិនបានឃើញមិនបានជួបនូវព្រះពុទ្ធអរិយមេត្តិយានឹងបានត្រាស់ដឹង ក្នុងកាលអនាគត ដោយពិតសេនាបតីរូបនេះគិតពិចារណាមួយសន្ទុះរកល្បិចកលបិទបាំងលាក់ទុកទីនេះកុំឱ្យព្រះរាជារូបនេះដឹង។ សេនាបតីរូបនេះប្រញាប់ប្រញាល់ចូលទៅបង្គំគាល់ព្រះរាជាវិញហើយក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពជាអម្ចាស់ព្រះអង្គ

មានព្រះរាជបញ្ជា ឱ្យខ្ញុំព្រះអង្គយកព្រះពុទ្ធរូបក្នុងវិហារនោះចេញក្នុងខណៈនេះ ភ្លាមមិនទាន់បានទេ ព្រោះព្រះពុទ្ធរូបអង្គនេះធំ សូមព្រះរាជឱកាសបាន៧ថ្ងៃ ដើម្បីខ្ញុំព្រះអង្គរកកម្លាំងនាំចេញលុះត្រាតែបាន ។ព្រះរាជាក៏ទ្រង់អនុញ្ញាត តាមការសុំរបស់សេនាបតី ។ សេនាបតីរូបនោះបានចាត់ចែងឱ្យអ្នកក្រោមបញ្ជាដែលជិតស្និទ្ធឱ្យធ្វើជាកំពែងបូកដី បិទឱ្យជិតមិនឱ្យអ្នកណាដឹងឃើញស្គាល់ហើយអុចប្រទីបបំភ្លឺទុកក្នុងរូងគុហានោះ ។ ហើយចូលទៅក្រាបទូលព្រះរាជាវិញថាខ្លួនបានចាត់ចែងយកព្រះពុទ្ធរូបនោះចេញហើយ ព្រះរាជាបានស្ដាប់ឮហើយ គួរតែត្រេកអររីករាយព្រោះសេចក្ដីប្រាថ្នារបស់ព្រះអង្គបានសម្រេចហើយ តែមួយរំពេចនោះព្រះរាជាអង្គនោះបែរជាក្អួតឈាមដាច់ខ្យល់ចូលទិវង្គតក្នុងពេលនោះ ព្រោះតែអំពើបាបកម្មរបស់ខ្លួន ។ ដោយបន្សល់ទុកនូវកងសេនានៅប្រចាំក្នុងទីតាំងដែលខ្លួនចាប់យកបាន ។ តែមិនយូរប៉ុន្មានការរឹករវរនេះបានជ្រាបដំណឹងដល់ព្រះចៅ **បុរណវរមាមគធរជ្ជ** ទ្រង់បញ្ជាសេនា-

បតីឱ្យនាំពលយោធាមកឡោមព័ទ្ធ វាយកម្ទេចកងទ័ពរបស់ព្រះចៅ**សាសង្កា** ដែលមកបៀតបៀនមហាពោធិព្រឹក្ស ទ្រង់វាយកំចាត់រត់បាក់ទ័ពបោសសំអាតអ្នកដែលមកប្រទូស្តរាយព្រះពុទ្ធសាសនា។ កងទ័ពរបស់ព្រះចៅ **បុរណាវរមា-មគធរដ្ឋ** បានកាន់កាប់ទាំងស្រុងក្នុងតំបន់ **គយាសីសៈ** និង **ពុទ្ធគយា** ព្រះ-អង្គយាងទៅពិនិត្យមើលនៅ ពោធិមណ្ឌល និង បរិវេណជុំវិញពុទ្ធស្ថានមហា-ពោធិព្រឹក្ស តើមានបាត់បង់ខូចខាតអ្វីខ្លះ ព្រះអង្គទ្រង់ទតឃើញមហាពោធិ-ព្រឹក្សត្រូវបំផ្លាញអស់មិនមានសល់សូម្បីតែឫសមួយកំណាត់ក៏មិនមានសេស-សល់គាស់កាយជារណ្តៅដុតបំផ្លាញទៅជាផេះធ្យូងព្រះរាជាទ្រង់សង្វេគសោកស្តាយជាខ្លាំង ទ្រង់ព្រះរាជបញ្ជាទៅសេនាបតីយោធា និងប្រជាជននៅជុំវិញពុទ្ធគយាឱ្យនាំគ្នារឹតយកទឹកដោះគោចំនួនមួយពាន់ក្បាល មកចាក់ស្រោចក្នុងរណ្តៅកន្លែងគល់ពោធិព្រឹក្សចាស់និងជុំវិញគល់ពោធិព្រឹក្ស ទ្រង់បញ្ជាឱ្យរៀបចំទីកន្លែងស្អាតឡើងវិញ ហើយព្រះអង្គទ្រង់គង់ប្រថាប់នៅចំពោះមុខកន្លែង

មហាពោធិព្រឹក្សចាស់នោះ តាំងសច្ចាធិដ្ឋានថា បើមិនមានមហាពោធិព្រឹក្ស មានពន្លកដុះឡើងក្នុងទីនេះទេ ខ្ញុំព្រះអង្គនឹងមិនគេចចេញពីទីនេះជាដាច់ខាត ថ្វាយបូជាជីវិតក្នុងទីនេះ ព្រះរាជាគង់ប្រថាប់ចំរើនមេត្តាភាវនានៅពោធិមណ្ឌលនេះ មិនយូរប៉ុន្មាន ដោយអំណាចសច្ចាធិដ្ឋាន និងបារមី នៃពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ ពោធិព្រឹក្សក៏មានដុះពន្លកមួយដើមត្រង់កន្លែងចាស់ គួរឱ្យអស្ចារ្យណាស់ព្រះរាជាទ្រង់ទតឃើញហើយ មានព្រះទ័យសោមនស្សរីក-រាយជាខ្លាំង ទ្រង់បញ្ជាឱ្យកងសេនាធ្វើកំពែងព័ទ្ធជុំវិញពោធិព្រឹក្ស យាមការពារត្រួតមើលមនុស្សចេញចូលដោយល្អ មិនឱ្យមានមនុស្សចូលទៅព្យាបាទបាន ។មហាពោធិព្រឹក្សដើមទីពីរនេះ មានអាយុបាន ៨៩១ឆ្នាំ។ ពុទ្ធស័ករាជ ១១៦៣ វស្សា ។

# មហាពោធិព្រឹក្សទី ៣

ដើមពោធិព្រឹក្សទី៣ ដែលព្រះរាជា **បុរណវរមា** បានបណ្តុះដាំឡើងវិញ ក្នុង ពុទ្ធស័ករាជ ១១៦៣ ព្រះអង្គបានថែរក្សា និងចម្រើនលូតលាស់ជាលំដាប់ ច្រើនដំណវង្ស ដែលពុទ្ធបរិស័ទជួយថែទាំមិនមានអ្នកបៀតបៀនមានអាយុ វែងបានមកដល់ពុទ្ធស័ក រាជ ២៤២១ មានអាយុបាន ១២៥៨ ឆ្នាំទើប ស្លាប់ ដោយចាស់ទ្រុឌទ្រោម នឹងត្រូវ ខ្យល់បក់បោកត្រូវ ។

តាមឯកសារនៅពុទ្ធគយាប្រាប់ថាមានជនជាតិអង់គ្លេសម្នាក់ជាអ្នកជំនាញការ ផ្នែកបូរាណវត្ថុ ឈ្មោះឧត្តមសេនីយ៍**ហ្សឺរ៉ែនឹងខាន់ហែម** មកកាន់ប្រទេសឥណ្ឌា ៣លើក បានមកពិនិត្យមើលនៅពោធិមណ្ឌលពុទ្ធគយា លើកទី១ ក្នុងឆ្នាំ ពុទ្ធស័ករាជ២៤១៥លើកទី២ក្នុងឆ្នាំពុទ្ធស័ករាជ២៤១៨បានឃើញមហាពោធិ-ព្រឹក្ស នេះចាស់ទ្រុឌទ្រោមណាស់ មានមែកបាក់មែកងាប់ស្លឹកជ្រុះច្រើនកន្លែង ហើយលោក ឧត្តមសេនីរូបនេះមកពុទ្ធគយាជាលើកទី៣ក្នុងឆ្នាំពុទ្ធស័ករាជ

២៤២១បានឃើញមហាពោធិព្រឹក្សនេះត្រូវស្លាប់ដោយខ្យល់ព្យុះបោកបក់ត្រូវ

មានគំនិតចង់ឱ្យមានពូជមហា ពោធិព្រឹក្សឡើងវិញ ក៏ធ្វើសំណុំរឿងទៅរដ្ឋា-

ភិបាលឥណ្ឌាក្នុង ខែត្រគយាសីសៈនេះរុះ រើគាស់កកាយដាំជាថ្មីឡើងវិញ ។

ដើមមហាពោធិព្រឹក្ស ទី៣នេះ មានអាយុបាន១២៥៨ ឆ្នាំ។

# មហាពោធិព្រឹក្សដើមទី៤

## ពោធិព្រឹក្សសព្វថ្ងៃនេះ

ពោធិព្រឹក្សដើមទី៤ នៅពុទ្ធគយាបច្ចុប្បន្ននេះ ក្រោយពីឧត្តមសេនីយ ហ្ស៊ីវ៉ឺនីងខាន់ហែម ពិនិត្យឃើញដើមពោធិព្រឹក្សទី៣ អស់អាយុហើយ លោកឧត្តមសេនីយ ខំពនិត្យដើររកគ្រាប់ពោធិព្រឹក្សនៅជុំវិញដើមពោធិព្រឹក្ស ដើម្បីយកមកបណ្ដុះ តែជាភ័ព្វ ល្អបានឃើញកូនពោធិព្រឹក្សដុះពន្លក ពីរដើម មួយដើមមានកម្ពស់៦ធ្នាប់ មួយដើម ទៀតមានកម្ពស់៤ធ្នាប់ ហើយលោក ឧត្តមសេនីយសូមការអនុញ្ញាតពីរដ្ឋាភិបាលក្នុង ខេត្រគយាសីសៈ គាស់កកាយ ដើមពោធិចាស់ដែលអស់អាយុហើយនោះធ្វើទីដីឱ្យស្អាត ឡើងវិញ ហើយយក កូនពោធិដែលមានកម្ពស់៦ធ្នាប់ មកដាំត្រង់កន្លែងចាស់ដូចដើម មួយដើម

ទៀតលោកឧត្តមសេនីយ៍ យកទៅដាំនៅទិសឦសានពោធិព្រឹក្សរតនបល្ល័ង្ក

ចម្ងាយប្រមាណជា ៥០ម៉ែត្រ ដោយលោកឧត្តមសេនីយ៍យល់ថាទីនោះ ជា

**អនិមិសកចេតិយ** កន្លែងព្រះពុទ្ធទ្រង់សំឡឹងមើលដើមពោធិព្រឹក្ស ។ តែតាម-

ការពិត **អនិមិសកចេតិយ**នៅចំទិសខាងកើតមហាពោធិព្រឹក្សដែលព្រះពុទ្ធអង្គ

ទ្រង់ឈរសម្លឹងមើលពោធិព្រឹក្ស នោះ ។

មហាពោធិព្រឹក្សដើមបច្ចុប្បន្ននេះ ដាំពីឆ្នាំ ពុទ្ធស័ករាជ២៤២១

មកដល់ឆ្នាំ ពុទ្ធស័ករាជ២៥៥១នេះ មានអាយុបាន១៣០ឆ្នាំហើយ ។

ដកស្រង់ចេញអំពី ប្រវត្តិពោធិព្រឹក្ស ដែលរៀបរៀងដោយភិក្ខុស្រីសុវណ្ណ **ចារុវណ្ណោ**

# ប្រវត្តិដើមពោធិព្រឹក្សក្នុងវត្តជេតពន

